## សេចក្ដីសង្ខេប

# របាយការណ៍អភិវឌ្ឍន៍មនុស្ស ឆ្នាំ ២០១៤

## ទ្រទ្រង់វឌ្ឍនភាពមនុស្ស៖

កាត់បន្ថយភាពងាយរងគ្រោះ និងកសាងភាពធន់



Copyright © 2014
by the United Nations Development Programme
1 UN Plaza, New York, NY 10017, USA

រក្សាសិទ្ធិគ្រប់យ៉ាង។ គ្មានផ្នែកណាមួយនៃរបាយការណ៍នេះអាចត្រូវបានយកទៅផលិតឡើងវិញ រក្សាទុកនៅក្នុងប្រព័ន្ធដែលអាចទាញមកប្រើប្រាស់ឡើងវិញ ឬ បញ្ជូនបន្ត ទោះតាមទម្រង់ណាមួយ ឬតាមមធ្យោបាយណាមួយក៏ដោយ សូម្បីជាទម្រង់អេឡិចត្រូនិក មេកានិក ការថតចម្លង អាត់សម្លេង ឬ តាមវិធីផ្សេងពីនេះ ប្រសិនបើគ្មានការអនុញ្ញាតជាមុន។

បញ្ជីសៀវភៅនេះមាននៅ British Library និង Library of Congress។

បោះពុម្ពនៅសហរដ្ឋអាមេរិក ដោយ PBM Graphics, an RR Donnelley Company, on Forest Stewardship Council certified and elemental chlorine-free papers. Printed using vegetable-based inks.

ពិនិត្យកែសម្រួល និងផលិតដោយ៖ Communications Development Incorporated, Washington DC, USA

Information design and data visualisation: Accurat s.r.l., Milan, Italy

ចំពោះកំហុសឆ្គង ឬពាក្យរម្លងនានាដែលបានរកឃើញនៅក្រោយពេលបោះពុម្ព សូមអាននៅក្នុងវេបសាយរបស់យើង http://hdr.undp.org

# ក្រុមចាត់ចែងរបាយការណ៍អភិវឌ្ឍន៍មនុស្សឆ្នាំ ២០១៤

## នាយក និងប្រធានក្រុមអ្នកនិពន្ធ

Khalid Malik

## នាយករង

Eva Jespersen

## អ្នកស្រាវជ្រាវ និងស្ថិតិ

Maurice Kugler (Head of Research), Milorad Kovacevic (Chief Statistician), Subhra Bhattacharjee, Astra Bonini, Cecilia Calderon, Alan Fuchs, Amie Gaye, Sasa Lucic, Arthur Minsat, Shivani Nayyar, Pedro Martins, Tanni Mukhopadhyay and José Pineda

## សារគមនាគមន៍ និងបោះពុម្ព

William Orme (ប្រធានផ្នែកសារគមនាគមន៍), Botagoz Abreyeva, Eleonore Fournier-Tombs, Anna Ortubia, Admir Jahic, Brigitte Stark-Merklein, Samantha Wauchope and Grace Sales

## របាយការណ៍អភិវឌ្ឍន៍មនុស្សថ្នាក់ជាតិ

Jon Hall (ប្រធានក្រុម), Christina Hackmann and Mary Ann Mwangi

## ប្រតិបត្តិការ និងរដ្ឋបាល

Sarantuya Mend (នាយកផ្នែកប្រតិបត្តិការ), Mamaye Gebretsadik and Fe Juarez-Shanahan

សេចក្តីសង្ខេប

# របាយការណ៍អភិវឌ្ឍន៍មនុស្សឆ្នាំ ២០១៤

## ទ្រទ្រង់វឌ្ឍនភាពមនុស្ស៖

កាត់បន្ថយភាពងាយរងគ្រោះ និងកសាងភាពធន់

Published for the
United Nations
Development
Programme
(UNDP)

UNDP
Empowered lives.
Resilient nations.

# បុព្វកថា

របាយការណ៍អភិវឌ្ឍន៍មនុស្សឆ្នាំ 2014 — *ទ្រទ្រង់វឌ្ឍនភាពមនុស្ស៖ កាត់បន្ថយភាពងាយរងគ្រោះ និងកសាងភាពធន់*—ពិនិត្យមើលសញ្ញាណពីរដែលប្រទាក់ប្រទងគ្នា និងមានសារៈសំខាន់ក្រៃលែងក្នុងការរក្សាវឌ្ឍនភាពនៃការអភិវឌ្ឍមនុស្ស។

ចាប់តាំងពីរបាយការណ៍អភិវឌ្ឍន៍មនុស្ស (HDR) ពិភពលោកលើកដំបូងរបស់កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP)នៅក្នុងឆ្នាំ 1990 មក ប្រទេសភាគច្រើនបានបង្ហាញឱ្យឃើញពី ការអភិវឌ្ឍមនុស្សគ្រាស់ក្រៃល។ របាយការណ៍ឆ្នាំនេះបង្ហាញថា និន្នាការជារួមលើពិភពលោកមានលក្ខណៈវិជ្ជមាន ហើយវឌ្ឍនភាពនៅតែមានជាបន្ត។ ប៉ុន្តែ ជីវិតមនុស្សកំពុងបន្តបាត់បង់ ហើយរបរចិញ្ចឹមជីវិត និងការអភិវឌ្ឍបានរងការខូចខាតដោយសារតែគ្រោះមហន្តរាយធម្មជាតិ ឬដែលបង្កដោយមនុស្ស និងវិបត្តិនានា។

យ៉ាងណាក៏ដោយ ចរន្តធាក់ថយទាំងនេះមិនមែនមិនអាចជៀសវាងបាននោះទេ។ បើទោះជាសង្គមនីមួយៗងាយប្រឈមនឹងហានិភ័យក៏ដោយ សង្គម ខ្លះប្រឈមនឹងគ្រោះថ្នាក់តិចតួចប៉ុណ្ណោះ និងងាយងើបមករកស្ថានភាពដើមវិញយ៉ាងឆាប់រហ័សជាងសង្គមផ្សេងទៀតនៅពេលដែលជួបគ្រោះថ្នាក់។ របាយការណ៍នេះ លើកសំណួរអំពីមូលហេតុនេះ ហើយនេះជាលើកដំបូងដែលរបាយការណ៍អភិវឌ្ឍន៍មនុស្សពិភពលោក គិតគូរអំពីភាពងាយរងគ្រោះ និងភាពធន់ តាមរយៈចក្ខុវិស័យនៃការអភិវឌ្ឍន៍មនុស្ស។

ការស្រាវជ្រាវដែលមានស្រាប់ជាច្រើន អំពីភាពងាយរងគ្រោះ បានគិតគូរអំពីការប្រឈមរបស់មនុស្សទៅនឹងហានិភ័យណាមួយ ហើយប្រការនេះមានភាពជាក់លាក់ទៅតាមវិស័យ។ របាយការណ៍នេះប្រកាន់យកវិធានខុសពីមុន និងមានលក្ខណៈគ្រប់ជ្រុងជ្រោយជាងមុន។ ក្នុងនេះវាពិចារណាអំពីកត្តានានាដែលរួមបង្កហានិភ័យដល់ការអភិវឌ្ឍមនុស្ស និងបន្ទាប់មកពិភាក្សាអំពីវិធីនានា ដែលក្នុងនោះគេអាចពង្រឹងភាពធន់សម្រាប់ក្រុមមនុស្សយ៉ាងច្រើន នៅចំពោះមុខ ហានិភ័យនានាដែលវិវត្តន៍ទៅមុខជានិច្ច។

វិធីនេះ មានសារៈសំខាន់ដោយឡែកនៅក្នុងពិភពលោកយើងនេះ ដែលមានភាពប្រទាក់ប្រទងគ្នា។ ទោះបីសកលភាវូបនីយកម្មបាននាំមកនូវផលប្រយោជន៍ ដល់មនុស្សជាច្រើនក៏ដោយ វាក៏នាំមកនូវកង្វល់ថ្មីៗ ដែលលេចឡើងនៅក្នុងដំណាក់កាលនានា ជាបែបប្រតិកម្មក្នុងស្រុកតបនឹងការសាយភាយឥទ្ធិពលពី ព្រឹត្តិការណ៍នានា ដែលកើតឡើងនៅទីឆ្ងាយ។ ការជួយប្រជាពលរដ្ឋឱ្យត្រៀមលក្ខណៈ សម្រាប់អនាគតមួយ ដែលមានភាពងាយរងគ្រោះតិចតួចជាង មានន័យថាជាការពង្រឹងភាពធន់សំខាន់ៗរបស់សហគមន៍ និងប្រទេសនានា។ របាយការណ៍នេះ ផ្តល់ជាមូលដ្ឋានគ្រឹះសម្រាប់ការធ្វើបែបនេះ។

ស្របជាមួយគំរូនៃការអភិវឌ្ឍមនុស្ស របាយការណ៍នេះប្រកាន់យកវិធានដែលផ្តោតលើមនុស្ស។ វាផ្តល់ការយកចិត្តទុកដាក់ជាពិសេសលើគម្លាតនៅក្នុងប្រទេស និងគម្លាតរវាងប្រទេសនានា។ វាកំណត់អត្តស ញ្ញាណក្រុមប្រជាពលរដ្ឋដែល "ងាយរងគ្រោះជារចនាសម្ព័ន្ធ" ពោលគឺ ក្រុមអ្នកដែលងាយរងគ្រោះខ្លាំងជាងក្រុមដទៃទៀត ដោយសារតែសាវតារបស់ពួកគេ ឬដោយសារតែពួកគេ រងនូវការប្រព្រឹត្តមិនស្មើភាពគ្នាពីសំណាក់ក្រុមមនុស្សដទៃទៀតនៅក្នុងសង្គម។ ភាពងាយរងគ្រោះទាំងនេះច្រើនតែបានវិវត្ត និងកើតមានឥតស្រាកស្រាន្តអស់ពេលជាយូរ ក្នុងនោះមានជាប់ពាក់ព័ន្ធ នឹងយេនឌ័រ ជាតិពន្ធុ ស្ថានភាព ជាជនជាតិដើមភាគតិច ឬ តាមទីកន្លែងជាក់លាក់ ក្នុងចំណោមកត្តាដទៃទៀត ជាច្រើន។ ប្រជាជន និង ក្រុមមនុស្សងាយរងគ្រោះបំផុតទាំងនេះជាច្រើន ប្រឈមបញ្ហាជាច្រើនម្តងហើយម្តងទៀត ដែលបង្កជាឧបសគ្គរាំងសមត្ថភាព ក្នុងការទប់ទល់នឹងបញ្ហានៃវិបត្តិនានា។ ឧទាហរណ៍ អ្នកក្រីក្រ ក៏ស្ថិតនៅក្នុងក្រុមជនភាគតិចផងដែរ ឬ ជាស្ត្រី និង មានពិការភាព ប្រឈមនឹងរបាំងជាច្រើន ដែលអាចជាការពង្រឹងគ្នាទៅវិញទៅមកក្នុងន័យអវិជ្ជមាន។

របាយការណ៍នេះ ពិចារណាអំពីវិធីដែលក្នុងនោះភាពងាយរងគ្រោះប្រែប្រួលនៅក្នុង ខ្សែជីវិតរបស់យើងដោយប្រកាន់យក "វិធាននៃវដ្តជីវិតទាំងមូល"។ មិនដូចម៉ូដែលអសកម្ម ការវិភាគនេះបង្ហាញថា កុមារមនុស្សជំទង់ និងមនុស្សចាស់ សុទ្ធតែប្រឈមហានិភ័យខុសៗគ្នា ដែលទាមទារឱ្យមានការឆ្លើយតបឱ្យចំគោលដៅ។ ដំណាក់កាលខ្លះក្នុងជីវិតត្រូវបានកំណត់ថាមានសារៈសំខាន់ជាពិសេស ដូចជា រយៈពេល 1.000 ថ្ងៃដំបូងនៃជីវិតរបស់កុមារ ឬ អន្តរកាលពីសាលារៀនទៅការងារ ឬ ពីការងារទៅដំណាក់កាលចូលនិវត្តន៍។ ដំណើរថយក្រោយនៅត្រង់ចំណុចទាំងនេះ អាចបង្កជា

ការលំបាកក្រៃលែងក្នុងការជំនះ ហើយមនុស្សជាច្រើនរងផលប៉ះពាល់បែបនេះរយៈពេលវែង។

ផ្អែកលើការវិភាគភស្តុតាងដែលមាន របាយការណ៍នេះបានលើកអនុសាសន៍សំខាន់ៗមួយចំនួន ដើម្បីសម្រេចបានពិភពលោកមួយដែលដោះស្រាយភាពងាយរងគ្រោះ និងបង្កើតភាពធន់ ចំពោះការប៉ះទង្គិចទៅអនាគត។ វាអំពាវនាវឱ្យមានការទទួលបានជាសកលនូវសេវាសង្គមសំខាន់ៗ ជាពិសេស សុខភាព និងការអប់រំ កិច្ចគាំពារសង្គមរឹងមាំជាងមុន ដែលរួមទាំងការធានារ៉ាប់រងលើភាពគ្មានការងារធ្វើ និងសោធននិវត្តន៍ និងការប្តេជ្ញាចំពោះ ភាពមានការងារធ្វើពេញលេញដោយទទួលស្គាល់ថា គុណតម្លៃនៃភាពមានការងារធ្វើមានវិសាលភាពធំធេងណាស់ ធៀបនឹងប្រាក់ចំណូល ដែលការងារផ្តល់ឱ្យ។ របាយការណ៍នេះ ពិនិត្យមើលសារៈសំខាន់នៃស្ថាប័ន ដែលមានការឆ្លើយតប និង ដែលត្រឹមត្រូវ និងកំណើនភាពចុះសម្រុងក្នុងសង្គម ដើម្បីបង្កើតភាពធន់នៅកម្រិតសហគមន៍ និងសម្រាប់កាត់បន្ថយលទ្ធភាពនៃការកើតមានទំនាស់។

របាយការណ៍នេះ ទទួលស្គាល់ថា ទោះបីគោលនយោបាយមានប្រសិទ្ធភាពកម្រិតណាក៏ដោយ ក្នុងការកាត់បន្ថយភាពងាយរងគ្រោះ វិបត្តិនឹងនៅតែបន្តកើតមានជាមួយផលវិបាក ប្រកបដោយសក្តានុពលមហន្តរាយ។ ការកសាងសមត្ថភាពសម្រាប់ត្រៀមបង្ការគ្រោះមហន្តរាយ និងការស្តារឡើងវិញ ដែលជួយសហគមន៍ឱ្យទប់ទល់បាននឹងស្ថានភាពធាតុអាកាស និងស្តារស្ថានភាពពីការប៉ះទង្គិចនានា បានប្រសើរជាងមុន មានសារៈសំខាន់ជាអាយុជីវិត។ នៅកម្រិតពិភពលោក ការទទួលស្គាល់ថា ហានិភ័យមានលក្ខណៈ ឆ្លងដែន ទាមទារឱ្យមានចំណាត់ការរួមគ្នា។ របាយការណ៍នេះអំពាវនាវឱ្យមានការប្តេជ្ញានៅកម្រិតពិភពលោក និងឱ្យមានអភិបាលកិច្ចប្រសើរជាងមុននៅកម្រិតអន្តរជាតិ។

អនុសាសន៍ទាំងនេះ សុទ្ធតែមានសារៈសំខាន់ និងត្រូវចំពេលទៀតផង។ ក្នុងពេលដែលរដ្ឋសមាជិកអង្គការសហប្រជាជាតិ ត្រៀមខ្លួនដើម្បីបញ្ចប់ការចរចាអំពីរបៀបវារៈអភិវឌ្ឍន៍សម្រាប់ក្រោយឆ្នាំ 2015 និង ប្រកាសគោលដៅអភិវឌ្ឍន៍ដោយចីរភាព ភស្តុតាង ដែលប្រមូលបាន និងដែលបានវិភាគនៅក្នុងរបាយការណ៍នេះ និងទស្សនវិស័យអំពីការអភិវឌ្ឍមនុស្សដែលជាបង្អែកនៃការវិភាគនេះ ពិតជាមានតម្លៃជាពិសេស។ ឧទាហរណ៍ ការលុបបំបាត់ភាពក្រីក្រ នឹងក្លាយជាគោលដៅស្នូលនៃរបៀបវារៈថ្មី។ ប៉ុន្តែ របាយការណ៍នេះអះអាងថា ប្រសិនបើប្រជាជន នៅតែប្រឈមហានិភ័យនៃការធ្លាក់ខ្លួនត្រឡប់ទៅក្នុងភាពក្រីក្រវិញ ដោយសារតែកត្តានានាដែលមានលក្ខណៈរចនាសម្ព័ន្ធ និងភាពងាយរងគ្រោះ ពុំរ៉ែ វឌ្ឍនភាពនៃការអភិវឌ្ឍនឹងនៅតែគ្មានភាពទៀងទាត់ឡើយ។ ការលុបបំបាត់ភាពក្រីក្រ មិនមែនត្រឹមតែមានន័យថា "ឈានឱ្យដល់ចំណុចសូន្យនៃភាពក្រីក្រ" នោះទេ ប៉ុន្តែ វាក៏ជាការធ្វើយ៉ាងណារក្សាស្ថានភាពគ្មានភាពក្រីក្រឱ្យបានរហូតផងដែរ។

ដើម្បីសម្រេចចក្ខុវិស័យរបស់កម្មវិធី អភិវឌ្ឍន៍សហប្រជាជាតិ ក្នុងការជួយប្រទេសនានាសម្រេចឱ្យបានទន្ទឹមគ្នានូវការលុបបំបាត់ភាពក្រីក្រ និងការកាត់បន្ថយបានច្រើននូវវិសមភាព និងការមិនរាប់រកក្នុងសង្គម ព្រមទាំងដើម្បីលើកកំពស់ការអភិវឌ្ឍមនុស្ស និងការអភិវឌ្ឍដោយចីរភាព គេទាមទារឱ្យមានការទទួលស្គាល់ស៊ីជម្រៅនូវសញ្ញាណនានានៃភាពងាយរងគ្រោះ និងភាពធន់។ ល្គឹកណាភាពងាយរងគ្រោះមិនត្រូវបានដោះស្រាយប្រកបដោយប្រសិទ្ធភាព ហើយប្រជាជនទាំងអស់មានឱកាសចែករំលែកវឌ្ឍនភាពនៃការអភិវឌ្ឍមនុស្ស ការចម្រើន ទៅមុខនៃការអភិវឌ្ឍ នឹងពុំមានសមធម៌ ហើយក៏មិនមាននិរន្តរភាពឡើយ។

របាយការណ៍នេះ មានគោលដៅជួយអ្នកធ្វើសេចក្តីសម្រេច និងភ្នាក់ងារអភិវឌ្ឍន៍ដទៃទៀតរក្សាបីបាច់កំណើននៃការអភិវឌ្ឍ តាមរយៈគោលនយោបាយនានាដែលកាត់បន្ថយភាពងាយរងគ្រោះ និងកសាងភាពធន់។ ខ្ញុំសូមឧទ្ទិសរបាយការណ៍នេះ ដល់អ្នកទាំងឡាយដែលប្រាថ្នា ចង់ឃើញវឌ្ឍនភាពនៃការអភិវឌ្ឍមានចីរភាព ជាពិសេសសម្រាប់ពលរដ្ឋ ដែលងាយរងគ្រោះបំផុតក្នុងពិភពលោកយើងនេះ។



**ហេឡិន ក្លាក**
អភិបាល
កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ

# មាតិការបាយការណ៍អភិវឌ្ឍមនុស្សឆ្នាំ ២០១៤


បុព្វកថា
សេចក្តីថ្លែងអំណរគុណ

ទិដ្ឋភាពរួម

## ជំពូក ១

ភាពងាយរងគ្រោះនិងការអភិវឌ្ឍមនុស្ស
ទស្សនៈវិស័យការអភិវឌ្ឍមនុស្ស
ប្រជាពលរដ្ឋងាយរងគ្រោះ ពិភពលោកងាយរងគ្រោះ
ជម្រើសនិងសមត្ថភាព
គោលនយោបាយ និង ចំណាត់ការរួមគ្នា

## ជំពូក ២

ស្ថានភាពនៃការអភិវឌ្ឍមនុស្ស
វឌ្ឍនភាពរបស់ប្រជាពលរដ្ឋ
ការគម្រាមកំហែងជាសកលចំពោះការអភិវឌ្ឍមនុស្ស

## ជំពូក ៣

ប្រជាពលរដ្ឋងាយរងគ្រោះ ពិភពលោកងាយរងគ្រោះ
សមត្ថភាពជីវិត និង ភាពងាយរងគ្រោះនៃវដ្តជីវិត
ភាពងាយរងគ្រោះជារចនាសម្ព័ន្ធ
អំពើហិង្សាជាក្រុម និង ជីវិតអសន្តិសុខ

## ជំពូក ៤

កសាងភាពធន់៖ សេរីភាពត្រូវបានពង្រីក ជម្រើសត្រូវបានការពារ
ការផ្តល់ជាសកលនូវសេវាសង្គមជាមូលដ្ឋាន
ដោះស្រាយភាពងាយរងគ្រោះវដ្តជីវិត
ជម្រុញឱ្យមានការងារពេញលេញ
ពង្រឹងកិច្ចគាំពារសង្គម
ដោះស្រាយបញ្ហាបរិយាប័ន្នសង្គម
បង្កើនសមត្ថភាពដើម្បីត្រៀមខ្លួននិងស្តារស្ថានភាពក្រោយមានវិបត្តិ

## ជំពូក ៥

ពង្រឹងវឌ្ឍនភាពឱ្យកាន់តែស៊ីជម្រៅ៖ គុណសម្បត្តិជាសកលនិងចំណាត់ការរួមគ្នា
ភាពងាយរងគ្រោះរវាងប្រជាជាតិ
គិតគូរផលប្រយោជន៍របស់ប្រជាពលរដ្ឋមុនគេ
ចំណាត់ការរួមគ្នាដើម្បីពិភពលោកមួយមានសុវត្ថិភាពជាងមុន

កំណត់សំគាល់
ឯកសារយោង

## ឧបសម្ព័ន្ធស្ថិតិ

សេចក្តីណែនាំសម្រាប់អ្នកអាន
សេចក្តីពន្យល់អំពីសន្ទស្សន៍អភិវឌ្ឍន៍មនុស្សនិងលំដាប់តាមប្រទេស ឆ្នាំ 2013
តារាងស្ថិតិ

1. សន្ទស្សន៍អភិវឌ្ឍន៍មនុស្សនិងសមាសភាគរបស់វា
2. និន្នាការសន្ទស្សន៍អភិវឌ្ឍន៍មនុស្ស 1980-2013
3. សន្ទស្សន៍អភិវឌ្ឍន៍មនុស្សដែលបានគិតបញ្ចូលវិសមភាព
4. សន្ទស្សន៍វិសមភាពយេនឌ័រ
5. សន្ទស្សន៍អភិវឌ្ឍន៍យេនឌ័រ
6. សន្ទស្សន៍ភាពក្រីក្រពហុទិដ្ឋភាព

6A. សន្ទស្សន៍ភាពក្រីក្រពហុទិដ្ឋភាព៖ ការប្រែប្រួលកន្លងមក (សូមជ្រើសរើសប្រទេស)

7. សុខភាព៖ កុមារ និង យុវវ័យ
8. សុខភាពជនពេញវ័យ និង ការចំណាយលើសុខភាព
9. ការអប់រំ
10. ការគ្រប់គ្រងនិងបែងចែកធនធាន
11. សមាហរណកម្មសង្គម
12. អសន្តិសុខបុគ្គល
13. សមាហរណកម្មអន្តរជាតិ
14. បរិស្ថាន
15. និន្នាការប្រជាសាស្ត្រ
16. សូចនាករបន្ថែម៖ ការយល់ឃើញអំពីសុខុមាលភាព

តំបន់
ទិន្នន័យយោង



# សេចក្តីសង្ខេប

*ដូចរបាយការណ៍អភិវឌ្ឍន៍មនុស្ស (HDRs)* ជាបន្តបន្ទាប់បានបង្ហាញរួចមកហើយ ប្រជាជនភាគច្រើននៅក្នុងប្រទេសភាគច្រើនសម្រេចបានភាពប្រសើរក្នុងការអភិវឌ្ឍមនុស្សជាលំដាប់។ ការឈានទៅមុខខាងបច្ចេកវិទ្យា ការអប់រំនិងប្រាក់ចំណូលបានផ្តល់សក្តានុពលកាន់តែច្រើនសម្រាប់ការរស់នៅបានអាយុវែង មានទ្រព្យសម្បត្តិ និងសន្តិសុខច្រើនជាងមុន។ ប៉ុន្តែទន្ទឹមនឹងនេះក៏មានការយល់ឃើញជាទូទៅផងដែរអំពីភាពមិនទៀងទាត់នៅក្នុងពិភពលោកសព្វថ្ងៃនេះខាងរបរចិញ្ចឹមជីវិត សន្តិសុខផ្ទាល់ខ្លួន បរិស្ថាន និងនយោបាយពិភពលោក។ សមិទ្ធផលយ៉ាងខ្ពស់លើទិដ្ឋភាពសំខាន់ៗនៃការអភិវឌ្ឍមនុស្ស ដូចជា សុខភាព និងអាហារូបត្ថម្ភ ងាយនឹងខូចខាតទៅវិញយ៉ាងឆាប់រហ័ស ដោយសារតែគ្រោះមហន្តរាយ ធម្មជាតិ ឬការដួលរលំនៃសេដ្ឋកិច្ច។ ចោរកម្ម និងការវាយប្រហារ អាចធ្វើឱ្យប្រជាជនកាន់តែខ្សត់ខ្សោយទាំងខាងរាងកាយ និងស្មារតី។ អំពើពុករលួយ និងកង្វះការឆ្លើយតបពីស្ថាប័នរដ្ឋ អាចធ្វើឱ្យអ្នកដែលត្រូវការជំនួយស្ថិតនៅក្នុងស្ថានភាពដែលគ្មានជម្រើស។

ដូច្នេះ វឌ្ឍនភាពពិតប្រាកដខាងការអភិវឌ្ឍមនុស្សមិនត្រឹមតែទាក់ទងនឹងការពង្រីកជម្រើសសំខាន់ៗ របស់ប្រជាពលរដ្ឋ និងលទ្ធភាពរបស់ពួកគេ ក្នុងការទទួលបានការសិក្សាអប់រំ មានសុខភាពល្អមានស្តង់ដារនៃការរស់នៅសមស្រប និងអារម្មណ៍ថាមានសុវត្ថិភាពប៉ុណ្ណោះទេ។ ចំណោតនៅត្រង់ថា តើសមិទ្ធផលទាំងនេះ វាឋិតថេរគង់វង្សបានប៉ុណ្ណា និងថាតើលក្ខខណ្ឌនានា មានភាពគ្រប់គ្រាន់សម្រាប់ធានានិរន្តរភាពនៃការអភិវឌ្ឍមនុស្សឬទេ។ ការគិតគូរអំពីវឌ្ឍនភាពនៃការអភិវឌ្ឍមនុស្សពុំមានភាពពេញលេញឡើយ ប្រសិនបើមិនបានស្វែងយល់ និងវាយតម្លៃភាពងាយរងគ្រោះទេនោះ។

ជាប្រពៃណី សញ្ញាណអំពីភាពងាយរងគ្រោះត្រូវបានប្រើប្រាស់សម្រាប់អធិប្បាយ អំពីការរងឥទ្ធិពលពីហានិភ័យ និងការគ្រប់គ្រងហានិភ័យ ដែលរាប់បញ្ចូលការធានាទល់នឹងការប៉ះទង្គិច និងការធ្វើពិពិធកម្ម ទ្រព្យ និងប្រាក់ចំណូល។ របាយការណ៍នេះប្រើប្រាស់គោលការណ៍ ទូលំទូលាយជាងមុន ដោយសង្កត់ធ្ងន់លើចំណងតំណជិតស្និទ្ធរវាងការកាត់បន្ថយ*ភាពងាយរងគ្រោះ* និងជម្រុញការអភិវឌ្ឍមនុស្ស។ យើងបង្ហាញជូនសញ្ញាណ ភាពងាយរងគ្រោះនៃមនុស្សដើម្បីអធិប្បាយអំពីបុរេសនានៃការបាត់បង់សមត្ថភាព និងជម្រើសរបស់ប្រជាជន។ សញ្ញាណអំពីភាពងាយរងគ្រោះមិនសូវមានលក្ខណៈអរូបិយទេ នៅពេលដែលគេបំបែកវាឱ្យឃើញច្បាស់ថា អ្នកណាងាយរងគ្រោះ តើពួកគេងាយរងគ្រោះពីអ្វី និងដោយសារហេតុអ្វី (រូបទី 1)។

យើងសង្កត់ធ្ងន់ជាពិសេស លើប្រភពភាពងាយរងគ្រោះដែលមានលក្ខណៈជាប្រព័ន្ធ និងជាប់ជាប្រចាំព្រមទាំងសួរពីមូលហេតុដែលអ្នកខ្លះធ្វើបានល្អជាងអ្នកដទៃ ក្នុងការជំនះស្ថានភាពមិនអនុគ្រោះ។ ប្រជាជនជួបប្រទះបញ្ហាអសន្តិសុខក្នុងកម្រិតផ្សេងគ្នា និងប្រភេទខុសគ្នានៃភាពងាយរងគ្រោះ នៅក្នុងដំណាក់កាលខុសគ្នាក្នុងជីវិតរបស់ពួកគេ។ កុមារមនុស្សជំទង់ មនុស្សចាស់ សុទ្ធតែងាយរងគ្រោះ ដូច្នេះយើងសួរថា តើការវិនិយោគ និងអន្តរាគមន៍បែបណាខ្លះ ដែលអាចកាត់បន្ថយភាពងាយរងគ្រោះនៅក្នុងអំឡុងពេលនៃអន្តរកាល ដែលផុយស្រួយបំផុតនៅក្នុងជីវិត។

រូបទី 1៖

**អ្នកណាងាយរងគ្រោះ កត្តាអ្វីខ្លះធ្វើឱ្យពួកគេងាយរងគ្រោះ និងមូលហេតុ?**




ប្រភព៖ការិយាល័យរបាយការណ៍អភិវឌ្ឍន៍មនុស្ស

*ភាពងាយរងគ្រោះបង្កការគំរាមកំហែងលើការអភិវឌ្ឍមនុស្ស ហើយដរាបណាវាមិនត្រូវបានដោះស្រាយជាលក្ខណៈប្រព័ន្ធ ដោយកែប្រែគោលនយោបាយ និងនិយាមសង្គម វឌ្ឍនភាពនឹងគ្មានសមធម៌ ឬនិរន្តរភាពឡើយ។*

របាយការណ៍នេះធ្វើទឡ្ហីករណ៍ថា និរន្តរភាពនៃការពង្រឹងសមត្ថភាពរបស់បុគ្គលនិងសង្គមគឺជាកត្តាចាំបាច់ ដើម្បីកាត់បន្ថយភាពងាយរងគ្រោះជាប់ជាប្រចាំទាំងនេះ ដែលភាគច្រើនរបស់វាមានជារចនាសម្ព័ន្ធ និងខ្លះទៀតស្ថិតនៅជាប់ក្នុងវដ្តជីវិតតែម្តង។ វឌ្ឍនភាពត្រូវតែជាការពង្រឹងភាពធន់នៃការអភិវឌ្ឍមនុស្ស។ មានការជជែកវែកញែកជាច្រើនអំពីខ្លឹមសារនៃភាពធន់ ប៉ុន្តែយើងសង្កត់ធ្ងន់លើ*ភាពធន់នៃមនុស្ស* ពោលគឺការធានាថា ជម្រើសរបស់ប្រជាជន មានភាពមាំមួន ទាំងក្នុងពេលបច្ចុប្បន្ន ក៏ដូចជាទៅអនាគត និងជួយធ្វើឱ្យប្រជាជនទប់ទល់ ព្រមទាំងសម្របខ្លួនទៅនឹងព្រឹត្តិការណ៍អវិជ្ជមាននានាផង។ ស្ថាប័នរចនាសម្ព័ន្ធ និងនិយាមអាចពង្រឹងភាពធន់នៃមនុស្ស ឬធ្វើឱ្យភាពធន់នេះចុះខ្សោយទៅវិញ។ គោលនយោបាយរបស់រដ្ឋនិងបណ្តាញគាំទ្រ សហគមន៍អាចពង្រឹងសិទ្ធិអំណាចរបស់ប្រជាជនដើម្បីជំនះការគំរាមកំហែងនានានៅក្នុងពេល និងតាមទីកន្លែងដែលការគំរាមកំហែងទាំងនោះកើតឡើង ចំណែកវិសមភាពក្នុងចំណោមមនុស្សនៅក្នុងក្រុមជាមួយគ្នា អាចធ្វើឱ្យបាត់បង់សមត្ថភាពទប់ទល់របស់ក្រុមទាំងនោះផងដែរ។

របាយការណ៍នេះ ស្វែងយល់អំពីប្រភេទនៃគោលនយោបាយ និងកំណែទម្រង់ស្ថាប័នដែលអាចកសាងភាពធន់នៅក្នុងរចនាសម្ព័ន្ធសង្គម ជាពិសេសសម្រាប់ក្រុមដែលសង្គមមើលរំលង និងនៅក្នុងអំឡុងពេលផុយស្រួយបំផុតនៃជីវិត។ វាពិនិត្យមើលវិធានការសកលនានាដែលអាចកាត់បន្ថយការរើសអើង និងផ្តោតលើតម្រូវការឱ្យមានចំណាត់ការរួមគ្នា ដើម្បីដោះស្រាយភាពងាយរងគ្រោះដែលកើតចេញពីស្ថាប័នជាតិដែលគ្មានការឆ្លើយតប និងភាពខ្វះចន្លោះនៃអភិបាលកិច្ចពិភពលោក។

## វឌ្ឍនភាពមនុស្ស

*របាយការណ៍អភិវឌ្ឍន៍មនុស្សឆ្នាំ 2013* បង្ហាញថា ប្រទេសកំពុងអភិវឌ្ឍន៍ចំនួនច្រើនជាង 40 ដែលមានចំនួនប្រជាជនច្រើនជាងគេលើពិភពលោក មានកំណើនយ៉ាងច្រើនខាងសន្ទស្សន៍អភិវឌ្ឍន៍មនុស្ស ជាងអ្វីដែលបានព្យាករណ៍ ដោយផ្អែកលើស្ថានភាពនៃប្រទេសទាំងនោះកាលឆ្នាំ 1990។ យ៉ាងណាក៏ដោយ យើងមិនអាចធ្វើការសន្មតបែបនេះ ជាទូទៅបានឡើយ។ មានភស្តុតាងបង្ហាញថា អត្រាជារួមនៃវឌ្ឍនភាពកំពុងថយចុះក្នុងចំណោមក្រុម ទាំងអស់នៃការអភិវឌ្ឍមនុស្ស (រូបទី 2)។ ប្រការសំខាន់គឺត្រូវដោះស្រាយ ភាពងាយរងគ្រោះ ចាប់ពីឥឡូវនេះ ដើម្បីការពារកំណើនដែលទទួលបានកន្លងមក និងទប់ស្កាត់ឧបសគ្គនានា ដែលរារាំងវឌ្ឍនភាពជាបន្ត។ ក្នុងដំណើរឆ្ពោះទៅកាន់របៀបវារៈក្រោយ ឆ្នាំ 2015 និងការរៀបចំគោលដៅអភិវឌ្ឍន៍ដោយចីរភាព នេះជាពេលដែលសហគមន៍អន្តរជាតិត្រូវធ្វើការឆ្លុះបញ្ចាំង និងជាឱកាសដើម្បីកែប្រែ និងបង្កើតឱ្យមានកិច្ចសហប្រតិបត្តិការតាមទម្រង់ថ្មីៗនៅកម្រិតពិភពលោក ដើម្បីកាត់បន្ថយភាពងាយរងគ្រោះដែលមានជាប់ជាប្រចាំ និងដែលមានជាលក្ខណៈប្រព័ន្ធ។

យើងក៏ត្រូវសួរសំណួរងាយមួយផងដែរថា៖ តើវិបុលភាពរបស់អ្នកណាដែលយើងកំពុងឃ្លាំមើល? យើងត្រូវសម្លឹងហួសពីតួលេខមធ្យម និងប្រាក់ចំណូលអប្បបរមាដើម្បីប្រមូលយកទស្សនៈកាន់តែទូលំទូលាយអំពីថា តើការកែលម្អខាងសុខុមាលភាព មានរបាយបែបណាក្នុងចំណោមបុគ្គល សហគមន៍ និង ប្រទេស។ ការបាត់បង់ជាមធ្យមខាងការអភិវឌ្ឍមនុស្ស ដោយសារតែវិសមភាពបានថយចុះនៅក្នុងតំបន់ភាគច្រើនក្នុងបណ្តាឆ្នាំកន្លងទៅថ្មីៗនេះ ដែលភាគច្រើនបានមកពីការកើនខាងសុខភាព។ ប៉ុន្តែភាពខុសគ្នា ខាងប្រាក់ចំណូលបានកើនឡើងនៅក្នុងតំបន់មួយចំនួន ហើយវិសមភាពខាងការអប់រំនៅតែមានទំហំធំធេងជាប្រចាំនៅឡើយ។ ការថយចុះនៃវិសមភាពគួរតែបានទទួលការអបអរសាទរ ប៉ុន្តែ ការលុបបំបាត់គម្លាតខាងប្រាក់ចំណូល ដែលកំពុងតែកើនឡើងតាមរយៈវឌ្ឍនភាពខាងសុខភាព នៅពុំគ្រប់គ្រាន់ទេ។ ដើម្បីដោះស្រាយភាពរងគ្រោះ ជាពិសេស ក្នុងចំណោមក្រុមមនុស្សទន់ខ្សោយការធានានិរន្តរភាពនៃសមិទ្ធផលដែលទទួលបានថ្មីៗនេះ ការកាត់បន្ថយវិសមភាពលើគ្រប់ទិដ្ឋភាពទាំងអស់នៃការអភិវឌ្ឍមនុស្សមានសារៈសំខាន់ណាស់។

## ប្រជាពលរដ្ឋងាយរងគ្រោះ ពិភពលោកងាយរងគ្រោះ

បណ្តាអ្នកដែលរស់នៅក្នុងភាពក្រីក្រធ្ងន់ធ្ងរ និងខ្សត់ខ្សោយស្ថិតក្នុងចំណោមក្រុមមនុស្ស ដែលងាយរងគ្រោះបំផុត។ បើទោះជាមានវឌ្ឍនភាពជាច្រើនត្រូវបានសម្រេចក្នុងការកាត់បន្ថយភាពក្រីក្រយ៉ាណាក្តី ក៏នៅមានប្រជាជនជាង ២,២ ពាន់លាននាក់ ដែលកំពុងរស់នៅក្បែរបន្ទាត់ភាពក្រីក្រ ឬក្នុងភាពក្រីក្រពហុទិដ្ឋភាពនៅឡើយ (រូបទី 3)។ នេះមានន័យថា ច្រើនជាង 15% នៃប្រជាជនលើពិភពលោកនៅតែងាយរងគ្រោះដោយសារកត្តាជាច្រើននៃភាពក្រីក្រ។ ទន្ទឹមនឹងនេះ ប្រជាជនជិត 80% លើពិភពលោក ខ្វះកិច្ចគាំពារសង្គមគ្រប់ជ្រុងជ្រោយ។ ប្រជាជនប្រមាណ 12% (842 លាននាក់) រងគ្រោះដោយសារភាពអត់ឃ្លានរ៉ាំរ៉ៃ និងចំនួនជិតពាក់កណ្តាលនៃកម្មករទាំងអស់ ពោលគឺច្រើនជាង 1,5ពាន់លាននាក់ កំពុងស្ថិតនៅក្នុងការងារមិនរៀបរយ ឬ ការងារមិនទៀងទាត់។

ប្រជាជនដែលមានសមត្ថភាពស្នូល ក្នុងកម្រិតកំណត់ ដូចជា សមត្ថភាពខាងការអប់រំ និងសុខភាព ពុំសូវមានភាពងាយស្រួលក្នុងការដឹកនាំខ្សែជីវិត តាមការចង់បានរបស់ខ្លួនឡើយ។ ជម្រើសរបស់ពួកគេអាចមាន កម្រិតកំណត់ ឬមិនអាចពង្រីកបានឡើយដោយសារតែរបាំងសង្គម និងទម្លាប់ដទៃទៀតនៃការរើសអើងនៅក្នុងសង្គម។ សមត្ថភាពក្នុងកម្រិតកំណត់ និងជម្រើសក្នុងកម្រិតកំណត់រួមជាមួយគ្នាបង្កើតជាកត្តារារាំងដែលមិនអាចឱ្យពួកគេ ទប់ទល់នឹង

រូបទី 2៖

**ក្រុមអភិវឌ្ឍន៍មនុស្សទាំងបួន បានបង្ហាញពីភាពយឺតយ៉ាវជាងមុននៃកំណើនសន្ទស្សន៍អភិវឌ្ឍន៍មនុស្ស**




សំគាល់៖ ក្រុមនានានៅក្នុងប្រទេសជឿនលឿន និងប្រទេសកំពុងអភិវឌ្ឍន៍ចំនួន 141 ជាមួយតួលេខកែតម្រូវខ្លះៗ
ប្រភព៖ ការគណនារបស់ការិយាល័យរបាយការណ៍អភិវឌ្ឍន៍មនុស្ស

ការគំរាមកំហែងនានាបានឡើយ។ នៅក្នុងដំណាក់កាលខ្លះៗ ជីវិត សមត្ថភាពអាចត្រូវកំហិតដោយសារតែការវិនិយោគ និងការយកចិត្តទុកដាក់មិនគ្រប់គ្រាន់ ទៅតាមពេលវេលាសមស្រប ដែលធ្វើឱ្យភាពងាយរងគ្រោះនានាអាចកើនឡើងបាន និងកាន់តែធ្ងន់ធ្ងរ។ ក្នុងចំណោមកត្តាដែលមានឥទ្ធិពលមកលើទម្រង់នៃការប៉ះទង្គិច និងដំណើរថយក្រោយ និងវិធីនៃការដោះស្រាយបញ្ហាទាំងនេះ គឺស្ថានភាពរបស់ពួកគេនៅក្នុងពេលកើត អាយុ អត្តសញ្ញាណនិងស្ថានភាពសេដ្ឋកិច្ចសង្គម - កាលៈទេសៈដែលបុគ្គលនានាមានសមត្ថភាពតិចតួច ឬគ្មានសមត្ថភាពក្នុងការត្រួតត្រា។

## ភាពងាយរងគ្រោះក្នុងវដ្តជីវិត

សមត្ថភាព ត្រូវបានកសាងឡើងជាបណ្តើរៗនៅក្នុងជីវិត និងត្រូវតែបានទទួលការបំពាក់បំប៉នបន្ថែមនិងថែរក្សា បើពុំនោះទេសមត្ថភាពទាំងនេះនឹងត្រូវបាត់បង់ទៅវិញ។ ភាពងាយរង គ្រោះ (និងភាពខ្លាំង) ជាច្រើនរបស់ប្រជាជន គឺជាលទ្ធផលនៃសាវតានៅក្នុងជីវិតរបស់ពួកគេ ដែលផលសម្រេចពីអតីតភាពរបស់ពួកគេ មានឥទ្ធិពលមកលើស្ថានភាពបច្ចុប្បន្ន និងរបៀបទប់ទល់ការប្រឈមនានា។ សមត្ថភាពនៅក្នុងជីវិតមានពីរបែប។ ទីមួយសមត្ថភាពក្នុងដំណាក់កាលណាមួយ នៃការរស់នៅរងឥទ្ធិពលពីការវិនិយោគនៅដំណាក់កាលខាងដើមនៃជីវិតរបស់ពួកគេ។ ពួកគេក៏រងឥទ្ធិពល ដោយសារតែស្ថានភាពអន្តរកាលនៃបរិស្ថានជុំវិញផ្ទាល់សហគមន៍ និងសង្គមផងដែរ។ ទីពីរការប៉ះទង្គិចរយៈពេលខ្លីច្រើនតែបង្កផលវិបាករយៈពេលវែង។ បុគ្គលនានា អាចពុំមានលទ្ធភាពក្នុងការស្តារស្ថានភាពដែលទំនងជាកើតឡើងដោយសារ ការប៉ះទង្គិចនៅក្នុងអន្តរកាលនោះឡើយ។ គេអាចធ្វើឱ្យឥទ្ធិពលខ្លះប្រែក្រឡាស់បាន ប៉ុន្តែមិនមែនធ្វើបានរហូតទេ ទៅតាមបរិបទជាក់លាក់ ហើយក៏វាមិនសុទ្ធតែមានប្រសិទ្ធភាព ខាងការចំណាយឡើយ។

ក្នុងករណីដែលការវិនិយោគធ្វើឡើង នៅក្នុងដំណាក់កាលដើមដំបូងនៃជីវិត បុរេសនាទៅអនាគត មានលក្ខណៈល្អជាង (សូមអានខ្សែជាប់ពណ៌ខៀវក្នុងរូបទី 4)។ ស្ថានភាពផ្ទុយពីនេះក៏ពិតផងដែរ ពោលគឺ ការវិនិយោគមិនទាន់ពេលវេលា និងជាប់ជាបន្តលើសមត្ថភាពសម្រាប់ការរស់នៅអាច

ភាពងាយរងគ្រោះក្នុងវដ្តជីវិត
ភាពងាយរងគ្រោះជារចនាសម្ព័ន្ធ និងជីវិតអសន្តិសុខ គឺជាប្រភពចំបងនៃភាពអត្តខាត់រ៉ាំរ៉ៃ ដែលត្រូវតែដោះស្រាយឱ្យបាន ទើបការអភិវឌ្ឍមនុស្ស និងវឌ្ឍនភាពមាននិរន្តរភាព។

### រូបទី 3៖

**ប្រជាជនប្រមាណ 1,2ពាន់លាននាក់ រស់នៅជាមួយចំណូលតិចជាង 1,25ដុល្លារក្នុងមួយថ្ងៃ និង ១,៥ពាន់លាននាក់ រស់នៅក្នុងភាពក្រីក្រពហុទិដ្ឋភាព**




ប្រភព៖ ភាពក្រីក្រពហុទិដ្ឋភាព - ការគណនារបស់ការិយាល័យរបាយការណ៍អភិវឌ្ឍន៍មនុស្ស បានផ្អែកលើការអង្កេតនានាតាមគ្រួសារ ដែលរួមទាំងការអង្កេតប្រជាសាស្ត្រ និងសុខភាពនៅកម្រិតម៉ាក្រូរបស់អង្គការ ICF ការអង្កេតពហុសូចនាករនៃមូលនិធិសហប្រជាជាតិដើម្បីកុមារ និងការអង្កេតគ្រួសារនៅថ្នាក់ជាតិមួយចំនួន។ ភាពក្រីក្រខាងប្រាក់ចំណូល - ការគណនារបស់ការិយាល័យរបាយការណ៍អភិវឌ្ឍន៍មនុស្ស បានផ្អែកលើទិន្នន័យពីកម្រងទិន្នន័យសូចនាករអភិវឌ្ឍន៍មនុស្សនៃធនាគារពិភពលោក។

ធ្វើឱ្យខាតបង់ធ្ងន់ធ្ងរចំពោះសមត្ថភាពរបស់បុគ្គលនានា ក្នុងការសម្រេចបានពេញលេញនូវសក្តានុពលអភិវឌ្ឍន៍មនុស្ស (សូមអាន ខ្សែជាប់ពណ៌ក្រហមក្នុងរូបទី 4)។ អន្តរាគមន៍ក្នុងអំឡុងពេលក្រោយមក អាចជួយបុគ្គលនានាស្តារស្ថានភាពឡើងវិញ ប៉ុន្តែតាមធម្មតាអាចស្តារបានតែមួយផ្នែកប៉ុណ្ណោះ និងអាចឈានទៅរកលំនាំនៃការអភិវឌ្ឍមនុស្សខ្ពស់ជាងមុន (សូមអានខ្សែដាច់ៗពណ៌ខៀវក្នុងរូបទី 4) ។

ជាញឹកញាប់ ភាពក្រីក្រគឺជាការរំខានចំពោះលំនាំជាធម្មតានៃវ័យវឌ្ឍនាការតាំងពីកុមារភាព ពោលគឺ កុមារច្រើនជាងម្នាក់ក្នុងចំណោមប្រាំនាក់ នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ រស់នៅក្នុងភាពក្រីក្រខាងប្រាក់ចំណូល និងងាយរងគ្រោះដោយសារបញ្ហាកង្វះអាហារូបត្ថម្ភ។ នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ (ដែលមានកុមារច្រើនជាង 92% រស់នៅ) 7នាក់ ក្នុងចំណោម 100នាក់ មិនអាចមានអាយុច្រើនជាង 5ឆ្នាំឡើយ 50នាក់ ពុំបានចុះបញ្ជីកំណើតរបស់ខ្លួនឡើយ 68នាក់ពុំបានចូលរៀនតាំងពីកុមារភាពឡើយ 17នាក់ មិនបានចុះឈ្មោះនៅថ្នាក់បឋមសិក្សាឡើយ 30នាក់ លូតលាស់មិនពេញលេញ និង 25នាក់ រស់នៅក្នុងភាពក្រីក្រ។ កង្វះស្បៀងអាហារសម្បូទាសម្រាប់អនាម័យ និងសម្រាប់ការរស់នៅស្អាត ធ្វើឱ្យកើនហានិភ័យនៃករណីមានជម្ងឺ និងការលូតលាស់មិនពេញលេញ៖ កុមារចំនួនជិត 156លាននាក់ លូតលាស់មិនពេញលញ ដោយសារតែកង្វះអាហារូបត្ថម្ភ និងការកើតជម្ងឺ។ កង្វះអាហារូបត្ថម្ភ រួមចំណែកនាំឱ្យមាន 35% នៃករណីបាត់បង់ជីវិតបណ្តាលពីរោគ កញ្ជ្រិល គ្រុនចាញ់ រោគរលាកសួត និងរាគរូស។ ផលប៉ះពាល់នេះមានកម្រិតធ្ងន់ធ្ងរបំផុត ប្រសិនបើការបាត់បង់បែបនេះកើតឡើងតាំងពីនៅកុមារភាព។ កង្វះអាហារូបត្ថម្ភជាមូលដ្ឋានការថែទាំសុខភាព និងការលើកទឹកចិត្ត ដើម្បីជម្រុញការលូតលាស់ ប្រកបដោយសុខភាពល្អ ធ្វើឱ្យកុមារក្រីក្រជាច្រើនខ្វះសមត្ថភាព ស្រូបយកបានការរៀនសូត្រ ហើយពួកគេ រៀនមិនពូកែ រៀនត្រួតថ្នាក់ និងទំនងជាត្រូវបោះបង់ចោលសាលារៀន។ សូម្បីនៅអាយុ 6ឆ្នាំ ឬនៅពេល

រូបទី 4៖

**ទស្សនវិស័យសម្រាប់អនាគតនឹងមានភាពប្រសើរជាងមុនកាលណាគេវិនិយោគលើសមត្ថភាពពីដំណាក់កាលដំបូងនៃជីវិត**




ប្រភព៖ ការគណនារបស់ការិយាល័យរបាយការណ៍អភិវឌ្ឍន៍មនុស្ស

ដែលគ្រប់អាយុចូលរៀន កុមារក្រីក្រអាចស្ថិតក្នុងស្ថានភាពបង់ចាញ់ រួចទៅហើយ (រូបទី 5)។ គម្លាតខាងជំនាញកើតមានតាំងពីដើមដំបូង។ ឧទាហរណ៍ការរៀនពាក្យចាប់ផ្តើមតាំងពីនៅវ័យក្មេង។ នៅសហរដ្ឋអាមេរិកនៅអាយុ 36ខែ ជំនាញនិយាយរបស់កុមារក្នុងគ្រួសារដែលមានស្ថានភាពសេដ្ឋកិច្ចសង្គមខុសៗគ្នា មានភាពខុសគ្នាគួរឱ្យកត់សំគាល់ ហើយភាពខុសគ្នា ឬ លំនាំនៃជំនាញក្នុងការនិយាយនៅតែមាននៅឡើយរហូតដល់អាយុ 9ឆ្នាំ។ ដូច្នេះអន្តរាគមន៍ទាន់ពេលវេលា ដូចជាការវិនិយោគលើការអប់រំតាមពីកុមារភាព មានសារៈសំខាន់ណាស់។

យុវវ័យ 15 ទៅ 24 ឆ្នាំ គឺជាអំឡុងពេល គន្លឹះនៃអន្តរកាល នៅពេលដែលពួកគេរៀនអំពីការចូលប្រឡូកក្នុងសង្គម និងក្នុងការងារ។ ក្នុងប្រទេសជាច្រើនចំនួនពលរដ្ឋវ័យក្មេងកំពុងកើនឡើង។ ពលរដ្ឋវ័យក្មេងនៅជុំវិញពិភពលោក ងាយរងគ្រោះជាពិសេស បណ្តាលពីការមិនយកចិត្តទុកដាក់ នៅក្នុងទីផ្សារការងារដោយសារ ពួកគេខ្វះបទពិសោធន៍ការងារបណ្តាញសង្គមសមត្ថភាព ស្វែងរកការងារ និងធនធានហិរញ្ញវត្ថុ ដើម្បីស្វែងរកការងារ។ ដូច្នេះពួកគេទំនងជាគ្មានការងារធ្វើ ធ្វើការមិនពេញសក្តានុពល ឬ ធ្វើការតាមកិច្ចសន្យាដែលគ្មានភាពទៀងទាត់។ នៅឆ្នាំ 2012 អត្រាយុវជនគ្មានការងារធ្វើនៅជុំវិញពិភពលោកត្រូវបានប៉ាន់ស្មានថាមាន 12,7% ដែលត្រូវជាជិតបីដងនៃអត្រាសម្រាប់មនុស្សពេញវ័យ។

គោលនយោបាយបែបមហិច្ឆតា មានសារៈសំខាន់ណាស់ ដើម្បីសម្រេចបាន តាមការរំពឹងទុករបស់ពលរដ្ឋវ័យក្មេង ក្នុងទីផ្សារការងារ។ ក្រោមសេណារីយ៉ូ "គោលនយោបាយប្រកបដោយមហិច្ឆតា" ភាពគ្មានការងារធ្វើនៃយុវជនលើពិភពលោក គួរតែមានទាបជាង 5% រហូតដល់ឆ្នាំ 2050 ដោយសារតែឥទ្ធិពល ទ្វេដងនៃពលរដ្ឋវ័យក្មេងក្នុងចំនួនតិចជាង ដែលចូលក្នុងទីផ្សារ ការងារ និងកំណើនសេដ្ឋកិច្ចដែលមានអត្រាខ្ពស់ជាង។ ទោះជាយ៉ាងណាក៏ដោយ ភាពចម្រុះនៅកម្រិតតំបន់ក៏មានសារៈសំខាន់ផងដែរ។ នៅក្រោមសេណារីយ៉ូ "ធុរកិច្ចតាមធម្មតា" គម្លាតនេះអាចនឹងបន្តកើនឡើង ជាពិសេស នៅតំបន់សាហារ៉ា ក្បែរអាហ្វ្រិក។ ប៉ុន្តែគោលនយោបាយ ប្រកបដោយមហិច្ឆតា (គោលនយោបាយអប់រំដែលផ្តល់ផល ឆាប់រហ័ស និងការបង្កើនសំទុះកំណើនសេដ្ឋកិច្ច) អាចបិទភ្ជិតគម្លាតរវាងការផ្គត់ផ្គង់ និងតម្រូវការកម្មករវ័យក្មេងនៅអាស៊ីអាគ្នេយ៍ និង

## រូបទី 5៖

### កុមារក្រីក្រមានភាពបង់ចាញ់ខាងជំនាញវាក្យស័ព្ទតាំងពីអាយុ 6ឆ្នាំម្ល៉េះ ដូចមានបង្ហាញក្នុងករណីប្រទេសអេក្វាឌ័រ




ប្រភព៖ Paxson and Schady 2007.

## រូបទី 6៖

### គោលនយោបាយដែលផ្តល់ផលឆាប់រហ័ស និងការបង្កើនសំទុះកំណើនសេដ្ឋកិច្ច អាចលុបបំបាត់គម្លាតនៃការផ្គត់ផ្គង់ និងតម្រូវការកម្មករវ័យក្មេង នៅអាស៊ីខាងត្បូង និងកាត់បន្ថយគម្លាតនេះនៅតំបន់សាហារ៉ាក្បែរអាហ្វ្រិករវាងឆ្នាំ 2010 និង 2050




ប្រភព៖ ការគណនារបស់ការិយាល័យរបាយការណ៍អភិវឌ្ឍន៍មនុស្សបានផ្អែកលើ Lutz and KC (2013) និង Pardee Center for International Futures (2013)

កាត់បន្ថយគម្លាតនេះ សម្រាប់តំបន់សាហារ៉ាក្បែរអាហ្វ្រិក (រូបទី 6)។ នៅអាស៊ីខាងត្បូង គម្លាតនេះ អាចបិទភ្ជិតរហូតដល់ឆ្នាំ 2050 ដោយសារតែឥទ្ធិពលទ្វេដងនៃគោលនយោបាយអប់រំស្តីពីឌីណាមិកប្រជាជន (ដែលអាចកាត់បន្ថយចំនួនពលរដ្ឋវ័យក្មេងដែលចូលក្នុងទីផ្សារការងារ) និងកំណើនសេដ្ឋកិច្ចដែលមានខ្ពស់ជាង។ សម្រាប់តំបន់សាហារ៉ាក្បែរអាហ្វ្រិក គោលនយោបាយបន្ថែម ដើម្បីបង្កើនប្រពលភាពការងារដើម្បីកំណើនសេដ្ឋកិច្ច គឺជាតម្រូវការចាំបាច់ដើម្បីបិទភ្ជិតគម្លាតនេះ។

ភាពក្រីក្រ និងការមើលរំលងពីសំណាក់សង្គមជាបញ្ហាសម្រាប់បណ្តាអ្នកដែលមានវ័យចំណាស់ ជាពិសេសដោយសារប្រជាពលរដ្ឋក្នុងវ័យចំណាស់ប្រមាណ 80% លើពិភពលោកពុំមានប្រាក់សោធននិវត្តន៍ និងពឹងផ្អែកលើពលកម្ម និងពឹងផ្អែកលើគ្រួសារសម្រាប់ប្រភពប្រាក់ចំណូល។ នៅពេលមនុស្សឈានដល់បច្ឆឹមវ័យ ជាទូទៅពួកគេមានស្ថានភាពរាងកាយ ស្មារតី និងសេដ្ឋកិច្ច កាន់តែងាយរងគ្រោះ។ ភាពក្រីក្រ ក្នុងចំណោមមនុស្សចាស់ច្រើន ទំនងជាមានលក្ខណៈ រ៉ាំរ៉ៃ ដោយសារពួកគេ ខ្វះឱកាស និងសន្តិសុខខាងសេដ្ឋកិច្ច នៅក្នុងដំណាក់កាលដើមដំបូងនៃជីវិតរបស់ពួកគេ ដែលធ្វើឱ្យពួកគេងាយរងគ្រោះនៅពេលចាស់។ ភាពបង់ចាញ់ដែលប្រមូលផ្តុំគ្នា ជាបន្តបន្ទាប់កាលនៅវ័យក្មេង ក៏មានន័យផងដែរថាជាការផ្ទេរភាពក្រីក្ររវាងមនុស្សពីមួយជំនាន់ ទៅមួយជំនាន់ទៀតផងដែរ។

## ភាពងាយរងគ្រោះជារចនាសម្ព័ន្ធ

ក្នុងករណីដែលស្ថាប័នសង្គម និងច្បាប់រចនាសម្ព័ន្ធអំណាចលំហានយោបាយ ឬ ប្រពៃណី និងនិយាម សង្គមវប្បធម៌ មិនបម្រើផលប្រយោជន៍របស់សមាជិក ក្នុងសង្គមបានស្មើគ្នា និងក្នុងករណីដែលកត្តាទាំងនេះបង្កើតរបាំងជារចនាសម្ព័ន្ធចំពោះប្រជាជន និងក្រុមខ្លះៗ ក្នុងការអនុវត្តសិទ្ធិ និងជម្រើសរបស់ពួកគេ ប្រការទាំងនេះ នាំមកនូវភាពងាយរងគ្រោះជារចនាសម្ព័ន្ធកាន់តែខ្លាំងឡើង។ ជាញឹកញាប់ ភាពងាយរងគ្រោះជារចនាសម្ព័ន្ធស្តែងឱ្យឃើញ តាមរយៈវិសមភាពស៊ីជម្រៅ និង ភាពក្រីក្រជាទូទៅ ដែលមានការពាក់ព័ន្ធជាមួយវិសមភាពរវាងក្រុមនានា និងវិសមភាពនៅក្នុងក្រុម អាស្រ័យតាមការទទួលស្គាល់ក្នុងសង្គម និងរចនាសម្ព័ន្ធក្រុមមនុស្សទាំងនោះ។ ជនក្រីក្រ ស្ត្រី ជនជាតិភាគតិច (ជាតិពន្ធុ ភាសា សាសនា ចំណាក ស្រុក ឬ ភេទ) ជនជាតិដើម ប្រជាជននៅតាមជនបទ ឬ តំបន់ដាច់ស្រយាល ឬ ដែលរស់នៅជាមួយពិការភាពនិងប្រទេសមិនជាប់សមុទ្រ ឬ មានធនធានធម្មជាតិក្នុងកម្រិតកំណត់ ទំនងជាប្រឈម ឧបសគ្គកាន់តែច្រើន និងជួនកាលថែមទាំងមានរបាំងខាងផ្លូវច្បាប់ផងដែរដែលរារាំងពួកគេមិនឱ្យកសាងសមត្ថភាព អនុវត្តជម្រើស និងការទាមទារសិទ្ធិរបស់ខ្លួន ដើម្បីទ្រទ្រង់ និងការពារខ្លួនបាន នៅក្នុងករណីរងការប៉ះទង្គិចនានា។

អសន្តិសុខសម្រាប់បណ្តាអ្នកដែលប្រឈមភាពងាយរងគ្រោះជាលក្ខណៈរចនាសម្ព័ន្ធបានវិវត្តន៍ និងមានជាប់ជាបន្តរយៈពេលវែង ដែលនាំឱ្យមានការបែងចែកដាច់គ្នារវាងភេទ ជាតិពន្ធុ ពូជសាសន៍ ប្រភេទការងារ និងឋានានុក្រមក្នុងសង្គម ដែលមិនងាយកំចាត់ចោលបានឡើយ។ ពលរដ្ឋដែលមានស្ថានភាពងាយរងគ្រោះជារចនាសម្ព័ន្ធ ក៏អាចមានសមត្ថភាពដូច អ្នកដទៃផងដែរ ប៉ុន្តែនៅតែអាចប្រឈមឧបសគ្គបន្ថែម ដែលមិនឱ្យពួកគេជំនះលក្ខខណ្ឌអវិជ្ជមានទាំងនោះបាន។ ឧទាហរណ៍ ជនពិការច្រើនតែពុំមានប្រកចេញចូលងាយស្រួលនៅតាមមធ្យោបាយដឹកជញ្ជូនសាធារណៈ ការិយាល័យ រដ្ឋាភិបាល និងទីសាធារណៈដទៃទៀត ដូចជា មន្ទីរពេទ្យ ដែលធ្វើឱ្យពួកគេកាន់តែលំបាកក្នុងការចូលរួម នៅក្នុងជីវភាពសេដ្ឋកិច្ច សង្គម និងនយោបាយ ឬ ក្នុងការស្វែងរកជំនួយនៅពេលពួកគេប្រឈមការគំរាមកំហែងចំពោះសុខុមាលភាពខាងរាងកាយរបស់ខ្លួន។

មនុស្សជាច្រើន ប្រឈមនឹងរចនាសម្ព័ន្ធនៃឧបសគ្គត្រួតគ្នាមួយចំនួន ដែលរារាំងសមត្ថភាពរបស់ពួកគេក្នុងការទប់ទល់ ដូចជា អ្នកក្រ និងមនុស្សក្នុងក្រុមជន ភាគតិច ឬស្ត្រីពិការ។ ជនក្រីក្រចំនួនបីភាគបួនលើពិភពលោករស់នៅតាមទីជនបទ ចំណែកកម្មករក្នុងវិស័យកសិកម្មប្រឈមនឹងអត្រាខ្ពស់បំផុតនៃភាពក្រីក្រ។ ពួកគេរស់នៅក្នុងស្ថានភាពដែលមានផលិតភាពទាប ភាពគ្មានការងារធ្វើតាមរដូវ ប្រាក់ឈ្នួលទាប និងងាយរងគ្រោះជាពិសេសនៅចំពោះមុខការប្រែប្រួលរបបធាតុអាកាស។ ក្រុមជនជាតិដែលត្រូវគេបំបាត់សិទ្ធិ និងក្រុមដែលមានជំនឿសាសនាភាគតិច មានភាពងាយរងគ្រោះ ដោយសារតែប្រពៃណីនៃការរើសអើង មានលទ្ធភាពតិចតួច ក្នុងការប្រើប្រាស់ប្រព័ន្ធយុត្តិធម៌ផ្លូវការ និងរងការខូចខាតដោយសារតែមរតកនៃការបង្ក្រាប និងការប្រកាន់ពូជសាសន៍កន្លងមក។ ទោះបីជនជាតិដើមភាគតិចមានត្រឹមប្រមាណ 5% នៃចំនួនប្រជាជនសរុបលើពិភពលោកក្តី ពួកគេស្ថិតក្នុងចំណោមជនក្រីក្រជាងគេ 15% លើពិភពលោក ដោយអ្នកទាំងនោះចំនួនមួយ ភាគបីរស់នៅក្នុងភាពក្រីក្រធ្ងន់ធ្ងរបំផុត។ នៅទូទាំងពិភពលោកប្រជាជនច្រើនជាង 46% ដែលមានអាយុ 60ឆ្នាំ និងច្រើនជាងនេះ រស់នៅជាមួយពិការភាពដែលប្រឈមនឹងការលំបាកធ្ងន់ធ្ងរ មិនអាចឱ្យពួកគេចូលរួមពេញលេញ នៅក្នុងសង្គម ហើយដែលស្ថានភាពនេះកាន់តែលំបាក ដោយសារតែឥរិយាបថរើសអើងក្នុងសង្គម។

## អំពើហិង្សាជាក្រុម និងជីវិតអសន្តិសុខ

ទំនាស់ និងអារម្មណ៍អំពីអសន្តិសុខផ្ទាល់ខ្លួន មានផលប៉ះពាល់អវិជ្ជមានជាប្រចាំមកលើការអភិវឌ្ឍមនុស្ស និងធ្វើឱ្យមនុស្សច្រើនពាន់លាននាក់ រស់នៅក្នុងលក្ខខណ្ឌមិនទៀងទាត់។ ប្រទេសជាច្រើននៅក្នុងស្រទាប់ខាងក្រោមសន្ទស្សន៍អភិវឌ្ឍន៍មនុស្សកំពុងងើបចេញពីទំនាស់ រ៉ាំរ៉ៃ ឬនៅតែប្រឈមមុខនៅឡើយ ចំពោះអំពើហិង្សាប្រដាប់អាវុធ។ មនុស្សច្រើនជាង 1,5ពាន់លាននាក់ រស់នៅក្នុងប្រទេស

ការឆ្លើយតបខាងគោលនយោបាយទៅនឹងភាពងាយរងគ្រោះ គួរតែទប់ស្កាត់ការគំរាមកំហែង លើកស្ទួយសមត្ថភាព និង ការពារប្រជាជន ជាពិសេស ក្រុមជនងាយរងគ្រោះបំផុត។

ប្រអប់ 1៖

## គោលការណ៍ និងគោលនយោបាយ

ផ្អែកតាមគំនិតនានាដែលទាក់ទងនឹងការអភិវឌ្ឍមនុស្ស និងការលើកកំពស់ឱកាសដូចគ្នាក្នុងការរស់នៅ យើងជម្រុញគោលការណ៍នាំមុខចំនួនបួនសម្រាប់ការបង្កើត និងអនុវត្តគោលនយោបាយនានា ដើម្បីកាត់បន្ថយភាពងាយរងគ្រោះ និងពង្រឹងភាពធន់។

### ការប្រកាន់យកគោលការណ៍សកលនិយម

បុគ្គលទាំងអស់មានគុណតម្លៃ និងសិទ្ធិដូចគ្នាក្នុងការទទួលបានកិច្ចការពារនិងការឧបត្ថម្ភគាំទ្រ។ ដូច្នេះ គេត្រូវតែទទួលស្គាល់កាន់តែច្រើនឡើងថា ពលរដ្ឋដែលប្រឈមហានិភ័យ និងការគំរាមកំហែង កុមារ ឬជនពិការ គួរទទួលបានការគាំទ្រ បន្ថែមដើម្បីធានាថា ឱកាសក្នុងជីវិតរបស់ពួកគេដូចគ្នានឹងឱកាសរបស់អ្នកដទៃដែរ។ ដូច្នេះ គោលការណ៍សកលនិយមអាចទាមទារឱ្យមានសិទ្ធិ និងការយកចិត្តទុកដាក់ដូចគ្នា។ ការគិតគូរឱ្យបានស្មើគ្នាសម្រាប់មនុស្សគ្រប់រូប អាចទាមទារឱ្យមានការយកចិត្តទុកដាក់ស្មើគ្នាដែលគាំទ្រដល់អ្នកទន់ខ្សោយ។[1]

### គិតគូរផលប្រយោជន៍របស់មនុស្សជាបឋម

ការកាត់បន្ថយភាពងាយរងគ្រោះ ទាមទារឱ្យមានការរម្លឹកឡើងវិញនូវសារគន្លឹះនៃការអភិវឌ្ឍមនុស្ស "គិតគូរប្រយោជន៍របស់មនុស្សជាបឋម" ពោលគឺសារមួយដែលត្រូវបានលើកស្ទួយជាប់ជាប្រចាំនៅក្នុងគ្រប់របាយការណ៍អភិវឌ្ឍន៍មនុស្ស តាំងពីរបាយការណ៍លើកទីមួយនៅឆ្នាំ 1990មកម្លេះ។ រាល់គោលនយោបាយសាធារណៈជាពិសេស គោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ត្រូវតែបានចាត់ទុកថា ជាមធ្យោបាយដើម្បីឈានទៅសម្រេចគោលដៅ តែមិនមែនជាគោលដៅផ្ទាល់នោះទេ។ អ្នកកសាងគោលនយោបាយត្រូវតែលើកសំណួរងាយៗមួយចំនួន។ តើកំណើនសេដ្ឋកិច្ចកំពុងកែលម្អការរស់នៅរបស់ប្រជាជនលើផ្នែកសំខាន់ៗសម្រាប់ពួកគេដែរឬទេ ដែលរាប់ចាប់ពីសុខភាព ការអប់រំ និងប្រាក់ចំណូល រហូតដល់សន្តិសុខជាមូលដ្ឋានសម្រាប់មនុស្ស និងសេរីភាពបុគ្គល? តើប្រជាជនមានអារម្មណ៍ថាកាន់តែងាយរងគ្រោះឬទេ? តើមានមនុស្សខ្លះត្រូវបានទុកចោលមិនទទួលផលដែរឬទេ? ប្រសិនបើមានករណីបែបនេះ តើពួកគេជាអ្នកណាខ្លះ ហើយថាតើអាចធ្វើបែបណាដើម្បីដោះស្រាយភាពងាយរងគ្រោះ និងវិសមភាពបែបនេះឱ្យបានល្អបំផុត?

### ការប្តេជ្ញាឱ្យមានចំណាត់ការរួមគ្នា

ការជំនះបាននូវការប្រឈមបច្ចុប្បន្ននេះ ទាមទារឱ្យមានចំណាត់ការរួមគ្នា។ នៅពេលប្រជាជនធ្វើសកម្មភាពរួមគ្នា ពួកគេពង្រឹងសមត្ថភាពនិងជម្រើសរបស់បុគ្គលរៀងៗខ្លួនរបស់ពួកគេ ដើម្បីជំនះការគំរាមកំហែងនានា ហើយភាពធន់រួមគ្នារបស់ពួកគេកាន់តែធ្វើឱ្យវឌ្ឍនភាពនៃការអភិវឌ្ឍមានលក្ខណៈស៊ីជម្រៅ និងធ្វើឱ្យការអភិវឌ្ឍនេះកាន់តែមាននិរន្តរភាព។ ករណីដូចគ្នានេះ ក៏អាចនិយាយបានផងដែរអំពីរដ្ឋនានា ដែលធ្វើសកម្មភាពរួមគ្នា ដើម្បីកាត់បន្ថយភាពងាយរងគ្រោះនៅចំពោះមុខការគំរាមកំហែងឆ្លងដែន ដោយបង្កើតផលប្រយោជន៍សាធារណៈពិភពលោក។ បើទោះជាមានភាពមិនប្រាកដប្រជាយ៉ាងច្រើននៅជុំវិញយើងក៏ដោយ ប្រការមួយដែលទំនងជាច្បាស់លាស់គឺ ចក្ខុវិស័យវិជ្ជមានមួយនៃកិច្ចការសាធារណៈ នឹងអាចសម្រេចបាន ឬ មិនបានអាស្រ័យជាចំបងលើជោគជ័យនៃការផ្តល់ផលប្រយោជន៍សាធារណៈទាំងនៅថ្នាក់ជាតិ និងពិភពលោក។

### ការសម្របសម្រួលរវាងរដ្ឋ និងស្ថាប័នសង្គម

បុគ្គលនានាមិនអាចចម្រើនតែឯងបានឡើយ។ ជាក់ស្តែង ពួកគេមិនអាចដំណើរការតែឯងបានឡើយ។ នៅពេលដែលពួកគេកើតឡើង គ្រួសារផ្តល់ការគាំទ្រសម្រាប់ការរស់នៅរបស់ពួកគេ។ ផ្ទុយទៅវិញ គ្រួសារនានាមិនអាចដំណើរការបានដោយឡែកដាច់ចេញពីសង្គមបានឡើយ។ គោលនយោបាយដើម្បីកែលម្អនិយាមសង្គមភាពជិតស្និទ្ធក្នុងសង្គម និងសមត្ថភាពសង្គមកាន់តែមានសារៈសំខាន់ ដែលអាចឱ្យរដ្ឋាភិបាល និងស្ថាប័នសង្គមធ្វើសកម្មភាពរួមគ្នា ដើម្បីកាត់បន្ថយភាពងាយរងគ្រោះ។ នៅពេលដែលទីផ្សារ និងប្រព័ន្ធនានាបង្កើតភាពងាយរងគ្រោះ រដ្ឋាភិបាល និងស្ថាប័នសង្គមត្រូវតម្រង់ទិសយន្តការទីផ្សារ ដើម្បីកំហិតភាពងាយរងគ្រោះ និងជួយប្រជាជន នៅក្នុងករណីដែលទីផ្សារមិនអាចធ្វើបែបនេះបាន។

1. Sen 1992.

ជនគ្រប់រូបគួរតែមានសិទ្ធិក្នុងការទទួលបានការអប់រំ ការថែទាំសុខភាព និងសេវាជាមូលដ្ឋានផ្សេងទៀត។ ការដាក់គោលការណ៍សកលនិយមនេះទៅក្នុងការអនុវត្តជាក់ស្តែង ទាមទារការយកចិត្តទុកដាក់ និងធនធានជាក់លាក់ ជាពិសេសសម្រាប់អ្នកក្រ និងក្រុមងាយរងគ្រោះ។

នានាដែលមានជម្លោះ ដែលមានប្រជាជនប្រមាណមួយភាគប្រាំនៃចំនួនប្រជាជន សរុបលើពិភពលោក។ អស្ថិរភាពនយោបាយក្នុងពេលថ្មីៗនេះ បានធ្វើឱ្យខូចខាតធ្ងន់ធ្ងរមកលើកត្តាមនុស្សពោលគឺ រហូតដល់ចុងឆ្នាំ 2012 មនុស្សប្រមាណ 45លាននាក់ ត្រូវបានជម្លៀសដោយបង្ខំបណ្តាលពីជម្លោះ ឬ ការធ្វើទុក្ខបុកម្នេញ ដែលជាអត្រាខ្ពស់បំផុតនៅក្នុងរយៈពេល 18ឆ្នាំ ដែលមានមនុស្សច្រើនជាង 15 លាននាក់ ក្លាយជាជនភៀសខ្លួន។ ក្នុងតំបន់ខ្លះៗនៅអាហ្វ្រិកខាងលិច និងអាហ្វ្រិកកណ្តាល ការមិនគោរពច្បាប់ និងជម្លោះប្រដាប់អាវុធ បន្តគំរាមកំហែងមកលើដំណើរឈានទៅមុខនៃការអភិវឌ្ឍមនុស្ស ដោយបង្កផលវិបាករយៈពេលវែងមកលើវឌ្ឍនភាពជាតិ។ ក្នុងប្រទេសមួយចំនួននៅអាមេរិកឡាទីន និងតំបន់ឈូងសមុទ្រការ៉ាអ៊ីប ទោះបីសមិទ្ធផលនៃការអភិវឌ្ឍមនុស្សមានខ្ពស់ ហើយក៏ដោយ ប្រជាជនយ៉ាងច្រើននៅតែមានអារម្មណ៍រងការគំរាមកំហែង ដោយសារអត្រាកើនឡើងនៃអំពើមនុស្សឃាត និងឧក្រិដ្ឋកម្មហិង្សាដទៃទៀតផងដែរ។

## ការកសាងភាពធន់

សុខុមាលភាពរបស់ប្រជាជន រងឥទ្ធិពលខ្លាំងពីសេរីភាពកាន់តែទូលំទូលាយក្នុងកន្លែង ដែលពួកគេរស់នៅ ហើយតាមរយៈសមត្ថភាពរបស់ខ្លួន ពួកគេអាចឆ្លើយតបទៅនឹងគ្រោះមហន្តរាយនានា និងងើបចេញពីស្ថានភាពទាំងនោះ មិនថាជាគ្រោះមហន្តរាយធម្មជាតិ ឬ គ្រោះមហន្តរាយបង្កដោយមនុស្សនោះទេ។ ភាពធន់គូសបញ្ជាក់អំពីវិធីនានា ក្នុងការធានាសុវត្ថិភាព និងទ្រទ្រង់និរន្តរភាពនៃការអភិវឌ្ឍមនុស្ស។ និយាយឱ្យចំ ភាពធន់គឺជាការធានាថា រដ្ឋសហគមន៍ និងស្ថាប័នពិភពលោក ធ្វើការដើម្បីពង្រឹងសិទ្ធិអំណាចប្រជាជន និង ការពារប្រជាជន។ ការអភិវឌ្ឍមនុស្សពាក់ព័ន្ធជាមួយការកំចាត់ចោលឧបសគ្គដែលរារាំងប្រជាជនពីការអនុវត្តសេរីភាពរបស់ពួកគេ។ វាជាការជួយឱ្យក្រុមមនុស្សទន់ខ្សោយ និងដែលសង្គមមើលរំលងអនុវត្តសិទ្ធិរបស់ខ្លួន សំដែង កង្វល់របស់ខ្លួនដោយចំហ ធ្វើឱ្យអ្នកដទៃឮ និងដើម្បីក្លាយជាភ្នាក់ងារជើសកម្មក្នុងការកំណត់ជោគវាសនារបស់ខ្លួន។ វាជាការមានសេរីភាពដើម្បីរស់

## រូបទី 7៖

**ប្រទេសមួយចំនួនបានចាប់ផ្តើមដាក់វិធានការនៃការធានារ៉ាប់រងសង្គម នៅពេលដែល GDP ក្នុងម្នាក់ៗនៃប្រទេសទាំងនោះធ្លាប់តែទាបជាងប្រទេសភាគច្រើននៅអាស៊ីខាងត្បូងក្នុងពេលបច្ចុប្បន្ននេះ**




ប្រភព៖ ការគណនាដែលផ្អែកតាម Maddison (2010).

នៅដែលមនុស្សគ្រប់គ្នាចង់បាន និងដើម្បីគ្រប់គ្រងកិច្ចការរបស់ខ្លួនឱ្យបានគ្រប់គ្រាន់។ របាយការណ៍នេះ គូសបញ្ជាក់អំពីគោលនយោបាយ គោលការណ៍ និងវិធានការគន្លឹះខ្លះៗ ដែលត្រូវមានជាចាំបាច់ដើម្បីបង្កើតភាពធន់ពោលគឺ ពង្រឹងជម្រើសពង្រីក ទីភ្នាក់ងារមនុស្ស (សមត្ថភាពរបស់មនុស្សក្នុងការជ្រើសរើស) និងលើកកំពស់សមត្ថភាពសង្គម។ របាយការណ៍នេះ បង្ហាញផងដែរថា ការសម្រេចបាន និងការរក្សាវឌ្ឍនភាពនៃការអភិវឌ្ឍមនុស្សអាចមានភាពខុសគ្នាអាស្រ័យលើប្រសិទ្ធភាពនៃការត្រៀមលក្ខណៈ និងការឆ្លើយតបនៅពេលរងការប៉ះទង្គិច។

## ការផ្តល់ជាសកលនូវសេវាសង្គមជាមូលដ្ឋាន

សកលនិយមមានន័យថា ការទទួលបាន និងឱកាសស្មើគ្នាសម្រាប់កសាងសមត្ថភាពស្នូល។ សម្រាប់ការផ្តល់ជាសកលនូវសេវាសង្គមជាមូលដ្ឋានដូចជា ការអប់រំ ការថែទាំសុខភាព ការផ្គត់ផ្គង់ទឹក និងអនាម័យ និងសុវត្ថិភាពសាធារណៈ ទាំងអស់នេះកើតមានទៅបានតែនៅក្នុងលក្ខខណ្ឌដែលមនុស្សទាំងអស់បានទទួលការពង្រឹងសិទ្ធិអំណាច ដើម្បីដឹកនាំជីវិតដែលពួកគេចង់បាន ហើយការទទួលបានជាតុផ្សំសំខាន់ៗសម្រាប់ការរស់នៅដោយថ្លៃថ្នូរ មិនគួរជាបន្ទុកដែលពួកគេត្រូវតែបង់ថ្លៃនោះទេ។ កម្រិតគ្របដណ្តប់ជាសកលនៃសេវាសង្គមសំខាន់ៗអាចធ្វើទៅបាននៅក្នុងដំណាក់កាលដើមដំបូងនៃការអភិវឌ្ឍ (រូបទី 7)។ បទពិសោធន៍ថ្មីមួយ ដូចជា នៅប្រទេសចិន វ៉ាន់ដា និងវៀតណាមបង្ហាញថា គេអាចសម្រេចបានយ៉ាងឆាប់រហ័សជាបង្គួរ (ក្នុងរយៈពេលខ្លីជាងមួយទសវត្សរ៍)។

ការផ្តល់ជាសកលនូវសេវាសង្គមជាមូលដ្ឋាន អាចបង្កើនសមត្ថភាពនិងកាត់បន្ថយភាពងាយរងគ្រោះជារចនាសម្ព័ន្ធ។ វាអាចជាកម្លាំងប្រកបដោយថាមពល សម្រាប់ធ្វើឱ្យមានឱកាសនិងលទ្ធផលស្មើគ្នា។ ឧទាហរណ៍ ការអប់រំសាធារណៈជាសកលប្រកបដោយគុណភាពខ្ពស់អាចកាត់បន្ថយគម្លាតនៃការអប់រំកុមាររវាងគ្រួសារអ្នកមាន និងគ្រួសារក្រីក្រ។ ការផ្ទេរសមត្ថភាពពីមនុស្ស មួយជំនាន់ទៅមួយជំនាន់ទៀត ដូចជា ការអប់រំនៅក្នុងគ្រួសារ អាចបន្តផ្តល់អត្ថប្រយោជន៍សម្រាប់រយៈពេលវែង។ គោលនយោបាយសកលក៏លើកកំពស់សាមគ្គីភាពក្នុងសង្គមផងដែរ តាមរយៈការបញ្ចៀស

កិច្ចគាំពារសង្គមរឹងមាំជាសកល មិនត្រឹមតែបង្កើនភាពធន់របស់បុគ្គលប៉ុណ្ណោះទេ វាក៏ជួយពង្រឹងភាពធន់នៃសេដ្ឋកិច្ចទាំងមូលផងដែរ។

រូបទី ៨៖

**ការចំណាយលើសុខភាព ការអប់រំ និងសុខុមាលភាព ដែលកើនឡើងជាបន្តបន្ទាប់ស្របនឹងការចម្រើនវ័យ មិនបណ្តុះ និងមិនគាំទ្រការអភិវឌ្ឍសមត្ថភាពនៅក្នុងដំណាក់កាលសំខាន់ៗពីដើមដំបូងឡើយ**




ប្រភព៖ Karoly and others 1997.

ការខូចប្រយោជន៍បណ្តាលពី ការផ្តោតតែលើភាពអាម៉ាស់ក្នុងសង្គមនៃអ្នកទទួលសេវា និងការផ្តល់ដែលមានលក្ខណៈដាច់ដាដុំនូវសេវាប្រកបដោយគុណភាព ក៏ដូចជាការខកខានមិនផ្តល់សេវាដល់ដៃមនុស្សជាច្រើនដែលងាយរងគ្រោះផងដែរ។

ការយល់ខុសជាទូទៅមួយគឺថា មានតែប្រទេសអ្នកមានប៉ុណ្ណោះដែលអាចបង់ថ្លៃសម្រាប់កិច្ចគាំពារសង្គម ឬការផ្តល់ជាសកលនូវសេវាសំខាន់ៗ។ ដូចដែលរបាយការណ៍នេះបានចងក្រងកន្លងមក ភស្តុតាងបង្ហាញផ្ទុយពីនេះ។ លើកលែងតែសង្គមដែលជួបប្រទះអំពើហិង្សា និងកោលាហល សង្គមភាគច្រើនអាចនិងបានដាក់ឱ្យអនុវត្តសេវាសំខាន់ៗនិងកិច្ចគាំពារសង្គមរួចហើយ។ សង្គមទាំងនោះបានរកឃើញថា ការវិនិយោគដំបូងត្រឹមមួយភាគចំណែកតូចនៃ GDP នាំមកនូវអត្ថប្រយោជន៍ដែលមានកម្រិតខ្ពស់ជាងការចំណាយពីដំបូងទៅទៀត។

## ការដោះស្រាយភាពងាយរងគ្រោះក្នុងវដ្តជីវិត

ប្រជាជនបានជួបបញ្ហាអសន្តិសុខក្នុងកម្រិតខុសៗគ្នា និងប្រភេទខុសគ្នានៃភាពងាយរងគ្រោះ នៅក្នុងដំណាក់កាលខុសគ្នានៃវដ្តជីវិត។ ចំណុចជួបប្រសព្វដែលមានលក្ខណៈផុយស្រួយបែបនេះ ជាអាទិ៍ វ័យកុមារ អន្តរកាលពីយុវវ័យទៅដំណាក់កាលដំបូងនៃមជ្ឈិមវ័យ និងពីមជ្ឈិមវ័យទៅបច្ឆិមវ័យ។ ថេរវេលាដែលត្រូវធ្វើអន្តរាគមន៍មានសារៈសំខាន់ណាស់ ដោយសារការខកខានមិនបានគាំទ្រដល់ការអភិវឌ្ឍសមត្ថភាពនៅក្នុងពេលសមស្រប នឹងត្រូវចំណាយខ្ពស់សម្រាប់ការកែតម្រូវនៅក្នុងដំណាក់កាលក្រោយនៃជីវិត។ ការអភិវឌ្ឍតាំងពីនៅក្នុងវ័យកុមារ ផ្តល់ជាឧទាហរណ៍ដ៏ល្អមួយអំពីវិធីដែលគោលការណ៍សកលនិយមជួយគាំទ្រដល់ការវិនិយោគនានា លើសមត្ថភាពមនុស្សនៅក្នុងជីវិតទាំងមូល។

ទោះជាយ៉ាងណាក៏ដោយ តាមធម្មតាគេមានធនធានត្រឹមតិចតួចប៉ុណ្ណោះ សម្រាប់ការអភិវឌ្ឍសមត្ថភាពតាំងពីវ័យកុមារ និងដើម្បីបង្កើនការចំណាយសង្គមក្នុងម្នាក់ៗនៅពេលដែលមនុស្សចម្រើនវ័យ។ ការចំណាយលើសុខភាព ការអប់រំ និងសុខុមាលភាព ដែលកើនស្របគ្នានឹងការចម្រើនវ័យ មិនបណ្តុះ និងមិនគាំទ្រការអភិវឌ្ឍសមត្ថភាពក្នុងបណ្តាឆ្នាំសំខាន់ៗពីដំបូងឡើយ (រូបទី ៨)។

## ការពង្រឹងកិច្ចគាំពារសង្គម

កិច្ចគាំពារសង្គម ដែលរួមទាំង ការធានារ៉ាប់រងសម្រាប់ភាពគ្មានការងារធ្វើ កម្មវិធីរបបសោធននិវត្តន៍ និងនិយ័តកម្មទីផ្សារពលកម្ម អាចផ្តល់កិច្ចការពារទល់នឹងហានិភ័យ និងភាពខ្វះខាតនានានៅទូទាំងអាយុកាលរបស់មនុស្ស និងជាពិសេស នៅក្នុងដំណាក់កាលផុយស្រួយ។ តាមរយៈការផ្តល់នូវការគាំទ្របន្ថែម និងដែលអាចព្យាករណ៍បានកម្មវិធីគាំពារសង្គមជួយគ្រួសារនានា ដើម្បីបញ្ចៀសការលក់ទ្រព្យសម្បត្តិ ការបញ្ឈប់កូនពីសាលារៀន ឬ ការពន្យាពេលនៃការថែទាំវេជ្ជសាស្ត្រចាំបាច់ ដែលទាំងអស់នេះ សុទ្ធតែជា

គ្រោះថ្នាក់ចំពោះសុខុមាលភាពរយៈពេលយូរអង្វែងរបស់ពួកគេ។ លើសពីនេះ គេក៏អាចប្រើប្រាស់បណ្តាញចែកចាយ និងយន្តការនានាសម្រាប់ចាត់ចែងកម្មវិធីគាំពារសង្គម ដើម្បីឆ្លើយតបនឹងករណីបន្ទាន់នានា នៅក្នុងរយៈពេលខ្លីចំពោះមុខផងដែរ និងការផ្តល់ជំនួយនៅក្នុងអំឡុងពេលមានវិបត្តិ ដូចជា គ្រោះមហន្តរាយធម្មជាតិ និងគ្រោះរាំងស្ងួត។

កិច្ចគាំពារសង្គមជាច្រើន មានឥទ្ធិពលវិជ្ជមានកើនឡើងជាបន្តបន្ទាប់។ ការធានារ៉ាប់រងសម្រាប់ភាពគ្មានការងារធ្វើ ជួយកែលម្អដំណើរការនៃទីផ្សារការងារ ដោយអនុញ្ញាតឱ្យអ្នកគ្មានការងារធ្វើ ជ្រើសយកមុខរបរដែលត្រូវគ្នាជាងមុន ធៀបនឹងជំនាញនិងបទពិសោធន៍របស់ពួកគេ ជាងការបង្ខំពួកគេឱ្យទទួលយកមុខរបរដែលមានពីដំបូង។ ការផ្តល់ប្រាក់ឧបត្ថម្ភដល់គ្រួសារនានា ត្រូវបានបង្ហាញថាជាការលើកទឹកចិត្តឱ្យមានការចូលរួមនៃទីផ្សារការងារ ដោយផ្តល់ធនធាន ដែលជួយប្រជាជនក្នុងការស្វែងរកឱកាសការងារប្រសើរជាងមុន ដែលរួមទាំងអនុញ្ញាតឱ្យសមាជិកគ្រួសារធ្វើចំណាកស្រុកដើម្បីស្វែងរកការងារផងដែរ។ អ្នកខ្លះជំទាស់ថាការគាំទ្របែបនេះ អាចកាត់បន្ថយការលើកទឹកចិត្តឱ្យស្វែងរកការងារទៅវិញ។ ករណីបែបនេះមួយចំនួនធំអាចកើតឡើងអាស្រ័យលើរចនាបថនៃគោលនយោបាយ។ ទោះជាយ៉ាងណាក៏ដោយ មានភស្តុតាងជាច្រើនដែលបង្ហាញថា និយ័តកម្មទីផ្សារការងារផ្តល់នូវតុល្យភាពវិជ្ជមាននៃអត្ថប្រយោជន៍ និងអាចកាត់បន្ថយវិសមភាព។

កិច្ចគាំពារសង្គម អាចធ្វើបាននៅក្នុងដំណាក់កាលដើមដំបូងនៃការអភិវឌ្ឍ និងថែមទាំងអាចនាំមកនូវអត្ថប្រយោជន៍ដទៃទៀតផងដែរ ដូចជា សម្រួលដល់ការចំណាយ និងកាត់បន្ថយភាពក្រីក្រផងដែរ។ កិច្ចគាំពារសង្គមអាចទប់ទល់នឹងភាពងាយប្រែប្រួលនៃលទ្ធផល ដោយកាត់បន្ថយភាពប្រែប្រួលនៃប្រាក់ចំណូលដែលអាចប្រើប្រាស់បាន។ គោលនយោបាយរឹងមាំ នៃការគាំពារសង្គមជាសកល មិនត្រឹមតែកែលម្អភាពធន់ប៉ុណ្ណោះទេ ប៉ុន្តែក៏ពង្រឹងភាពធន់នៃសេដ្ឋកិច្ចទាំងមូលផងដែរ។

## លើកកំពស់ភាពមានការងារធ្វើពេញលេញ

គោលបំណងនៃភាព មានការងារធ្វើពេញលេញ មានសារៈសំខាន់ជាស្នូលនៃគោលនយោបាយ ម៉ាក្រូសេដ្ឋកិច្ចនៅក្នុងទសវត្សរ៍ឆ្នាំ 1950 និង 1960។ គោលនយោបាយនេះបានបាត់ពីក្នុងរបៀបវារៈពិភពលោកនៅក្នុងសម័យកាលនៃការធ្វើឱ្យមានស្ថិរភាព ដែលបន្តដោយវិបត្តិក្នុងវិស័យប្រេងនៅក្នុងឆ្នាំ 1973 និង 1979។ ឥឡូវនេះដល់ពេល ដែលត្រូវវិលទៅរកការប្តេជ្ញាបែបនោះ ដើម្បីឱ្យវឌ្ឍនភាព រឹងប៉ឹង និងងាយស្រួលក្នុងការរក្សានិរន្តរភាព។ ភាពមានការងារធ្វើពេញលេញ មិនត្រឹមតែពង្រីកគោលការណ៍សកលនិយមនៃយន្តការទីផ្សារប៉ុណ្ណោះទេ វាថែមទាំងជួយទ្រទ្រង់ដល់ការផ្តល់សេវាសង្គមផងដែរ។ ជាក់ស្តែងភាពមានការងារធ្វើពេញលេញ មានសារៈសំខាន់ណាស់ក្នុងការទ្រទ្រង់និរន្តរភាពក្នុងបណ្តាប្រទេសនៅស្កង់ឌីណាវ ដោយសារភាពមានការងារធ្វើកម្រិតខ្ពស់ បានជួយធានាបង្កើនផលចំណូលគ្រប់គ្រាន់ពីពន្ធសម្រាប់ផ្តល់ការគាំទ្រដល់ការផ្តល់សេវាជាសកល។

ភាពមានការងារធ្វើពេញលេញ ក៏ជាវត្ថុបំណងសម្រាប់ផលប្រយោជន៍សង្គមផងដែរ។ ភាពគ្មានការងារធ្វើទាក់ទងនឹងការខាតបង់ខាងសេដ្ឋកិច្ច និងសង្គមដែលនាំឱ្យបាត់បង់លទ្ធផលជារៀងរហូត និងការថយចុះជំនាញ និងផលិតភាពការងារ។ ការបាត់បង់ផលិតផល និងផលចំណូលខាងផ្នែកពន្ធដែលពាក់ព័ន្ធនឹងផលិតផលទាំងនោះ អាចទាមទារឱ្យមានការចំណាយខ្ពស់ជាងមុខលើវិស័យសាធារណៈ ដើម្បីទ្រទ្រង់ដល់ការធានារ៉ាប់រងភាពគ្មានការងារធ្វើ។ ភាពគ្មានការងារធ្វើរយៈពេលវែង គឺជាការគំរាមកំហែងធ្ងន់ធ្ងរចំពោះសុខភាព (រាងកាយនិងស្មារតី) និងចំពោះគុណភាពនៃការរស់នៅ (ដែលរួមទាំងការអប់រំកុមារផងដែរ)។ ភាពគ្មានការងារធ្វើ ទំនងជាមានការពាក់ព័ន្ធជាមួយកំណើនឧក្រិដ្ឋកម្ម អត្តឃាដ អំពើហិង្សា ការសេពគ្រឿងញៀន និងបញ្ហាសង្គមដទៃទៀតផងដែរ។ ដូច្នេះ អត្ថប្រយោជន៍សង្គមនៃមុខរបរមានច្រើនខ្លាំងណាស់ធៀបនឹងអត្ថប្រយោជន៍ឯកជន ពោលគឺ ប្រាក់ឈ្នួល។

ការងារ ពង្រឹងស្ថិរភាពសង្គម និងសម្ព័ន្ធភាពក្នុងសង្គម ហើយការងារសមរម្យ ពង្រឹងសមត្ថភាពរបស់ប្រជាជនក្នុងការគ្រប់គ្រងការប៉ះទង្គិច និងភាពមិនប្រាកដប្រជា។ ការងារដែលមានន័យថា របរចិញ្ចឹមជីវិត គឺជាការពង្រឹងទីភ្នាក់ងារមនុស្ស និងមានគុណភាពតម្លៃកាន់តែធំសម្រាប់គ្រួសារ និងសហគមន៍។ សន្តិសុខការងារ មានគុណតម្លៃខ្ពស់ខាងស្មារតីផងដែរ។

ដូច្នេះ គោលនយោបាយនានាដែលគាំទ្រឱ្យមានកំណែទម្រង់ជារចនាសម្ព័ន្ធ ដែលបង្កើនការងារក្នុងវិស័យផ្លូវការ និងធ្វើនិយ័តកម្មលក្ខខណ្ឌការងារ គឺជាតម្រូវការចាំបាច់ដើម្បីកាត់បន្ថយភាពងាយរងគ្រោះនៃភាពមានការងារធ្វើនៅក្នុងរយៈពេលមធ្យម និងរយៈពេលយូរអង្វែង ប៉ុន្តែគោលនយោបាយទាំងនោះ នៅពុំទាន់គ្រប់គ្រាន់ដើម្បីដោះស្រាយភាពងាយរងគ្រោះនៅឡើយទេសម្រាប់ពលករភាគច្រើន នៅក្នុងរយៈពេលខ្លី។ ដូច្នេះ គោលនយោបាយក៏មានសារៈសំខាន់ជាសារវន្ត សម្រាប់ដោះស្រាយភាពងាយរងគ្រោះផងដែរ និងសម្រាប់ធានាសន្តិសុខរបរចិញ្ចឹមជីវិតនៃពលករជាច្រើន ដែលនឹងនៅតែស្ថិតក្នុងវិស័យនៃសកម្មភាពតាមប្រពៃណី និងក្នុងវិស័យមិនរៀបរយនៅក្នុងរយៈពេលខ្លី។ ការលើកទឹកចិត្តឱ្យមានការកែប្រែបែបនេះ និងការបង្កើតការងាដែលផ្តល់ផលទូលំទូលាយ ទាមទារឱ្យមានយុទ្ធសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ច ដែលមានប្រសិទ្ធភាពខ្ពស់ជាងមុន ដែលរួមទាំងការវិនិយោគសាធារណៈកាន់តែច្រើនលើហេដ្ឋារចនាសម្ព័ន្ធ ការអភិវឌ្ឍសមត្ថភាពមនុស្ស ការលើកកំពស់យ៉ាងសកម្មឱ្យមានការបង្កើតថ្មី និងគោលនយោបាយយុទ្ធសាស្ត្រសម្រាប់ពាណិជ្ជកម្ម ជាពិសេសសម្រាប់ការនាំចេញ។

ភាពមានការងារធ្វើពេញលេញ គួរតែជាគោលដៅមួយនៃគោលនយោបាយសម្រាប់សង្គមនៅគ្រប់លំដាប់ថ្នាក់នៃការអភិវឌ្ឍ។

## ស្ថាប័នមានភាពឆ្លើយតប សង្គមមានសិនិទ្ធភាព

ការកសាងភាពធន់នៃមនុស្ស ទាមទារឱ្យមានស្ថាប័នដែលមានលក្ខណៈឆ្លើយតប។ គោលនយោបាយ និងធនធានគ្រប់គ្រាន់ គឺជាតម្រូវការចាំបាច់ដើម្បីផ្ដល់ការងារគ្រប់គ្រាន់ ការថែទាំសុខភាព និងឱកាសដើម្បីសិក្សា ជាពិសេសសម្រាប់ជនក្រីក្រ និងងាយរងគ្រោះ។ ជាពិសេស រដ្ឋនានាដែលទទួលស្គាល់ និងចាត់វិធានការដើម្បីកាត់បន្ថយវិសមភាពក្នុងចំណោមក្រុមនានា (ដែលហៅថា វិសមភាពរវាងក្រុម) មានលទ្ធភាពច្រើនក្នុងការលើកស្ទួយគោលការណ៍សកលនិយម កសាងភាពចុះសម្រុងក្នុងសង្គម និងទប់ស្កាត់វិបត្តិ ព្រមទាំងងើបចេញពីស្ថានភាពវិបត្តិផងដែរ។

ភាពងាយរងគ្រោះជាប្រចាំ មានឫសគល់នៅក្នុងការមើលរំលងពីសំណាក់សង្គមអស់ពេលជាយូរកន្លងមក ពោលគឺស្ត្រីនៅក្នុងសង្គមបិតាធិបតេយ្យ ដែលជនជាតិស្បែកខ្មៅនៅអាហ្វ្រិកខាងត្បូង និងនៅសហរដ្ឋអាមេរិក និងនៅដាលីតក្នុងប្រទេសឥណ្ឌា ជួបប្រឈមការរើសអើង និងការមិនរាប់រក ដោយសារតែប្រពៃណី និងនិយាមសង្គមយូរអង្វែង។ ស្ថាប័នអភិបាលកិច្ចដែលឆ្លើយតប និងមានគណនេយ្យភាព មានសារៈសំខាន់ណាស់ ក្នុងការជំនះស្ថានភាពអយុត្តិធម៌ ភាពងាយរងគ្រោះ និងការសង្គមមើលរំលងបែបនេះ ដែលអាចពង្រឹងភាពទោមនស្សក្នុងសង្គម។ ការចូលរួមក្នុងការងារស៊ីវិល និងការកៀងគរកម្លាំងសរុបរួមគ្នា ក៏មានសារៈសំខាន់មិនអាចខ្វះបានផងដែរ ក្នុងការធានាថា រដ្ឋទទួលស្គាល់ផលប្រយោជន៍ និងសិទ្ធិរបស់ជនងាយរងគ្រោះ។

> ឥទ្ធិពលនៃវិបត្តិ នៅពេលកើតឡើង អាចកាត់បន្ថយបាន តាមរយៈការត្រៀមលក្ខណៈ និងកិច្ចប្រឹងប្រែងស្តារឡើងវិញ ដែលអាចធ្វើឱ្យសង្គមមានភាពធន់ជាងមុន។

រដ្ឋអាចធ្វើអន្តរាគមន៍ ដើម្បីកាត់បន្ថយវិសមភាពក្នុងក្រុម តាមរយៈអន្តរាគមន៍គោលនយោបាយចម្រុះ។ អន្តរាគមន៍ផ្ទាល់ ដូចជា ចំណាត់ការជាវិជ្ជមានអាចផ្ដល់ផលភ្លាមៗ សម្រាប់ដោះស្រាយអយុត្តិធម៌ជាប្រវត្តិសាស្ត្រ ប៉ុន្តែគេនៅពុំទាន់ដឹងច្បាស់អំពីឥទ្ធិពលរយៈពេលវែងរបស់វា នៅឡើយទេ។ ចំណាត់ការជាវិជ្ជមានមិនសុទ្ធតែអាចកែតម្រូវឫសគល់ជាលក្ខណៈប្រព័ន្ធដែលជាមូលហេតុនៃវិសមភាពជាប់ជាប្រចាំឡើយ។ គេត្រូវការជាចាំបាច់នូវគោលនយោបាយដែលឆ្លើយតបនៅក្នុងរយៈពេលខ្លី និងលើកកំពស់លទ្ធភាពសម្រាប់រយៈពេលវែង និងដែលមាននិរន្តរភាពសម្រាប់ការទទួលបានសេវាសង្គម ការងារ និងកិច្ចគាំពារសង្គមសម្រាប់ក្រុមងាយរងគ្រោះ។ អន្តរាគមន៍ទាំងនោះអាចរាប់បញ្ចូល ការលើកទឹកចិត្ត និងទណ្ឌកម្មជាផ្លូវការ ដូចជា ច្បាប់ដើម្បីទប់ស្កាត់។ ឧទាហរណ៍ ច្បាប់ដែលផ្អែកលើសិទ្ធិ អាចធ្វើឱ្យមានការកែលម្អយ៉ាងច្រើនសម្រាប់ក្រុមមនុស្សដែលងាយរងគ្រោះ ដែលជាអ្នកទទួលសិទ្ធិអំណាចតាមរយៈសិទ្ធិស្របច្បាប់ក្នុងការដាក់បណ្ដឹងសារទុក្ខ និងការដេញដោលជាសាធារណៈ នៅពេលដែលស្ថាប័ននានាខកខានមិនជួយពួកគេ។

ការកែប្រែនិយាមនានាដើម្បីកសាងភាពអត់ធ្មត់ និងបង្កើនសិនិទ្ធភាពក្នុងសង្គម (ឬភាពចុះសម្រុងគ្នាក្នុងសង្គម) ក៏ជាប្រការចាំបាច់ផងដែរ ហើយជាញឹកញាប់ វាជាប្រការដែលត្រូវគេមើលរម្លងនៅក្នុងការកសាងសង្គម ដែលមានភាពធន់។ សង្គមដែលកាន់តែមានសិនិទ្ធភាពផ្ដល់នូវភាពខ្លាំងដែលអាចការពារ ប្រជាជនពីទុរគត និងអាចទទួលយកបានច្រើននូវគោលនយោបាយនានា ដែលផ្អែកលើគោលការណ៍ សកលនិយម។ កង្វះសិនិទ្ធភាពក្នុងសង្គមមានទំនាក់ទំនងជាមួយទំនាស់ និង អំពើហិង្សាជាពិសេសនៅក្នុងស្ថានភាពនៃការទទួលបានធនធាន ឬផលប្រយោជន៍មិនស្មើគ្នាពីធនធានធម្មជាតិ និងក្នុងពេលដែលគ្មានសមត្ថភាពក្នុងការដោះស្រាយយ៉ាងមានប្រសិទ្ធភាព នូវការប្រែប្រួលសង្គម និងសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស ឬផលប៉ះពាល់បណ្ដាលពីការប៉ះទង្គិចខាងសេដ្ឋកិច្ច ឬដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ។ ជាក់ស្ដែង ការឈានទៅសម្រេចគោលដៅទូលំទូលាយនៃសមធម៌ ការរួមបញ្ចូល និងយុត្តិធម៌ គឺជាការពង្រឹងស្ថាប័នសង្គម និងជួយពង្រឹងសិនិទ្ធភាពជាបន្តនៅក្នុងសង្គម។

## កសាងសមត្ថភាពដើម្បីត្រៀមលក្ខណៈសម្រាប់វិបត្តិ និងការងើបចេញពីស្ថានភាពវិបត្តិ

គ្រោះមហន្តរាយធម្មជាតិ បង្កឱ្យភាពងាយរងគ្រោះកាន់តែធ្ងន់ធ្ងរ ដូចជា ភាពក្រីក្រ វិសមភាព ការរេចរឹលបរិស្ថាន និងភាពទន់ខ្សោយខាងអភិបាលកិច្ច។ ប្រទេស និងសហគមន៍នានាដែលមិនបានត្រៀមលក្ខណៈ ដែលមិនបានដឹងអំពីហានិភ័យ និងដែលមានសមត្ថភាពត្រឹមតិចតួចសម្រាប់ទប់ស្កាត់ នឹងរងការប៉ះពាល់ជាខ្លាំងបណ្ដាលពីគ្រោះមហន្តរាយធ្ងន់ធ្ងរ។ គេត្រូវការឱ្យមានកិច្ចប្រឹងប្រែងច្រើនថែមទៀតដើម្បីពង្រឹងប្រព័ន្ធជូនដំណឹងជាមុននៅថ្នាក់ជាតិ និងតំបន់។ កិច្ចសហប្រតិបត្តិការថ្នាក់តំបន់លើការជូន ដំណឹងជាមុន អាចមានប្រសិទ្ធភាពខ្ពស់ ដោយសារគ្រោះមហន្តរាយធម្មជាតិច្រើន តែបង្កការប៉ះពាល់លើប្រទេសជាច្រើនក្នុងពេលជាមួយគ្នា។ ការជូនដំណឹងជាមុន គឺជាធាតុសំខាន់មួយក្នុងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ។ វាជួយសង្គ្រោះអាយុជីវិត និងកាត់បន្ថយការបាត់បង់ខាងសេដ្ឋកិច្ច និងសម្ភារៈបណ្ដាលពីគ្រោះមហន្តរាយ។

ទោះបីប្រទេសណាមួយបានត្រៀមខ្លួនកម្រិតណាក៏ដោយ ហើយទោះបីក្របខ័ណ្ឌគោលនយោបាយរបស់ប្រទេសនោះបានល្អកម្រិតណាក៏ដោយ ការប៉ះទង្គិចនឹងនៅតែកើតឡើងដែលជាញឹកញាប់បង្កផលវិបាក ដែលមិនអាចជៀសវាងបាន និងរងការខូចខាតកម្រិតខ្ពស់។ ដូច្នេះ គោលបំណងគន្លឹះគឺស្ថាបនាឡើងវិញ ទន្ទឹមនឹងបង្កើនភាពធន់ខាងសង្គម សម្ភារៈ និងស្ថាប័ន។ ការឆ្លើយតបនានាទៅនឹងព្រឹត្តិការណ៍ធាតុអាកាសមិនប្រក្រតី កាន់តែមានលក្ខណៈស្មុគស្មាញ ដោយសារភាពទន់ខ្សោយខាងស្ថាប័ន និងទំនាស់។ ភាពធន់របស់ប្រទេសណាមួយមានជាអាទិ៍ សមត្ថភាពរបស់ប្រទេសនោះក្នុងការងើបចេញបានឆាប់រហ័ស និងដោយងាយស្រួលពីគ្រោះមហន្តរាយនានា។ ប្រការនេះពាក់ព័ន្ធជាមួយការគ្រប់គ្រងឥទ្ធិពលចំពោះមុខនៃគ្រោះមហន្តរាយនានា ក៏ដូចជា ការអនុវត្តវិធានការជាក់លាក់ដើម្បីបញ្ចៀស

ប្រអប់ 2៖

## របៀបវារៈសំខាន់ៗចំនួនបួនស្តីពីអភិបាលកិច្ចពិភពលោក

### ក្របខ័ណ្ឌសកម្មភាព Hyogo

ក្របខ័ណ្ឌសកម្មភាព Hyogo ដែលអនុម័តដោយប្រទេសចំនួន 168 នៅឆ្នាំ 2005 មានគោលដៅកាត់បន្ថយហានិភ័យគ្រោះមហន្តរាយពិភពលោកហូតដល់ឆ្នាំ 2015។[1] ក្របខ័ណ្ឌនេះចែងអំពីកិច្ចការ និងសកម្មភាពមួយចំនួនដែលផ្តោតលើការកសាងសមត្ថភាព របស់ស្ថាប័ននៅមូលដ្ឋាន និងថ្នាក់ជាតិ ដែលគាំទ្រដល់ប្រព័ន្ធជូនដំណឹងជាមុន គាំទ្រដល់វប្បធម៌សុវត្ថិភាពនិងភាពធន់ ការកាត់បន្ថយបុព្វហេតុនៃភាពងាយរងគ្រោះ និងពង្រឹងការត្រៀមលក្ខណៈនិងការឆ្លើយតបនឹងគ្រោះមហន្តរាយ។

ក្របខ័ណ្ឌនេះផ្តោតលើសកម្មភាពរួមគ្នា ឆ្ពោះទៅកាត់បន្ថយហានិភ័យគ្រោះមហន្តរាយនៅក្នុងរបៀបវារៈថ្នាក់ជាតិ តំបន់និងអន្តរជាតិ។ ប៉ុន្តែ មានកិច្ចការច្រើនទៀតដែលត្រូវសម្រេចឱ្យបាន ហើយវឌ្ឍនភាពនៅពុំទាន់មានឯកភាពគ្នានៅឡើយទេក្នុងប្រទេសនានា ឬវិស័យនានានៃសកម្មភាព។ ប្រការដែលនៅជាការប្រឈមនៅឡើយ មានជាអាទិ៍ ការបង្កើត និងប្រើប្រាស់សូចនាករ និងការបង្កើតប្រព័ន្ធជូនដំណឹងជាមុននៅក្នុងបរិស្ថានដែលមានមុខសញ្ញាមហន្តរាយច្រើន និងការពង្រឹងសមត្ថភាពរបស់រដ្ឋ ដើម្បីរួមបញ្ចូលការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយទៅក្នុងគោលនយោបាយ និងការកសាងផែនការអភិវឌ្ឍន៍ដោយចីរភាពនៅថ្នាក់ជាតិ និងអន្តរជាតិ។

### កិច្ចប្រជុំកំពូលមនុស្សធម៌ពិភពលោក

កិច្ចប្រជុំកំពូលមនុស្សធម៌ពិភពលោកដែលគ្រោងធ្វើនៅឆ្នាំ 2016 មានគោលដៅធ្វើឱ្យចំណាត់ការខាងមនុស្សធម៌កាន់តែមានច្រើន នៅកម្រិតពិភពលោក ប្រសិទ្ធភាព និងសម្រាប់ទាំងអស់គ្នា និងកាន់តែមានលក្ខណៈជាតំណាងឱ្យតម្រូវការនៃពិភពលោកដែលប្រែប្រួលឆាប់រហ័ស។[2] វានឹងក្លាយជាឱកាសដើម្បីសម្របសម្រួលអង្គការជំនួយមនុស្សធម៌អន្តរជាតិនៅជុំវិញបញ្ហាកាត់បន្ថយភាពងាយរងគ្រោះ និងការគ្រប់គ្រងហានិភ័យ។

ការឆ្លើយតបនឹងចំនួនកាន់តែច្រើននៃភាពបន្ទាន់កាន់តែស្មុគស្មាញ ខាងផ្នែកមនុស្សធម៌ នឹងចាប់ផ្តើមដោយកំណត់អត្តសញ្ញាណ និងអនុវត្តវិធីសាស្ត្រដើម្បីកាត់បន្ថយ និងគ្រប់គ្រងហានិភ័យខាងមនុស្សធម៌។ កិច្ចប្រជុំកំពូលនេះនឹងក្លាយជាឱកាសដើម្បីវាយតម្លៃអំពីថាតើភ្នាក់ងារជំនួយមនុស្សធម៌ និងភ្នាក់ងារអភិវឌ្ឍន៍អាចប្រើប្រាស់វិធីសាស្ត្រដែលកាន់តែមានលក្ខណៈប្រព័ន្ធ ស៊ីសង្វាក់គ្នាបែបណានៅក្នុងការកសាងផែនការ ការចាត់ជាអាទិភាព និងការផ្តល់មូលនិធិសម្រាប់កម្មវិធីនានា និងតើសកម្មភាពអាចនឹងត្រូវសម្របសម្រួលបែបណានៅទូទាំងកិច្ចការសេដ្ឋកិច្ច សង្គម និងបរិស្ថាន។ កិច្ចប្រជុំនេះនឹងលើកទឹកចិត្តឱ្យមានកិច្ចសហការក្នុងចំណោមប្រទេសដែលងាយរងគ្រោះ ម្ចាស់ជំនួយ និងអង្គការអន្តរជាតិ ដើម្បីបង្កើតរួមគ្នានូវយុទ្ធសាស្ត្រជំនួយមនុស្សធម៌ និងអភិវឌ្ឍន៍។

### ការប្រែប្រួលអាកាសធាតុ – កំហិតត្រឹម 2 អង្សា

នៅក្នុងកិច្ចព្រមព្រៀង (Accord) កូប៉េនហាក់ឆ្នាំ 2009 និងកិច្ចព្រមព្រៀងកាន់គុនឆ្នាំ 2010 ភាគីចំនួន 195 ក្នុងអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ បានឯកភាពកំហិតកំណើនជាមធ្យមនៃសីតុណ្ហភាពពិភពលោកត្រឹមតិចជាង 2 អង្សាសេ ធៀបនឹងកម្រិតនៅមុនសម័យឧស្សាហកម្ម។[3] ការប្តេជ្ញានេះបានផ្អែកលើការឯកភាពមតិជាទូទៅខាងវិទ្យាសាស្ត្រថា កំណើន 2 អង្សាជាកម្រិតអតិបរមាដែលពិភពលោកអាចធ្វើទៅបាន ដើម្បីកំហិតផលប៉ះពាល់ប្រកបដោយគ្រោះថ្នាក់ដែលអាចបង្កការរំខាន។

ការសន្យា និងការប្តេជ្ញារបស់សហគមន៍អន្តរជាតិ នៅពុំទាន់គ្រប់គ្រាន់ដើម្បីសម្រេចគោលដៅនេះនៅឡើយទេ។ ការព្យាករណ៍របស់ក្រុមការងារអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុបានសន្និដ្ឋានថា សីតុណ្ហភាពពិភពលោកទំនងជានឹងកើនឡើង 1,5 អង្សា ហូតដល់ចុងសតវត្សរ៍ទី 21 និងអាចកើនឡើង 2 អង្សារសេយ៉ាងងាយ ប្រសិនបើគ្មានចំណាត់ការចំបងៗដើម្បីកាត់បន្ថយការបំភាយទេនោះ។[4] ការសម្រេចគោលបំណងនេះនៅតែអាចធ្វើបាន ទៅតាមគោលការណ៍បច្ចេកទេសនិងសេដ្ឋកិច្ច ប៉ុន្តែគេនៅត្រូវការមហិច្ឆតាខាងនយោបាយ ដើម្បីបំពេញគម្លាតរវាងការបំភាយបច្ចុប្បន្ន ដែលនឹងកំណត់ថាពិភពលោកស្ថិតក្នុងលំនាំនៃការបំភាយទាបជាង 2 អង្សារហូតដល់ឆ្នាំ 2020។

### របៀបវារៈក្រោយឆ្នាំ 2015 និងគោលដៅអភិវឌ្ឍន៍ដោយចីរភាព

នៅក្នុងដំណាក់កាលឈានទៅរបៀបវារៈសម្រាប់ក្រោយឆ្នាំ2015 សហគមន៍អន្តរជាតិមានឱកាសមិនស្របគ្នា ក្នុងការធ្វើឱ្យការកាត់បន្ថយភាពងាយរងគ្រោះក្លាយជាអាទិភាពមួយនៅក្នុងក្របខ័ណ្ឌអភិវឌ្ឍន៍អន្តរជាតិ។ គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍បានជួយកាត់បន្ថយភាពក្រីក្រ និងកែលម្អការរស់នៅរបស់មនុស្សជាច្រើន។ ប៉ុន្តែ ការបន្តវឌ្ឍនភាពមិនអាចធានាបានទេ លើកលែងតែអាចកាត់បន្ថយការប៉ះទង្គិច ហើយសមត្ថភាពរបស់ប្រជាជនសម្រាប់ការទប់ទល់ ត្រូវបានកែលម្អ។ ស្របគ្នានេះ ការអំពាវនាវដើម្បីឈានដល់ភាពក្រីក្រសូន្យភាគរយ គួរតែពង្រីកជាបន្ថែមដើម្បីរក្សាភាពក្រីក្រសូន្យឱ្យនៅកម្រិត ហើយត្រូវរក្សាវឌ្ឍនភាពនៅក្នុងវិស័យផ្សេងទៀត។ អ្នកដែលងាយរងគ្រោះបំផុតចំពោះមុខ គ្រោះមហន្តរាយធម្មជាតិ ការប្រែប្រួលអាកាសធាតុ និងដំណើរធាក់ថយខាងហិរញ្ញវត្ថុ ត្រូវតែទទួលបានសិទ្ធិអំណាច និងកិច្ចការពារជាពិសេស។ ការធ្វើឱ្យការកាត់បន្ថយភាពងាយរងគ្រោះក្លាយជាស្នូលនៃរបៀបវារៈអភិវឌ្ឍន៍ទៅអនាគត គឺជាវិធីតែមួយគត់ ដើម្បីធានាវឌ្ឍនភាពដែលមានភាពធន់ និងមាននិរន្តរភាព។

1. UNISDR 2005. 2. UNOCHA 2014. 3. UNFCCC 2009, 2011. 4. IPCC 2013.

ផលវិបាកបន្ថែមទៀតខាងសេដ្ឋកិច្ចសង្គមផងដែរ។ សង្គមដែលមិនបានត្រៀមខ្លួនសម្រាប់គ្រប់គ្រងការប៉ះទង្គិច ច្រើនតែជួបប្រទះការខូចខាត និងការបាត់បង់ដែលមានទំហំធំផង និងរយៈពេលវែង។

ទោះបីកិច្ចប្រឹងប្រែងដើម្បីបង្កើតភាព ចុះសម្រុងគ្នាក្នុងសង្គមមានលក្ខណៈខុសគ្នា ដែលអាស្រ័យតាមបរិបទ និងកាលៈទេសៈជាតិក៏ដោយ គេនៅតែអាចកំណត់បាននូវធាតុរួមខ្លះៗ។ គោលនយោបាយ និងស្ថាប័ន ដែលប្រយុទ្ធប្រឆាំងការមិនរាប់រក និងការធ្វើឱ្យទន់ខ្សោយ ដែលបង្កើតជាស្មារតីនៃភាពម្ចាស់ការ ដែលលើកកំពស់ទំនុកចិត្ត និងដែលផ្តល់ឱកាសសម្រាប់ការឈានឡើង អាចកាត់បន្ថយលទ្ធភាពនៃការកើតមានទំនាស់។ ការបង្កើននូវការយល់ដឹងជាសាធារណៈ និងការទទួលបានព័ត៌មាន អាចបង្កើតឱ្យមានការគាំទ្រជាសាធារណៈដើម្បីសន្តិភាព និងនយោបាយដែលមិនសូវមានវិវាទ។ ការចូលរួមរបស់អន្តរការី និងអ្នកផ្សះផ្សារដែលគួរជឿបាន អាចបង្កើតទំនុកចិត្ត និងការជឿទុកចិត្តក្នុងចំណោមក្រុមដែលមានទំនាស់ និងដែលមានជំហរផ្ទុយគ្នា និងការឯកភាពមតិលើបញ្ហាដែលមានសារៈសំខាន់សម្រាប់ជាតិ ដែលរាប់ចាប់ពីការចាត់ចែងបោះឆ្នោត រហូតដល់ធាតុសំខាន់ៗនៃរដ្ឋធម្មនុញ្ញថ្មី។ ការវិនិយោគលើការងារ និងរបរចិញ្ចឹមជីវិតអាចជួយសហគមន៍ និងបុគ្គលនានា ឱ្យងើបចេញពីវិបត្តិនៅក្នុងរយៈពេលខ្លី និងបង្កើនភាពធន់នៅចំពោះមុខការប្រឈមនានា នៃវិបត្តិទៅអនាគត។

## ពង្រីកការគិតគូររបស់យើងអំពីភាពងាយរងគ្រោះ

អង្គការសហប្រជាជាតិបានសង្កត់ធ្ងន់អំពីសន្តិសុខមនុស្ស នៅក្នុងគ្រប់ទិដ្ឋភាពទាំងអស់។ កាលពីខ្ញុំនៅជាប្រធានផ្នែកសេដ្ឋកិច្ចនៃធនាគារពិភពលោក យើងបានអង្កេតប្រជាជនក្រីក្រជាច្រើនពាន់នាក់នៅទូទាំងពិភពលោក ដើម្បីបញ្ជាក់អំពីអ្វីដែលជាកង្វល់ខ្លាំងជាងគេបំផុតសម្រាប់អ្នកទាំងនោះ ហើយនៅភាគខាងលើនៃតារាងលទ្ធផល (ទន្ទឹមនឹងកង្វះជាក់ស្តែងនានាអំពីកង្វះប្រាក់ចំណូល និងភាពមិនគ្រប់គ្រាន់ ខាងសម្លេងនៅក្នុងកិច្ចការដែលមានឥទ្ធិពលលើការរស់នៅរបស់ពួកគាត់) គឺអសន្តិសុខ - ភាពងាយរងគ្រោះ។

នៅកម្រិតនេះ ភាពងាយរងគ្រោះត្រូវបានឱ្យនិយមន័យថាជា ការស្ថិតក្រោមឥទ្ធិពលនៃការថយចុះគួរឱ្យកត់សំគាល់នូវស្តង់ដារនៃការរស់នៅ។ វាជាកង្វល់ពិសេសនៅពេលវាកើតឡើងរយៈពេលវែង និងនៅពេលដែលស្តង់ដារនៃការរស់នៅធ្លាក់ក្រោមកម្រិតទាបបំផុតមួយ ពោលគឺ ចំណុចនៃការបាត់បង់ធ្ងន់ធ្ងរ។

ការយកចិត្តទុកដាក់តែមួយមុខដែលជាទម្លាប់ពីមុនមករបស់អ្នកសេដ្ឋកិច្ច ដែលផ្តោតតែលើ GDP បាននាំឱ្យពួកគេមើលពុំឃើញភាពងាយរងគ្រោះឡើយ។ បុគ្គលនានាពុំចូលចិត្តហានិភ័យឡើយ។ ការដឹងថា ខ្លួនងាយរងគ្រោះ បាននាំទៅរកការបាត់បង់សុខុមាលភាព រួចទៅហើយ សូម្បីនៅមុនពួកគេប្រឈមនឹងផលវិបាកនៃការប៉ះទង្គិចដោយផ្ទាល់។ បរាជ័យនៃប្រព័ន្ធរបស់យើងក្នុងការស្រង់យកបានគ្រប់គ្រាន់អំពីសារៈសំខាន់នៃសន្តិសុខសម្រាប់សុខុមាលភាពបុគ្គល និងសង្គមគឺជាការទិទៀនគន្លឹះមួយចំពោះ GDP ដោយគណៈកម្មការអន្តរជាតិស្តីពីវង្វាស់លទ្ធផលសេដ្ឋកិច្ច និងវឌ្ឍនភាពសង្គម។

ប្រសិនបើយើងត្រូវបង្កើតគោលនយោបាយដើម្បីកាត់បន្ថយភាពងាយរងគ្រោះប្រការសំខាន់គឺត្រូវមានទស្សនៈធំទូលាយអំពីអ្វីដែលបង្កើតឱ្យមានភាពងាយរងគ្រោះបែបនោះ។ បុគ្គលនានា និងសង្គម មិនអាចជៀសវាងបានពីឥទ្ធិពលនៃអ្វីដែលអ្នកសេដ្ឋកិច្ចហៅថា "ការប៉ះទង្គិច" ព្រឹត្តិការណ៍អវិជ្ជមាននានាដែលមានលទ្ធភាពក្នុងការនាំឱ្យមានការថយចុះគួរឱ្យកត់សំគាល់នូវស្តង់ដារនៃការរស់នៅ។ កាលណាការប៉ះទង្គិចកាន់តែមានទំហំធំ ជម្រៅនិងរយៈពេលនៃការប៉ះទង្គិចនោះកាន់តែធំ ហើយភាពងាយរងគ្រោះកាន់តែធំផងដែរនោះ អ្វីៗទាំងអស់ផ្សេងទៀតមានដូចគ្នា។ ប៉ុន្តែបុគ្គលនានានិងសង្គម បង្កើតយន្តការនានាសម្រាប់ទប់ទល់នឹងការប៉ះទង្គិច។ សង្គមនិងសេដ្ឋកិច្ចខ្លះបានធ្វើការយ៉ាងល្អ ដើម្បីពង្រឹងសមត្ថភាពទប់ទល់នឹងការប៉ះទង្គិចបានល្អជាងសង្គមនិងសេដ្ឋកិច្ចដទៃទៀត។ ភាពងាយរងគ្រោះកើតមានខ្លាំងជាងគេចំពោះសង្គមនានាដែលទុកឱ្យខ្លួនឯងទទួលរងឥទ្ធិពលពីការប៉ះទង្គិចធំៗ ប៉ុន្តែបន្សល់ទុកប្រជាជនយ៉ាងច្រើនរបស់ខ្លួន ជាមួយអវត្តមានយន្តការគ្រប់គ្រាន់សម្រាប់ទប់ទល់។

កត្តាធំជាងគេដែលរួមចំណែកធ្វើមានឱ្យភាពងាយរងគ្រោះ ដែលជួនកាលមានឥទ្ធិពលអវិជ្ជមានមកលើកត្តាជាច្រើនដែលបានកត់សំគាល់ខាងលើផងដែរនោះ គឺវិសមភាព ហើយវាជាកត្តារួមចំណែកតាមវិធីជាច្រើន។ វិសមភាពបង្កឱ្យមានអស្ថិរភាព កំណើនភាពញឹកញាប់នៃកម្លាំងជម្រុញនៅក្នុងសេដ្ឋកិច្ច។ វិសមភាពក្នុងកម្រិតធ្ងន់ធ្ងរមានន័យថា ប្រជាជនជាចំនួនច្រើនស្ថិតនៅក្នុងភាពក្រីក្រ ដោយមានសមត្ថភាពទាបសម្រាប់ទប់ទល់នឹងការប៉ះទង្គិចនានានៅពេលដែលវាកើតឡើង។ កម្រិតធ្ងន់ធ្ងរនៃវិសមភាពសេដ្ឋកិច្ចមិនអាចជៀសវាងបានពីការនាំឱ្យមានអស្ថិរភាពនយោបាយឡើយ ហើយជាលទ្ធផល រដ្ឋាភិបាលមិនទំនងជាអាចផ្តល់ប្រព័ន្ធគាំពារសង្គម ដែលអាចការពារពលរដ្ឋក្រីក្រពីផលវិបាកនានានៃការប៉ះទង្គិចធំៗបានឡើយ។ យើងត្រូវចាប់ផ្តើមគិតអំពីវិសមភាព មិនមែនត្រឹមតែក្នុងបរិបទនៃក្រមសីលធម៌ប៉ុណ្ណោះទេ ដែលវាពិតជាត្រឹមត្រូវហើយ ប៉ុន្តែក៏ត្រូវគិតថាវាជាកង្វល់ដ៏សំខាន់ខាងសេដ្ឋកិច្ចផងដែរ ដែលជាផ្នែករួមមួយអំពីការអភិវឌ្ឍមនុស្ស និងជាពិសេស មានការពាក់ព័ន្ធជាមួយគ្រប់ការវិភាគអំពីភាពងាយរងគ្រោះ។

### បង្កើនវឌ្ឍនភាព និងចំណាត់ការរួមគ្នា

*ភាពងាយរងគ្រោះកាន់តែមានលក្ខណៈជាសកល ទាំងផ្នែកប្រភពដើម និងផលប៉ះពាល់របស់វា ដែលទាមទារឱ្យមានចំណាត់ការរួមគ្នា និងអភិបាលកិច្ចអន្តរជាតិប្រសើរជាងមុន។*

សកលភាវូបនីយកម្ម ធ្វើឱ្យប្រទេសនានាចូលរួមជាមួយគ្នា និងបានផ្តល់ឱកាសថ្មីៗ។ ប៉ុន្តែវាក៏បានបង្កើនហានិភ័យនៃការសាយភាយព្រឹត្តិការណ៍អវិជ្ជមានកាន់តែឆាប់រហ័សផងដែរ។ ព្រឹត្តិការណ៍ក្នុងពេលថ្មីៗនេះបានធ្វើឱ្យមានគម្លាតយ៉ាងធំ លើរបៀបនៃការគ្រប់គ្រងសកលភាវូបនីយកម្ម បញ្ហានានា ដែលរាប់ចាប់ពីសន្តិសុខស្បៀងរហូតដល់ការទទួលបានថាមពល ចាប់ពីនិយ័តកម្មហិរញ្ញវត្ថុ រហូតដល់ការប្រែប្រួលអាកាសធាតុ។ ការប្រឈមឆ្លងដែនទាំងនេះទំនងជានៅមានបន្តក្នុងបណ្តាទសវត្សរ៍ខាងមុខ ដោយសារនិម្មាបនកម្មអភិបាលកិច្ចពិភពលោក នៅខ្វះសមត្ថភាពសម្រាប់ទប់ស្កាត់ ឬកាត់បន្ថយការប៉ះទង្គិច។ អ្នកកសាងគោលនយោបាយ និងមេដឹកនាំនានាអាចឃើញថា ខ្លួនស្ថិតក្នុងស្ថានភាពពុំបានត្រៀមលក្ខណៈសម្រាប់ការប្រែប្រួលទាំងនេះ ដែលកើតឡើងយ៉ាងឆាប់រហ័ស និងក្នុងវិសាលភាពធំធេង។

### ធាតុផ្សំនៃកិច្ចសន្យាសង្គមពិភពលោក

*កិច្ចប្រឹងប្រែងកម្រិតពិភពលោកគឺជាតម្រូវការចាំបាច់ ដើម្បីធានាថាសកលភាវូបនីយកម្មឈានទៅមុខ និងការពារការអភិវឌ្ឍមនុស្ស – វិធានការនៅថ្នាក់ជាតិនឹងមានភាពងាយអនុម័តជាង នៅពេលមានការប្តេជ្ញា និងការគាំទ្រនៅកម្រិតពិភពលោក។*

សមត្ថភាពអាចត្រូវបានពង្រឹង និងជម្រើសនានាអាចការពារបាននៅថ្នាក់ជាតិ ប៉ុន្តែវិធានការរបស់ជាតិអាចអនុវត្តបានដោយងាយនៅពេលមានការប្តេជ្ញានៅកម្រិតពិភពលោក និងការគាំទ្រនៅកម្រិតពិភពលោក។ អំឡុងពេលឈានទៅរបៀបវារៈក្រោយឆ្នាំ 2015 និងការបង្កើតគោលដៅអភិវឌ្ឍន៍ដោយចីរភាពគឺជាឱកាសមួយសម្រាប់សហគមន៍អន្តរជាតិ និងរដ្ឋសមាជិក ក្នុងការប្តេជ្ញាសម្រេចគោលដៅនៃការផ្តល់ជាសកលនូវសេវាសាធារណៈ កិច្ចគាំពារសង្គមនៅថ្នាក់ជាតិ និងភាពមានការងារធ្វើពេញលេញ ដែលជាគោលដៅគន្លឹះសម្រាប់សហគមន៍ពិភពលោក។ ការប្តេជ្ញានៅកម្រិតពិភពលោកចំពោះគោលដៅទាំងនេះ អាចបើកឱកាសសម្រាប់គោលនយោបាយនៅថ្នាក់ជាតិ ដើម្បីឱ្យរដ្ឋកំណត់អំពីវិធីនានាសម្រាប់បង្កើតភាពមានការងារធ្វើ និងផ្តល់សេវានិងកិច្ចគាំពារសង្គម ដែលផ្តល់ផលបានល្អបំផុតនៅក្នុងបរិបទជាក់លាក់របស់រដ្ឋទាំងនោះ ប៉ុន្តែកិច្ចព្រមព្រៀងនៅកម្រិតពិភពលោកមានសារៈសំខាន់ណាស់ ដោយសារតែកិច្ចព្រមព្រៀងទាំងនោះ អាចញ៉ាំងឱ្យមានចំណាត់ការ និងការប្តេជ្ញា និងបង្កើតការគាំទ្រខាងហិរញ្ញវត្ថុ និងការគាំទ្រដទៃទៀត។

### ការកែលម្អអភិបាលកិច្ចពិភពលោក

បច្ចុប្បន្ននេះ ការប្រឈមជាច្រើនបានរួមបញ្ចូលគ្នា ដែលនាំមកនូវសារៈសំខាន់កាន់តែខ្លាំងឡើង ដែលរាប់ចាប់ពីការប្រែប្រួលអាកាសធាតុ រហូតដល់ទំនាស់ វិបត្តិសេដ្ឋកិច្ច និងការរំដើបរំជួលក្នុងសង្គម។ គេត្រូវការជាចាំបាច់នូវគោលនយោបាយជាក់លាក់ ដើម្បីកាត់បន្ថយភវនីយភាពនៃការគំរាមកំហែងជាក់លាក់ ប៉ុន្តែការកែប្រែជាទ្រង់ទ្រាយធំជាងមុន នៅលំដាប់ទីមួយនៃនិម្មាបនកម្មអភិបាលកិច្ចអាចជាតម្រូវការចាំបាច់ មុននឹងអាចធ្វើឱ្យមានវឌ្ឍនភាពលើបញ្ហា

បែបនោះ ដូចជា ភាពងាយប្រែប្រួលខាងហិរញ្ញវត្ថុ អតុល្យភាពនៃរបបពាណិជ្ជកម្ម ឬការប្រែប្រួលអាកាសធាតុ។

ការកែប្រែគោលនយោបាយគឺ ជាតម្រូវការចាំបាច់ដើម្បីកាត់បន្ថយការប៉ះទង្គិចបែបណាមួយ។ ការប្រឈមនៅ កម្រិតពិភពលោកមានច្រើនណាស់ ហើយអនុសាសន៍របស់យើងពុំមានលក្ខណៈគ្រប់គ្រាន់ឡើយ ប៉ុន្តែយើងដឹងថា ប្រព័ន្ធហិរញ្ញវត្ថុ និងពាណិជ្ជកម្មអាចនឹងកែសម្រួលបាន ហើយការគំរាមកំហែងលើបរិស្ថានអាចកាត់បន្ថយបាន តាមរយៈការកែប្រែនូវការយកចិត្តទុកដាក់របស់ស្ថាប័ន ទៅរកការផ្តល់ផលប្រយោជន៍សាធារណៈពិភពលោក។ អនុសាសន៍ទាំងនេះមានជាអាទិ៍ យន្តការហិរញ្ញវត្ថុ និងស្ថាប័ន ដែលជានាលទ្ធភាពប្រើប្រាស់ធនធានសម្រាប់ការទូទាត់ កាត់បន្ថយភាពងាយប្រែប្រួលនៃលំហូរហិរញ្ញវត្ថុ និងកាត់បន្ថយការរីករាលដាលបញ្ហាទាំងនេះ។ ត្រូវធ្វើការពិនិត្យឡើងវិញផងដែរនូវបទប្បញ្ញត្តិសម្រាប់ពាណិជ្ជកម្មកសិផល និង សេវាកម្ម ដោយផ្អែកលើនិន្នាការឆ្ពោះទៅកិច្ចព្រមព្រៀង ពាណិជ្ជកម្មទ្វេភាគី និងការរួមបញ្ចូលមាត្រានានាក្រៅពីពាណិជ្ជកម្ម ដែលកាត់បន្ថយលំហគោលនយោបាយនៅក្នុងវិស័យដទៃទៀត។ ការប្រែប្រួលអាកាសធាតុគឺជាការប្រឈមដ៏សំខាន់បំផុតមួយ សម្រាប់របៀបវារៈអភិវឌ្ឍន៍ពិភពលោក។ ការថែងមិនបានគ្រប់គ្រាន់អំពី ស្ថិរភាពអាកាសធាតុ ដែលជាប្រយោជន៍សាធារណៈពិភពលោក មួយដែរនោះ និងការលេចឡើងនៃភាពងាយរងគ្រោះ នៅចំពោះមុខព្រឹត្តិការណ៍ធាតុអាកាសមិនប្រក្រតី និងវិបត្តិ ស្បៀងអាហារ បានក្លាយជាការគំរាមកំហែងជាបន្តបន្ទាប់នៅក្នុងតំបន់ខុសៗគ្នានៃពិភពលោក។ ចំណាត់ការជាបន្ទាន់គឺជា តម្រូវការចាំបាច់នៅក្នុងសមរភូមិនេះ។ មានចំណាត់ការដែលអាចទុកចិត្តបាននៅថ្នាក់ក្រោមជាតិ ប៉ុន្តែចំណាត់ការនៅកម្រិតពហុភាគី គឺជាគន្លឹះនៅក្នុងវិធីសាស្រ្តទូលំទូលាយមួយ។

## ចំណាត់ការរួមគ្នាដើម្បីពិភពលោកមួយមានសុវត្ថិភាពជាងមុន

ការកាត់បន្ថយភាពងាយរងគ្រោះ នៅចំពោះមុខការគំរាមកំហែងឆ្លងដែន ទោះបីតាមរយៈការកែលម្អនិម្មាបនកម្មអភិបាលកិច្ច ដើម្បីកាត់បន្ថយការប៉ះទង្គិច ឬតាមរយៈវិធានការដើម្បីជួយប្រជាជនធ្វើការទប់ទល់ សុទ្ធតែទាមទារឱ្យមានការដឹកនាំនិងកិច្ចសហប្រតិបត្តិការខ្លាំងក្លាជាងមុនក្នុងចំណោមរដ្ឋនានា និងរវាងអង្គការអន្តរជាតិនានា។ កិច្ចការនេះក៏ទាមទារឱ្យមានវិធីដែលស៊ីសង្វាក់គ្នាផងដែរ ដើម្បីកំណត់អាទិភាព និងកាត់បន្ថយឥទ្ធិពលសាយភាយ និងការចូលរួមជាលក្ខណៈប្រព័ន្ធជាងមុនជាមួយសង្គមស៊ីវិល និងវិស័យឯកជន។

កង្វះការសម្របសម្រួល កិច្ចសហប្រតិបត្តិការ និងការដឹកនាំ ជាការរារាំងវឌ្ឍនភាពឆ្ពោះទៅដោះស្រាយការប្រឈមនានានៅកម្រិតពិភពលោក និងការកាត់បន្ថយភាពងាយរងគ្រោះ។ ទោះបីសំណើដើម្បីកែសម្រួលភាពជាប់គាំងនៃកិច្ចសហប្រតិបត្តិការអភិបាលកិច្ចពិភពលោក នៅពុំទាន់បានទទួលយកនៅឡើយក៏ដោយ ពិភពលោកបានប្រែប្រួលជាច្រើននៅក្នុងទសវត្សរ៍ កន្លងមកនេះ។ ការប្រឈមនៅកម្រិតពិភពលោកមានភាពបន្ទាន់បំផុតដែលពុំធ្លាប់ជួបប្រទះពីមុនមក ហើយបរិស្ថានភូមិសាស្រ្តនយោបាយពិភពលោកក៏មានភាពខុសគ្នាផងដែរ។ ដូចរបាយការណ៍អភិវឌ្ឍន៍មនុស្សឆ្នាំ 2013 បានគូសបញ្ជាក់រួចមកហើយ ការងើបឡើងនៃភូមិភាគខាងត្បូង តំណាងឱ្យឱកាសមួយដើម្បីធ្វើឱ្យអភិបាលកិច្ចពិភពលោកមានលក្ខណៈតំណាងច្រើនជាងមុន និងកាន់តែមានប្រសិទ្ធភាពផងដែរ។ ប៉ុន្តែការធ្វើបែបនេះបាននៅទាមទារឱ្យមានដំណោះស្រាយថ្មីសម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ និងការដឹកនាំ។

អភិបាលកិច្ចពិភពលោក ទំនងជាត្រូវចាត់ចែងឡើងដាច់ដោយឡែកពីគ្នាដោយមានស្ថាប័នដាច់ពីគ្នាដែលផ្តោតលើបញ្ហានានា ដូចជា ពាណិជ្ជកម្ម អាកាសធាតុ ហិរញ្ញវត្ថុ និងចំណាកស្រុក។ ប្រការនេះធ្វើឱ្យកាន់តែលំបាកក្នុងការនាំយកទស្សនវិស័យនៃប្រព័ន្ធនេះសម្រាប់ដោះស្រាយការប្រឈមនៅកម្រិតពិភពលោក ឬ ដើម្បីកំណត់អត្តសញ្ញាណឥទ្ធិពលសាយភាយ និងភាពផ្ទុយគ្នានៃចំណាត់ការរបស់រដ្ឋ និងទីភ្នាក់ងារអន្តរជាតិ។ ការវាយតម្លៃពេញលេញ និងពិស្តារនៅក្នុងពេលខុសៗគ្នាជាច្រើន និងដែលត្រួតគ្នាជាមួយបញ្ហានិម្មាបនកម្មនៃអភិបាលកិច្ចពិភពលោក គឺជាតម្រូវការចាំបាច់ ដើម្បីធានាថា កិច្ចសហប្រតិបត្តិការកម្រិតពិភពលោក មានប្រសិទ្ធភាព និងផ្តោតលើវិស័យដែលមានសារៈសំខាន់បំផុត។ ការវាយតម្លៃទាំងនេះគួរតែធ្វើឡើងដោយស្ថាប័នដែលគ្មានជំហរនយោបាយ និងមានអ្នកជំនាញការឯករាជ្យ ដែលអាចផ្តោតលើទស្សនវិស័យនៃប្រព័ន្ធបរានុម័តអំពីបញ្ហាពិភពលោក និងផ្តល់ការណែនាំ និងអនុសាសន៍នានាដល់ស្ថាប័នដឹកនាំ។

អភិបាលកិច្ចអាចកែលម្អទៅបាន នៅពេលដែលពលរដ្ឋបានចូលរួមពាក់ព័ន្ធដោយផ្ទាល់។ នៅក្នុងទំនាក់ទំនងជិតស្និទ្ធ ជាមួយសាធារណជន រដ្ឋាភិបាលអាចទទួលបានព័ត៌មានសុក្រឹត្យអំពីភាពងាយរងគ្រោះរបស់ប្រជាជន និងតាមដានឥទ្ធិពលនៃ អន្តរាគមន៍គោលនយោបាយ។ ការចូលរួមបែបនេះអាចនាំឱ្យអន្តរាគមន៍របស់រដ្ឋ និងការប្រើប្រាស់ធនធានសាធារណៈមានប្រសិទ្ធភាព។ ការចូលរួមប្រកបដោយប្រសិទ្ធភាពកើតឡើងនៅពេលណាដែលប្រជាជនមានសេរីភាព សន្តិសុខ សមត្ថភាព និងសម្លេង ដើម្បីមានឥទ្ធិពលលើការធ្វើសេចក្តីសម្រេច។ ពួកគេត្រូវតែជឿលើអំណាចរបស់ខ្លួន ក្នុងការបង្កើតឥទ្ធិពលដែលពួកគេចង់បាន តាមរយៈចំណាត់ការរួមគ្នា។

* * *

គោលដៅដែលបានសន្មតសម្រាប់កំណើន និងការអភិវឌ្ឍនៅកម្រិតពិភពលោក ដើម្បីទាំងអស់គ្នា មានចីរភាព និងមានភាពធន់ជាងមុន ទាមទារឱ្យមានចក្ខុវិស័យវិជ្ជមានអំពីកិច្ចការសាធារណលើពិភពលោក និងការទទួលស្គាល់ថា "ពិភពលោកដែលយើងចង់បាន" អាស្រ័យលើការផ្តល់ដោយជោគជ័យនូវប្រយោជន៍សាធារណៈពីធម្មជាតិ និងដែលមនុស្សជាអ្នកបង្កើត។ ទីផ្សារ ទោះបីមានសារៈសំខាន់ក៏ដោយ មិនអាចផ្តល់ផ្តល់កិច្ចការពារសង្គម និងបរិស្ថានបានគ្រប់គ្រាន់ដោយខ្លួនឯងឡើយ។ រដ្ឋនីមួយៗ ឬ រួមគ្នា ត្រូវតែគិតរួមបញ្ចូលគ្នានូវឆន្ទៈខ្លាំងក្លាជាងមុន ដែលគិតគូរអំពីអនាគត ដើម្បីធ្វើសហប្រតិបត្តិការ តាមរយៈការធ្វើសុខដុមូនីយកម្មគោលនយោបាយជាតិ ឬ តាមរយៈចំណាត់ការរួមគ្នាជាអន្តរជាតិ។ រដ្ឋាភិបាលនានាត្រូវផ្តល់លំហនយោបាយធំទូលាយជាងមុន ដើម្បីផ្តល់កិច្ចគាំពារ និងភាពមានការងារធ្វើសម្រាប់ពលរដ្ឋរបស់ខ្លួន។ សង្គមស៊ីវិលអាចបង្កើតឆន្ទៈនយោបាយ ប៉ុន្តែនៅក្នុងករណីដែលពលរដ្ឋទទួលស្គាល់គុណតម្លៃនៅកម្រិតបុគ្គល អំពីកិច្ចសហការឆ្លងដែន និងផលិតផលសាធារណៈតែប៉ុណ្ណោះ។

ដើម្បីមានវឌ្ឍនភាពទាមទារឱ្យមានសកម្មភាព។ ចំណុចដៅជាច្រើននៅក្នុងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ទំនងជាសម្រេចបាននៅកម្រិតជាតិ រហូតដល់ឆ្នាំ 2015 ប៉ុន្តែជោគជ័យមិនមែនកើតឡើងដោយស្វ័យប្រវត្តិឡើយ ចំណែកកំណើនមិនសុទ្ធតែកើតឡើងជាអចិន្ត្រៃយ៍ផងដែរទេ។ ការជម្រុញនូវការអភិវឌ្ឍមួយជំហានទៅមុខទៀត ទាមទារឱ្យមានកិច្ចការពារសមិទ្ធផល ទល់នឹងភាពងាយរងគ្រោះ និងការប៉ះទង្គិចនានា បង្កើនភាពធន់ និងធ្វើឱ្យវឌ្ឍនភាពមានភាពស៊ីជម្រៅជាងមុន។ ការកំណត់អត្តសញ្ញាណ និងការផ្តោតលើក្រុមងាយរងគ្រោះ ការកាត់បន្ថយវិសមភាព និងការដោះស្រាយភាពងាយរងគ្រោះដែលមានលក្ខណៈជារចនាសម្ព័ន្ធមានសារៈសំខាន់ជាសារវន្ត ដើម្បីទ្រទ្រង់និរន្តរភាពនៃការអភិវឌ្ឍនៅក្នុងអាយុកាលនៃបុគ្គលម្នាក់ៗ និងរវាងជំនាន់មនុស្សខុសៗគ្នា។

# ប្រទេស និងលំដាប់ HDI នៅឆ្នាំ ២០១៣ និងការប្រែប្រួលលំដាប់ពីឆ្នាំ ២០១២ ដល់ ២០១៣

| | | | |
|---|---|---|---|
| អាហ្វកានីស្ថង់ | 169 | 0 | |
| អាបានី | 95 | 2 | ↑ |
| អាល់ហ្សេរី | 93 | 0 | |
| អង់ដូរ៉ា | 37 | 0 | |
| អង់ហ្គោឡា | 149 | 0 | |
| អង់ទីហ្គានិងបាបោឌូ | 61 | –1 | ↓ |
| អាហ្សង់ទីន | 49 | 0 | |
| អាមេនី | 87 | 0 | |
| អូស្ត្រាលី | 2 | 0 | |
| អូទ្រីស | 21 | 0 | |
| អាហ្សែបៃហ្សង់ | 76 | –1 | ↓ |
| បាហាម៉ាស | 51 | 0 | |
| បារ៉ែន | 44 | 0 | |
| បង់ក្លាដែស | 142 | 1 | ↑ |
| បារបាដូស | 59 | –1 | ↓ |
| បេឡារុស | 53 | 1 | ↑ |
| បែលហ្ស៊ិក | 21 | 0 | |
| បេលីហ្ស | 84 | 0 | |
| បេនីន | 165 | 0 | |
| ប៊ុយតង់ | 136 | 0 | |
| បូលីវី (រដ្ឋពហុជាតិ) | 113 | 0 | |
| បូស្នៀ និងហេហ្សីហ្គោវីណា | 86 | 0 | |
| បូស្វាណា | 109 | –1 | ↓ |
| ប្រេស៊ីល | 79 | 1 | ↑ |
| ប្រ៊ុយណេដារូសាឡាម | 30 | 0 | |
| ប៊ុលហ្គារី | 58 | 0 | |
| ប៊ូគីណាហ្វាសូ | 181 | 0 | |
| ប៊ូរុនឌី | 180 | 0 | |
| កម្ពុជា | 136 | 1 | ↑ |
| កាមេរូន | 152 | 0 | |
| កាណាដា | 8 | 0 | |
| ខេប វែគ | 123 | –2 | ↓ |
| សាធារណរដ្ឋអាហ្វ្រិកកណ្ដាល | 185 | 0 | |
| ឆាត | 184 | –1 | ↓ |
| ស៊ីលី | 41 | 1 | ↑ |
| ចិន | 91 | 2 | ↑ |
| កូឡុំប៊ី | 98 | 0 | |
| កូម៉ូរ៉ូស | 159 | –1 | ↓ |
| កុងហ្គោ | 140 | 0 | |
| កុងហ្គោ(សាធារណរដ្ឋប្រជាធិបតេយ្យ) | 186 | 1 | ↑ |
| កូស្តារីកា | 68 | –1 | ↓ |
| កូដឌីវ័រ | 171 | 0 | |
| ក្រូអាទី | 47 | 0 | |
| គុយបា | 44 | 0 | |
| សាយប្រ៊ីស | 32 | 0 | |
| ឆែក សាធារណរដ្ឋ | 28 | 0 | |
| ដាណឺម៉ាក | 10 | 0 | |
| ជីប៊ូទី | 170 | 0 | |
| ដូមីនីកា | 93 | –1 | ↓ |
| សាធារណរដ្ឋដូមីនីក | 102 | 0 | |
| អាក្វាឌ័រ | 98 | 0 | |
| អេហ្ស៊ីប | 110 | –2 | ↓ |
| អែលសាល់វ៉ាឌ័រ | 115 | 0 | |
| អេក្វាទ័រៀលហ្គីនេ | 144 | –3 | ↓ |
| អេរីទ្រា | 182 | 0 | |
| អេស្តូនៀ | 33 | 0 | |
| អេត្យូពី | 173 | 0 | |
| ហ្វីជី | 88 | 0 | |
| ហ្វាំងឡង់ | 24 | 0 | |
| បារាំង | 20 | 0 | |
| ហ្គាបុង | 112 | –1 | ↓ |
| ហ្គាំប៊ី | 172 | 0 | |
| ជ័រជៀ | 79 | 2 | ↑ |
| អាល្លឺម៉ង់ | 6 | 0 | |
| ហ្គាណា | 138 | 0 | |
| ក្រិក | 29 | 0 | |
| ក្រេណាដា | 79 | –1 | ↓ |
| ហ្គាតេម៉ាឡា | 125 | 0 | |
| ហ្គីនេ | 179 | –1 | ↓ |
| ហ្គីនេ-ប៊ីសូ | 177 | 0 | |
| ហ្គាយយ៉ាណា | 121 | 0 | |
| ហៃទី | 168 | 0 | |
| ហុងឌុយរ៉ាស | 129 | 0 | |
| ហុងកុង (ចិន) | 15 | 0 | |
| ហុងគ្រី | 43 | 0 | |
| អាយស្លែន | 13 | 0 | |
| ឥណ្ឌា | 135 | 0 | |
| ឥណ្ឌូនេស៊ី | 108 | 0 | |
| អ៊ីរ៉ង់ (សាធារណរដ្ឋអ៊ីស្លាម) | 75 | –2 | ↓ |
| អ៊ីរ៉ាក់ | 120 | 0 | |
| អៀរឡង់ | 11 | –3 | ↓ |
| អ៊ីស្រាអែល | 19 | 0 | |
| អ៊ីតាលី | 26 | 0 | |
| ចាម៉ៃកា | 96 | –3 | ↓ |
| ជប៉ុន | 17 | –1 | ↓ |
| ហ្ស៊កដង់ | 77 | 0 | |
| កាហ្សាក់ស្ថង់ | 70 | 0 | |
| កេនយ៉ា | 147 | 0 | |
| គីរីបាទី | 133 | 0 | |
| កូរ៉េ(សាធារណរដ្ឋ) | 15 | 1 | ↑ |
| គុយវ៉ែត | 46 | –2 | ↓ |
| គៀហ្គីស្ថង់ | 125 | 1 | ↑ |
| ឡាវ (សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិត) | 139 | 0 | |
| ឡាទ្វី | 48 | 0 | |
| លីបង់ | 65 | 0 | |
| ឡេហ្សូថូ | 162 | 1 | ↑ |
| លីបេរី | 175 | 0 | |
| លីប៊ី | 55 | –5 | ↓ |
| លិចទេនស្តេន | 18 | –2 | ↓ |
| លីទុយអានី | 35 | 1 | ↑ |
| លុចហ្សំបួ | 21 | 0 | |
| ម៉ាដាហ្គាស្កា | 155 | 0 | |
| ម៉ាឡាវី | 174 | 0 | |
| ម៉ាឡេស៊ី | 62 | 0 | |
| ម៉ាល់ឌីវ | 103 | 0 | |
| ម៉ាលី | 176 | 0 | |
| ម៉ាល់តា | 39 | 0 | |
| ម៉ូរីតានី | 161 | –2 | ↓ |
| ម៉ូរីទ្យុស | 63 | 0 | |
| ម៉ិចស៊ិច | 71 | –1 | ↓ |
| មីក្រូនេស៊ី (រដ្ឋសហព័ន្ធ) | 124 | 0 | |
| ម៉ុលដូវ៉ា (សាធារណរដ្ឋ) | 114 | 2 | ↑ |
| ម៉ុងហ្គោលី | 103 | 3 | ↑ |
| ម៉ុងតេនេក្រូ | 51 | 1 | ↑ |
| ម៉ូរ៉ុកកូ | 129 | 2 | ↑ |
| ម៉ូហ្សំប៊ិក | 178 | 1 | ↑ |
| មីយ៉ាន់ម៉ា | 150 | 0 | |
| ណាមីប៊ី | 127 | 0 | |
| នេប៉ាល់ | 145 | 0 | |
| ហូឡង់ | 4 | 0 | |
| នូវែលហ្សេឡង់ | 7 | 0 | |
| នីការ៉ាហ្គា | 132 | 0 | |
| នីហ្សេរ | 187 | –1 | ↓ |
| នីហ្សេរីយ៉ា | 152 | 1 | ↑ |
| ន័រវេស | 1 | 0 | |
| អូម៉ង់ | 56 | 0 | |
| ប៉ាគីស្ថង់ | 146 | 0 | |
| ប៉ាឡាវ | 60 | 0 | |
| រដ្ឋប៉ាលេស្ទីន | 107 | 0 | |
| ប៉ាណាម៉ា | 65 | 2 | ↑ |
| ប៉ាពួញូហ្គីនេ | 157 | –1 | ↓ |
| ប៉ារ៉ាហ្គាយ | 111 | 0 | |
| ប៉េរូ | 82 | 0 | |
| ហ្វីលីពីន | 117 | 1 | ↑ |
| ប៉ូឡូញ | 35 | –1 | ↓ |
| ព័រទុយហ្គាល់ | 41 | 0 | |
| កាតា | 31 | 0 | |
| រូម៉ា នី | 54 | 1 | ↑ |
| សហព័ន្ធរុស្ស៊ី | 57 | 0 | |
| រវ៉ាន់ដា | 151 | 0 | |
| សាំងគីត និងនេវីស | 73 | 0 | |
| សាំងលូសា | 97 | –4 | ↓ |
| សាំងវ៉ាំងសង់ និងក្រេណាឌីន | 91 | 0 | |
| សាម៉ាវ | 106 | –2 | ↓ |
| សាវតូមេ និងព្រីនស៊ីពេ | 142 | –1 | ↓ |
| អារ៉ាប់ប៊ីសាអ៊ូឌីត | 34 | 0 | |
| សេនេហ្គាល់ | 163 | –3 | ↓ |
| ស៊ែកប៊ី | 77 | 1 | ↑ |
| សីស្ស៊ីល | 71 | –1 | ↓ |
| សេរ៉ាឡេអូន | 183 | 1 | ↑ |
| សឹង្ហបុរី | 9 | 3 | ↑ |
| ស្លូវ៉ាគី | 37 | 1 | ↑ |
| ស្លូវេនៀ | 25 | 0 | |
| កោះសូឡូម៉ុង | 157 | 0 | |
| អាហ្វ្រិកខាងត្បូង | 118 | 1 | ↑ |
| អេស្ប៉ាញ | 27 | 0 | |
| ស្រីឡង្កា | 73 | 2 | ↑ |
| ស៊ូដង់ | 166 | 0 | |
| ស៊ូរីនែម | 100 | 1 | ↑ |
| ស្វាស៊ីលេន | 148 | 0 | |
| ស៊ុយអែដ | 12 | –1 | ↓ |
| ស្វីស | 3 | 0 | |
| សាធារណរដ្ឋអារ៉ាប់សេរី | 118 | –4 | ↓ |
| តាជីគីស្ថង់ | 133 | 1 | ↑ |
| តង់ហ្សានី (សហភាពសាធារណរដ្ឋ) | 159 | 1 | ↑ |
| ថៃ | 89 | 0 | |
| សាធារណរដ្ឋយូហ្គោស្លាវនៃម៉ាសេដូនី | 84 | 1 | ↑ |
| ទីម័រលីស | 128 | 1 | ↑ |
| តូហ្គោ | 166 | 1 | ↑ |
| តុងហ្គា | 100 | 0 | |
| ទ្រីនីដាត និងតូបាហ្គោ | 64 | 0 | |
| ទុយនេហ្ស៊ី | 90 | 0 | |
| ទួគី | 69 | 0 | |
| ទួមេនីស្ថង់ | 103 | 1 | ↑ |
| យូហ្គាន់ដា | 164 | 0 | |
| អ៊ុយក្រែន | 83 | 0 | |
| សហភាពអារ៉ាប់អេមីរេត | 40 | 0 | |
| ចក្រភពអង់គ្លេស | 14 | 0 | |
| សហរដ្ឋអាមេរិក | 5 | 0 | |
| អ៊ុយរ៉ាហ្គាយ | 50 | 2 | ↑ |
| អ៊ូស្បេគីស្ថង់ | 116 | 0 | |
| វ៉ាណាទូ | 131 | –3 | ↓ |
| វេនេហ្ស៊ុយអេឡា (សាធារណរដ្ឋបូលីវ៉ារ៉ាន) | 67 | –1 | ↓ |
| វៀតណាម | 121 | 0 | |
| យេមែន | 154 | 0 | |
| ហ្សំប៊ី | 141 | 2 | ↑ |
| ហ្ស៊ីមបាវេ | 156 | 4 | ↑ |

សំគាល់៖ តម្លៃវិជ្ជមានឬអវិជ្ជមាន និងគំនូសព្រួញ បង្ហាញលេខលំដាប់ឡើងចុះរបស់ប្រទេសនីមួយៗ ពីឆ្នាំ២០១២ដល់២០១៣។ ប្រឡោះទំនេរបង្ហាញថា លេខលំដាប់គ្មានការប្រែប្រួលទេ។

# សន្ទស្សន៍អភិវឌ្ឍន៍មនុស្ស

| | សន្ទស្សន៍អភិវឌ្ឍន៍មនុស្ស | HDI កែតម្រូវតាមវិសមភាព | | | សន្ទស្សន៍វិសមភាពយេនឌ័រ | | សន្ទស្សន៍អភិវឌ្ឍន៍ទាក់ទងនឹងយេនឌ័រ | | សន្ទស្សន៍ភាពក្រីក្រពហុវិជ្ជភាព | |
|---|---|---|---|---|---|---|---|---|---|---|
| | តម្លៃ | តម្លៃ | ភាពខុសគ្នាពីលំដាប់ HDI | មេគុណវិសមភាពមនុស្ស | តម្លៃ | លំដាប់ | តម្លៃ | លំដាប់ | តម្លៃ[c] | ឆ្នាំ/អង្កេត[d] |
| លំដាប់ HDI | 2013 | 2013 | 2013[a] | 2013 | 2013 | 2013 | 2013 | 2013[b] | | |
| **ការអភិវឌ្ឍមនុស្សខ្ពស់ខ្លាំង** | | | | | | | | | | |
| 1 ន័រវេស | 0.944 | 0.891 | 0 | 5.5 | 0.068 | 9 | 0.997 | 5 | .. | .. |
| 2 អូស្ត្រាលី | 0.933 | 0.860 | 0 | 7.5 | 0.113 | 19 | 0.975 | 40 | .. | .. |
| 3 ស្វីស | 0.917 | 0.847 | –1 | 7.6 | 0.030 | 2 | 0.953 | 76 | .. | .. |
| 4 ហូឡង់ | 0.915 | 0.854 | 1 | 6.6 | 0.057 | 7 | 0.968 | 51 | .. | .. |
| 5 សហរដ្ឋអាមេរិក | 0.914 | 0.755 | –23 | 16.2 | 0.262 | 47 | 0.995 | 7 | .. | .. |
| 6 អាល្លឺម៉ង់ | 0.911 | 0.846 | 1 | 7.0 | 0.046 | 3 | 0.962 | 61 | .. | .. |
| 7 នូវែលហ្សេឡង់ | 0.910 | .. | .. | .. | 0.185 | 34 | 0.971 | 47 | .. | .. |
| 8 កាណាដា | 0.902 | 0.833 | –2 | 7.5 | 0.136 | 23 | 0.986 | 24 | .. | .. |
| 9 សឹង្ហបុរី | 0.901 | .. | .. | .. | 0.090 | 15 | 0.967 | 52 | .. | .. |
| 10 ដាណឺម៉ាក់ | 0.900 | 0.838 | 0 | 6.8 | 0.056 | 5 | 0.989 | 17 | .. | .. |
| 11 អៀរឡង់ | 0.899 | 0.832 | –1 | 7.4 | 0.115 | 20 | 0.965 | 56 | .. | .. |
| 12 ស៊ុយអែដ | 0.898 | 0.840 | 3 | 6.4 | 0.054 | 4 | 1.004 | 6 | .. | .. |
| 13 អាយស្លែន | 0.895 | 0.843 | 5 | 5.6 | 0.088 | 14 | 0.982 | 30 | .. | .. |
| 14 ចក្រភពអង់គ្លេស | 0.892 | 0.812 | –4 | 8.6 | 0.193 | 35 | 0.993 | 13 | .. | .. |
| 15 ហុងកុង (ចិន) | 0.891 | .. | .. | .. | .. | .. | 0.969 | 49 | .. | .. |
| 15 កូរ៉េ(សាធារណរដ្ឋ) | 0.891 | 0.736 | –20 | 16.8 | 0.101 | 17 | 0.940 | 85 | .. | .. |
| 17 ជប៉ុន | 0.890 | 0.779 | –6 | 12.2 | 0.138 | 25 | 0.951 | 79 | .. | .. |
| 18 លិចតេនស្តែន | 0.889 | .. | .. | .. | .. | .. | .. | .. | .. | .. |
| 19 អ៊ីស្រាអែល | 0.888 | 0.793 | –4 | 10.4 | 0.101 | 17 | 0.984 | 29 | .. | .. |
| 20 បារាំង | 0.884 | 0.804 | –2 | 8.9 | 0.080 | 12 | 0.989 | 17 | .. | .. |
| 21 អូទ្រីស | 0.881 | 0.818 | 4 | 7.1 | 0.056 | 5 | 0.935 | 91 | .. | .. |
| 21 បែលហ្ស៊ិក | 0.881 | 0.806 | 0 | 8.5 | 0.068 | 9 | 0.977 | 38 | .. | .. |
| 21 លុចហ្សំបួ | 0.881 | 0.814 | 3 | 7.5 | 0.154 | 29 | 0.961 | 66 | .. | .. |
| 24 ហ្វាំងឡង់ | 0.879 | 0.830 | 9 | 5.5 | 0.075 | 11 | 1.006 | 8 | .. | .. |
| 25 ស្លូវេនៀ | 0.874 | 0.824 | 9 | 5.7 | 0.021 | 1 | 1.006 | 8 | .. | .. |
| 26 អ៊ីតាលី | 0.872 | 0.768 | –1 | 11.6 | 0.067 | 8 | 0.962 | 61 | .. | .. |
| 27 អេស្ប៉ាញ | 0.869 | 0.775 | 1 | 10.5 | 0.100 | 16 | 0.985 | 25 | .. | .. |
| 28 ឆែក សាធារណរដ្ឋ | 0.861 | 0.813 | 9 | 5.5 | 0.087 | 13 | 0.969 | 49 | .. | .. |
| 29 ក្រិក | 0.853 | 0.762 | 0 | 10.5 | 0.146 | 27 | 0.959 | 69 | .. | .. |
| 30 ប្រ៊ុយណេដារូសាឡាម | 0.852 | .. | .. | .. | .. | .. | 0.981 | 31 | .. | .. |
| 31 កាតា | 0.851 | .. | .. | .. | 0.524 | 113 | 0.979 | 32 | .. | .. |
| 32 សាយប្រ៊ីស | 0.845 | 0.752 | –3 | 10.9 | 0.136 | 23 | 0.940 | 85 | .. | .. |
| 33 អេស្តូនៀ | 0.840 | 0.767 | 3 | 8.5 | 0.154 | 29 | 1.042 | 70 | .. | .. |
| 34 អារ៉ាប់ប៊ីសាអ៊ូឌីត | 0.836 | .. | .. | .. | 0.321 | 56 | 0.897 | 112 | .. | .. |
| 35 លីទុយអានី | 0.834 | 0.746 | –3 | 10.4 | 0.116 | 21 | 1.036 | 58 | .. | .. |
| 35 ប៉ូឡូញ | 0.834 | 0.751 | –2 | 9.7 | 0.139 | 26 | 1.010 | 14 | .. | .. |
| 37 អង់ដូរ៉ា | 0.830 | .. | .. | .. | .. | .. | .. | .. | .. | .. |
| 37 ស្លូវ៉ាគី | 0.830 | 0.778 | 9 | 6.2 | 0.164 | 32 | 1.000 | 1 | .. | .. |
| 39 ម៉ាល់តា | 0.829 | 0.760 | 5 | 8.2 | 0.220 | 41 | 0.954 | 75 | .. | .. |
| 40 សហភាពអារ៉ាប់អេមីរេត | 0.827 | .. | .. | .. | 0.244 | 43 | 0.958 | 70 | .. | .. |
| 41 ស៊ីលី | 0.822 | 0.661 | –16 | 18.5 | 0.355 | 68 | 0.962 | 61 | .. | .. |
| 41 ព័រទុយហ្កាល់ | 0.822 | 0.739 | 0 | 9.8 | 0.116 | 21 | 0.970 | 48 | .. | .. |
| 43 ហុងគ្រី | 0.818 | 0.757 | 7 | 7.3 | 0.247 | 45 | 0.998 | 4 | .. | .. |
| 44 បារ៉ែន | 0.815 | .. | .. | .. | 0.253 | 46 | 0.961 | 66 | .. | .. |
| 44 គុយបា | 0.815 | .. | .. | .. | 0.350 | 66 | 0.962 | 61 | .. | .. |
| 46 គុយវ៉ែត | 0.814 | .. | .. | .. | 0.288 | 50 | 0.987 | 22 | .. | .. |
| 47 ក្រូអាទី | 0.812 | 0.721 | –2 | 11.1 | 0.172 | 33 | 0.987 | 22 | .. | .. |
| 48 ឡាទ្វី | 0.810 | 0.725 | 0 | 10.3 | 0.222 | 42 | 1.033 | 52 | .. | .. |
| 49 អាហ្សង់ទីន | 0.808 | 0.680 | –4 | 15.3 | 0.381 | 74 | 1.001 | 2 | 0.015[e] | 2005 N |
| **ការអភិវឌ្ឍមនុស្សខ្ពស់** | | | | | | | | | | |
| 50 អ៊ុយរ៉ាហ្គាយ | 0.790 | 0.662 | –8 | 15.7 | 0.364 | 70 | 1.015 | 25 | .. | .. |
| 51 បាហាម៉ាស | 0.789 | 0.676 | –3 | 14.0 | 0.316 | 53 | .. | .. | .. | .. |
| 51 ម៉ុងតេនេក្រូ | 0.789 | 0.733 | 5 | 7.1 | .. | .. | .. | .. | 0.012[f] | 2005/2006 M |
| 53 បេឡារូស | 0.786 | 0.726 | 6 | 7.5 | 0.152 | 28 | 1.021 | 32 | 0.001 | 2005 M |
| 54 រ៉ូម៉ានី | 0.785 | 0.702 | 4 | 10.4 | 0.320 | 54 | 0.973 | 43 | .. | .. |
| 55 លីប៊ី | 0.784 | .. | .. | .. | 0.215 | 40 | 0.931 | 93 | .. | .. |
| 56 អូម៉ង់ | 0.783 | .. | .. | .. | 0.348 | 64 | .. | .. | .. | .. |
| 57 សហព័ន្ធរុស្ស៊ី | 0.778 | 0.685 | 3 | 11.6 | 0.314 | 52 | 1.038 | 61 | .. | .. |

| | | សន្ទស្សន៍អភិវឌ្ឍន៍មនុស្ស | HDI កែតម្រូវតាមវិសមភាព | | មេគុណវិសមភាពមនុស្ស | សន្ទស្សន៍វិសមភាពយេនឌ័រ | | សន្ទស្សន៍អភិវឌ្ឍន៍ទាក់ទងនឹងយេនឌ័រ | | សន្ទស្សន៍ភាពក្រីក្រពហុវិជ្ជភាព | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | តម្លៃ | តម្លៃ | ភាពខុសគ្នាពីលំដាប់ HDI | | តម្លៃ | លំដាប់ | តម្លៃ | លំដាប់ | តម្លៃ[c] | ឆ្នាំ/អង្កេត[d] |
| លំដាប់ HDI | | 2013 | 2013 | 2013[a] | 2013 | 2013 | 2013 | 2013 | 2013[b] | | |
| 58 | ប៊ុលហ្គារី | 0.777 | 0.692 | 5 | 10.8 | 0.207 | 38 | 0.994 | 8 | .. | .. |
| 59 | បារបាដូស | 0.776 | .. | .. | .. | 0.350 | 66 | 1.021 | 32 | .. | .. |
| 60 | ប៉ាឡាវ | 0.775 | .. | .. | .. | .. | .. | .. | .. | .. | .. |
| 61 | អង់ទីហ្គានិងបារបាឌូ | 0.774 | .. | .. | .. | .. | .. | .. | .. | .. | .. |
| 62 | ម៉ាឡេស៊ី | 0.773 | .. | .. | .. | 0.210 | 39 | 0.935 | 91 | .. | .. |
| 63 | ម៉ូរីទ្យុស | 0.771 | 0.662 | –2 | 14.1 | 0.375 | 72 | 0.957 | 72 | .. | .. |
| 64 | ទ្រីនីដាត និងតូបាហ្គោ | 0.766 | 0.649 | –6 | 15.0 | 0.321 | 56 | 0.994 | 8 | 0.007 | 2006 M |
| 65 | លីបង់ | 0.765 | 0.606 | –17 | 20.3 | 0.413 | 80 | 0.900 | 110 | .. | .. |
| 65 | ប៉ាណាម៉ា | 0.765 | 0.596 | –18 | 21.4 | 0.506 | 107 | 0.978 | 36 | .. | .. |
| 67 | វេនេហ្ស៊ូអេឡា (សាធារណរដ្ឋបូលីវ៉ារ៉ាន) | 0.764 | 0.613 | –10 | 19.4 | 0.464 | 96 | 0.999 | 2 | .. | .. |
| 68 | កូស្តារីកា | 0.763 | 0.611 | –11 | 19.1 | 0.344 | 63 | 0.973 | 43 | .. | .. |
| 69 | ទួគី | 0.759 | 0.639 | –3 | 15.6 | 0.360 | 69 | 0.884 | 118 | .. | .. |
| 70 | កាហ្សាក់ស្តង់ | 0.757 | 0.667 | 9 | 11.8 | 0.323 | 59 | 1.015 | 25 | 0.004 | 2010/2011 M |
| 71 | ម៉ិចស៊ិច | 0.756 | 0.583 | –13 | 22.3 | 0.376 | 73 | 0.940 | 85 | 0.024 | 2012 N |
| 71 | សីស្ស៊ីល | 0.756 | .. | .. | .. | .. | .. | .. | .. | .. | .. |
| 73 | សាំងគីត និងនេវីស | 0.750 | .. | .. | .. | .. | .. | .. | .. | .. | .. |
| 73 | ស្រីឡាំងកា | 0.750 | 0.643 | 1 | 14.2 | 0.383 | 75 | 0.961 | 66 | .. | .. |
| 75 | អ៊ីរ៉ង់ (សាធារណរដ្ឋអ៊ីស្លាម) | 0.749 | 0.498 | –34 | 32.1 | 0.510 | 109 | 0.847 | 128 | .. | .. |
| 76 | អាហ្សែរបៃហ្សង់ | 0.747 | 0.659 | 7 | 11.5 | 0.340 | 62 | 0.952 | 77 | 0.009 | 2006 D |
| 77 | ហ្ស៊រដង់ | 0.745 | 0.607 | –5 | 18.5 | 0.488 | 101 | 0.842 | 130 | 0.004 | 2009 D |
| 77 | សែកប៊ី | 0.745 | 0.663 | 12 | 10.9 | .. | .. | .. | .. | 0.001 | 2010 M |
| 79 | ប្រេស៊ីល | 0.744 | 0.542 | –16 | 26.3 | 0.441 | 85 | .. | .. | 0.012 [g] | 2012 N |
| 79 | ជ័រជៀរ | 0.744 | 0.636 | 4 | 14.0 | .. | .. | 0.941 | 84 | 0.008 | 2005 M |
| 79 | ក្រេណាដា | 0.744 | .. | .. | .. | .. | .. | .. | .. | .. | .. |
| 82 | ប៉េរូ | 0.737 | 0.562 | –9 | 23.4 | 0.387 | 77 | 0.957 | 72 | 0.043 | 2012 D |
| 83 | អ៊ុយក្រែន | 0.734 | 0.667 | 18 | 9.1 | 0.326 | 61 | 1.012 | 21 | 0.002 [g] | 2007 D |
| 84 | បេលីហ្ស | 0.732 | .. | .. | .. | 0.435 | 84 | 0.963 | 60 | 0.030 | 2011 M |
| 84 | អតីតសាធារណរដ្ឋយូហ្គោស្លាវនៃម៉ាសេដូនី | 0.732 | 0.633 | 7 | 13.3 | 0.162 | 31 | 0.944 | 83 | 0.007 [f] | 2011 M |
| 86 | បូស្នៀ និងហេហ្ស៊ីហ្គោវីណា | 0.731 | 0.651 | 13 | 10.7 | 0.201 | 36 | .. | .. | 0.006 [f] | 2011/2012 M |
| 87 | អាមេនី | 0.730 | 0.655 | 15 | 10.2 | 0.325 | 60 | 0.994 | 8 | 0.002 | 2010 D |
| 88 | ហ្វីជី | 0.724 | 0.613 | 6 | 15.1 | .. | .. | 0.937 | 89 | .. | .. |
| 89 | ថៃ | 0.722 | 0.573 | –2 | 20.0 | 0.364 | 70 | 0.990 | 14 | 0.004 [g] | 2005/2006 M |
| 90 | ទុយនេហ្ស៊ី | 0.721 | .. | .. | .. | 0.265 | 48 | 0.891 | 116 | 0.006 | 2011/2012 M |
| 91 | ចិន | 0.719 | .. | .. | .. | 0.202 | 37 | 0.939 | 88 | 0.026 [h] | 2009 N |
| 91 | សាំងវ៉ាងសង់ និងក្រេណាឌីន | 0.719 | .. | .. | .. | .. | .. | .. | .. | .. | .. |
| 93 | អាល់ហ្សេរី | 0.717 | .. | .. | .. | 0.425 | 81 | 0.843 | 129 | .. | .. |
| 93 | ដូមីនីកា | 0.717 | .. | .. | .. | .. | .. | .. | .. | .. | .. |
| 95 | អាបានី | 0.716 | 0.620 | 11 | 13.4 | 0.245 | 44 | 0.957 | 72 | 0.005 | 2008/2009 D |
| 96 | ចាម៉ៃកា | 0.715 | 0.579 | 1 | 18.6 | 0.457 | 88 | 0.989 | 17 | .. | .. |
| 97 | សាំងលូសា | 0.714 | .. | .. | .. | .. | .. | .. | .. | .. | .. |
| 98 | កូឡុំប៊ី | 0.711 | 0.521 | –10 | 25.7 | 0.460 | 92 | 0.972 | 46 | 0.032 | 2010 D |
| 98 | អាក្វាឌ័រ | 0.711 | 0.549 | –3 | 22.4 | 0.429 | 82 | .. | .. | .. | .. |
| 100 | ស៊ូរីនេម | 0.705 | 0.534 | –6 | 23.5 | 0.463 | 95 | 0.974 | 41 | 0.033 [f] | 2010 M |
| 100 | តុងហ្គា | 0.705 | .. | .. | .. | 0.458 | 90 | 0.966 | 54 | .. | .. |
| 102 | សាធារណរដ្ឋដូមីនិក | 0.700 | 0.535 | –4 | 23.4 | 0.505 | 105 | .. | .. | 0.026 | 2007 D |
| **ការអភិវឌ្ឍមនុស្សមធ្យម** | | | | | | | | | | | |
| 103 | ម៉ាល់ឌីវ | 0.698 | 0.521 | –7 | 24.2 | 0.283 | 49 | 0.936 | 90 | 0.008 | 2009 D |
| 103 | ម៉ុងហ្គោលី | 0.698 | 0.618 | 16 | 11.4 | 0.320 | 54 | 1.021 | 32 | 0.077 | 2005 M |
| 103 | ទួមេនីស្តង់ | 0.698 | .. | .. | .. | .. | .. | .. | .. | .. | .. |
| 106 | សាម៉ាវ | 0.694 | .. | .. | .. | 0.517 | 111 | 0.948 | 81 | .. | .. |
| 107 | រដ្ឋប៉ាលេស្ទីន | 0.686 | 0.606 | 13 | 11.7 | .. | .. | 0.974 | 41 | 0.007 | 2006/2007 N |
| 108 | ឥណ្ឌូនេស៊ី | 0.684 | 0.553 | 5 | 19.1 | 0.500 | 103 | 0.923 | 98 | 0.024 [g] | 2012 D |
| 109 | បូស្វាណា | 0.683 | 0.422 | –21 | 36.5 | 0.486 | 100 | 0.964 | 58 | .. | .. |
| 110 | អេហ្ស៊ីប | 0.682 | 0.518 | –5 | 22.8 | 0.580 | 130 | 0.855 | 125 | 0.036 [i] | 2008 D |
| 111 | ប៉ារ៉ាហ្គាយ | 0.676 | 0.513 | –5 | 23.7 | 0.457 | 88 | 0.966 | 54 | .. | .. |
| 112 | ហ្គាបុង | 0.674 | 0.512 | –5 | 24.0 | 0.508 | 108 | .. | .. | 0.073 | 2012 D |
| 113 | បូលីវី (រដ្ឋពហុជាតិ) | 0.667 | 0.470 | –10 | 29.4 | 0.472 | 97 | 0.931 | 93 | 0.097 | 2008 D |
| 114 | ម៉ុលដូវ៉ា (សាធារណរដ្ឋ) | 0.663 | 0.582 | 16 | 12.0 | 0.302 | 51 | 0.990 | 14 | 0.005 | 2005 D |
| 115 | អែលសាល់វាឌ័រ | 0.662 | 0.485 | –7 | 26.2 | 0.441 | 85 | 0.965 | 56 | .. | .. |

| លំដាប់ HDI | សន្ទស្សន៍អភិវឌ្ឍន៍មនុស្ស | HDI កែតម្រូវតាមវិសមភាព | | មេគុណវិសមភាពមនុស្ស | សន្ទស្សន៍វិសមភាពយេនឌ័រ | | សន្ទស្សន៍អភិវឌ្ឍន៍ទាក់ទងនឹងយេនឌ័រ | | សន្ទស្សន៍ភាពក្រីក្រពហុវិជ្ជភាព | |
|---|---|---|---|---|---|---|---|---|---|---|
| | តម្លៃ | តម្លៃ | ភាពខុសគ្នាពីលំដាប់ HDI | | តម្លៃ | លំដាប់ | តម្លៃ | លំដាប់ | | |
| | 2013 | 2013 | 2013[a] | 2013 | 2013 | 2013 | 2013 | 2013[b] | តម្លៃ[c] | ឆ្នាំ/អង្កេត[d] |
| 116 អ៊ូស្បេគីស្ថង់ | 0.661 | 0.556 | 14 | 15.3 | .. | .. | 0.945 | 82 | 0.013 | 2006 M |
| 117 ហ្វីលីពីន | 0.660 | 0.540 | 10 | 18.0 | 0.406 | 78 | 0.989 | 17 | 0.038[g,j] | 2008 D |
| 118 អាហ្វ្រិកខាងត្បូង | 0.658 | .. | .. | .. | 0.461 | 94 | .. | .. | 0.041 | 2012 N |
| 118 សាធារណរដ្ឋអារ៉ាប់សេរី | 0.658 | 0.518 | 4 | 20.8 | 0.556 | 125 | 0.851 | 127 | 0.024 | 2006 M |
| 120 អ៊ីរ៉ាក់ | 0.642 | 0.505 | 0 | 21.2 | 0.512 | 120 | 0.802 | 137 | 0.052 | 2011 M |
| 121 ហ្គាយយ៉ាណា | 0.638 | 0.522 | 10 | 18.0 | 0.524 | 113 | 0.985 | 25 | 0.031 | 2009 D |
| 121 វៀតណាម | 0.638 | 0.543 | 15 | 14.9 | 0.322 | 58 | .. | .. | 0.026 | 2010/2011 M |
| 123 ខេប វែគ | 0.636 | 0.511 | 4 | 19.4 | .. | .. | .. | .. | .. | .. |
| 124 មីក្រូនេស៊ី (រដ្ឋសហព័ន្ធ) | 0.630 | .. | .. | .. | .. | .. | .. | .. | .. | .. |
| 125 ហ្គាតេម៉ាឡា | 0.628 | 0.422 | –8 | 32.0 | 0.523 | 112 | 0.910 | 104 | .. | .. |
| 125 គៀរហ្គីស្តង់ | 0.628 | 0.519 | 10 | 16.9 | 0.348 | 64 | 0.976 | 39 | 0.013 | 2005/2006 M |
| 127 ណាមីប៊ី | 0.624 | 0.352 | –22 | 39.3 | 0.450 | 87 | 0.978 | 36 | 0.200 | 2006/2007 D |
| 128 ទីម័រលើស | 0.620 | 0.430 | –3 | 29.4 | .. | .. | 0.875 | 122 | 0.322 | 2009/2010 D |
| 129 ហុងឌុយរ៉ាស | 0.617 | 0.418 | –6 | 31.1 | 0.482 | 99 | 0.929 | 95 | 0.098[k] | 2011/2012 D |
| 129 ម៉ូរ៉ុកកូ | 0.617 | 0.433 | 0 | 28.5 | 0.460 | 92 | 0.828 | 132 | .. | .. |
| 131 វ៉ាណាទូ | 0.616 | .. | .. | .. | .. | .. | 0.900 | 110 | 0.135 | 2007 M |
| 132 នីការ៉ាហ្គា | 0.614 | 0.452 | 4 | 25.8 | 0.458 | 90 | 0.912 | 102 | 0.088 | 2011/2012 |
| 133 គីរីបាទី | 0.607 | 0.416 | –4 | 30.1 | .. | .. | .. | .. | .. | .. |
| 133 តាជីគីស្តង់ | 0.607 | 0.491 | 9 | 18.8 | 0.383 | 75 | 0.952 | 77 | 0.031 | 2012 D |
| 135 ឥណ្ឌា | 0.586 | 0.418 | 0 | 27.7 | 0.563 | 127 | 0.828 | 132 | 0.282 | 2005/2006 D |
| 136 ប៊ុយតង់ | 0.584 | 0.465 | 9 | 20.2 | 0.495 | 102 | .. | .. | 0.128 | 2010 M |
| 136 កម្ពុជា | 0.584 | 0.440 | 7 | 24.6 | 0.505 | 105 | 0.909 | 105 | 0.211 | 2010 D |
| 138 ហ្គាណា | 0.573 | 0.394 | –1 | 31.2 | 0.549 | 123 | 0.884 | 118 | 0.144 | 2011 M |
| 139 ឡាវ (សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិត) | 0.569 | 0.430 | 8 | 24.1 | 0.534 | 118 | 0.897 | 112 | 0.186 | 2011/2012 M |
| 140 កុងហ្គោ | 0.564 | 0.391 | 0 | 30.6 | 0.617 | 135 | 0.928 | 96 | 0.192 | 2011/2012 D |
| 141 ហ្សំប៊ី | 0.561 | 0.365 | –4 | 34.5 | 0.617 | 135 | 0.913 | 101 | 0.318 | 2007 D |
| 142 បង់ក្លាដែស | 0.558 | 0.396 | 4 | 28.7 | 0.529 | 115 | 0.908 | 107 | 0.237 | 2011 D |
| 142 សាវតូមេ និងព្រីនស៊ីពេ | 0.558 | 0.384 | 0 | 30.4 | .. | .. | 0.894 | 115 | 0.217 | 2008/2009 D |
| 144 អេក្វាតូរៀលហ្គីនេ | 0.556 | .. | .. | .. | .. | .. | .. | .. | .. | .. |
| **ការអភិវឌ្ឍមនុស្សទាប** | | | | | | | | | | |
| 145 នេប៉ាល់ | 0.540 | 0.384 | 3 | 27.8 | 0.479 | 98 | 0.912 | 102 | 0.197 | 2011 D |
| 146 ប៉ាគីស្ថង់ | 0.537 | 0.375 | 2 | 28.7 | 0.563 | 127 | 0.750 | 145 | 0.237 | 2012/2013 D |
| 147 កេនយ៉ា | 0.535 | 0.360 | 0 | 32.7 | 0.548 | 122 | 0.908 | 107 | 0.226 | 2008/2009 D |
| 148 ស្វាស៊ីលេន | 0.530 | 0.354 | –2 | 33.1 | 0.529 | 115 | 0.877 | 121 | 0.113 | 2010 M |
| 149 អង់ហ្គោឡា | 0.526 | 0.295 | –17 | 43.6 | .. | .. | .. | .. | .. | .. |
| 150 មីយ៉ាន់ម៉ា | 0.524 | .. | .. | .. | 0.430 | 83 | .. | .. | .. | .. |
| 151 រ្វាន់ដា | 0.506 | 0.338 | –4 | 33.1 | 0.410 | 79 | 0.950 | 80 | 0.352 | 2010 D |
| 152 កាមេរូន | 0.504 | 0.339 | –2 | 32.4 | 0.622 | 138 | 0.872 | 123 | 0.260 | 2011 D |
| 152 នីហ្សេរីយ៉ា | 0.504 | 0.300 | –14 | 40.2 | .. | .. | 0.839 | 131 | 0.239 | 2011 M |
| 154 យេម៉ែន | 0.500 | 0.336 | –2 | 31.7 | 0.733 | 152 | 0.738 | 146 | 0.191[g] | 2006 M |
| 155 ម៉ាដាហ្គាស្កា | 0.498 | 0.346 | 2 | 30.3 | .. | .. | 0.917 | 99 | 0.420 | 2008/2009 D |
| 156 ហ្ស៊ីមបាវេ | 0.492 | 0.358 | 7 | 26.8 | 0.516 | 110 | 0.909 | 105 | 0.181 | 2010/2011 D |
| 157 ប៉ាពូញ៉ូហ្គីនេ | 0.491 | .. | .. | .. | 0.617 | 135 | .. | .. | .. | .. |
| 157 កោះសូឡូម៉ុង | 0.491 | 0.374 | 11 | 23.8 | .. | .. | .. | .. | .. | .. |
| 159 កូម៉ូរ៉ូស | 0.488 | .. | .. | .. | .. | .. | .. | .. | .. | .. |
| 159 តង់ហ្សានី (សហភាពសាធារណរដ្ឋ) | 0.488 | 0.356 | 8 | 26.9 | 0.553 | 124 | 0.916 | 100 | 0.335 | 2010 D |
| 161 ម៉ូរីតានី | 0.487 | 0.315 | –2 | 34.6 | 0.644 | 142 | 0.801 | 138 | 0.362 | 2007 M |
| 162 ឡេសូថូ | 0.486 | 0.313 | –2 | 34.9 | 0.557 | 126 | 0.973 | 43 | 0.227 | 2009 D |
| 163 សេនេហ្គាល់ | 0.485 | 0.326 | 3 | 32.3 | 0.537 | 119 | 0.864 | 124 | 0.390 | 2010/2011 D |
| 164 យូហ្គាន់ដា | 0.484 | 0.335 | 5 | 30.8 | 0.529 | 115 | 0.896 | 114 | 0.359 | 2011 D |
| 165 បេនីន | 0.476 | 0.311 | 0 | 34.2 | 0.614 | 134 | 0.822 | 134 | 0.401 | 2006 D |
| 166 ស៊ូដង់ | 0.473 | .. | .. | .. | 0.628 | 140 | .. | .. | .. | .. |
| 166 តូហ្គោ | 0.473 | 0.317 | 4 | 32.6 | 0.579 | 129 | 0.803 | 136 | 0.260 | 2010 M |
| 168 ហៃទី | 0.471 | 0.285 | –3 | 38.9 | 0.599 | 132 | .. | .. | 0.242 | 2012 D |
| 169 អាហ្វកានីស្តង់ | 0.468 | 0.321 | 7 | 30.0 | 0.705 | 150 | 0.602 | 148 | 0.293[g] | 2010/2011 M |
| 170 ជីប៊ូទី | 0.467 | 0.306 | 2 | 33.7 | .. | .. | .. | .. | 0.127 | 2006 M |
| 171 កូដឌីវ័រ | 0.452 | 0.279 | –2 | 37.9 | 0.645 | 143 | .. | .. | 0.307 | 2011/2012 D |
| 172 ហ្គាំប៊ី | 0.441 | .. | .. | .. | 0.624 | 139 | .. | .. | 0.329 | 2005/2006 M |
| 173 អេត្យូពី | 0.435 | 0.307 | 5 | 28.0 | 0.547 | 121 | 0.853 | 126 | 0.537 | 2011 D |

| លំដាប់ HDI | សន្ទស្សន៍អភិវឌ្ឍន៍មនុស្ស | HDI កែតម្រូវតាមវិសមភាព | | មេគុណវិសមភាពមនុស្ស | សន្ទស្សន៍វិសមភាពយេនឌ័រ | | សន្ទស្សន៍អភិវឌ្ឍន៍ទាក់ទងនឹងយេនឌ័រ | | សន្ទស្សន៍ភាពក្រីក្រពហុទិដ្ឋភាព | |
|---|---|---|---|---|---|---|---|---|---|---|
| | តម្លៃ | តម្លៃ | ភាពខុសគ្នាពីលំដាប់ HDI | | តម្លៃ | លំដាប់ | តម្លៃ | លំដាប់ | | |
| | 2013 | 2013 | 2013[a] | 2013 | 2013 | 2013 | 2013 | 2013[b] | តម្លៃ[c] | ឆ្នាំ/អង្កេត[d] |
| 174 ម៉ាឡាវី | 0.414 | 0.282 | 1 | 31.6 | 0.591 | 131 | 0.891 | 116 | 0.332 | 2010 D |
| 175 លីបេរី | 0.412 | 0.273 | –1 | 32.8 | 0.655 | 145 | 0.786 | 140 | 0.459 | 2007 D |
| 176 ម៉ាលី | 0.407 | .. | .. | .. | 0.673 | 148 | 0.771 | 143 | 0.533 | 2006 D |
| 177 ហ្គីនេ-ប៊ីសូ | 0.396 | 0.239 | –4 | 39.4 | .. | .. | .. | .. | 0.495 | 2006 M |
| 178 ម៉ូហ្សំប៊ិក | 0.393 | 0.277 | 2 | 28.9 | 0.657 | 146 | 0.879 | 120 | 0.390 | 2011 D |
| 179 ហ្គីនេ | 0.392 | 0.243 | –1 | 37.8 | .. | .. | 0.785 | 141 | 0.548 | 2005 D |
| 180 ប៊ូរុនឌី | 0.389 | 0.257 | 2 | 32.6 | 0.501 | 104 | 0.904 | 109 | 0.442 | 2010 D |
| 181 ប៊ូគីណាហ្វាសូ | 0.388 | 0.252 | 2 | 34.6 | 0.607 | 133 | 0.924 | 97 | 0.508 | 2010 D |
| 182 អេរីទ្រា | 0.381 | .. | .. | .. | .. | .. | .. | .. | .. | .. |
| 183 សេរ៉ាឡេអូន | 0.374 | 0.208 | –3 | 43.6 | 0.643 | 141 | 0.799 | 139 | 0.405 | 2010 M |
| 184 ឆាត | 0.372 | 0.232 | 1 | 36.8 | 0.707 | 151 | 0.762 | 144 | .. | .. |
| 185 សាធារណរដ្ឋអាហ្វ្រិកកណ្តាល | 0.341 | 0.203 | –2 | 39.9 | 0.654 | 144 | 0.776 | 142 | 0.424 | 2010 M |
| 186 កុងហ្គោ (សាធារណរដ្ឋប្រជាធិបតេយ្យ) | 0.338 | 0.211 | 1 | 36.8 | 0.669 | 147 | 0.822 | 134 | 0.399 | 2010 M |
| 187 នីហ្សេរ | 0.337 | 0.228 | 3 | 31.8 | 0.674 | 149 | 0.714 | 147 | 0.584 | 2012 D |
| **ប្រទេស និងដែនដីដទៃទៀត** | | | | | | | | | | |
| កូរ៉េ (សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិត) | .. | .. | .. | .. | .. | .. | .. | .. | .. | .. |
| កោះម៉ាស្សាល់ | .. | .. | .. | .. | .. | .. | .. | .. | .. | .. |
| ម៉ូណាកូ | .. | .. | .. | .. | .. | .. | .. | .. | .. | .. |
| ណៅរូ | .. | .. | .. | .. | .. | .. | .. | .. | .. | .. |
| សានម៉ារីណូ | .. | .. | .. | .. | .. | .. | .. | .. | .. | .. |
| សូម៉ាលី | .. | .. | .. | .. | .. | .. | .. | .. | 0.500 | 2006 M |
| ស៊ូដង់ខាងត្បូង | .. | .. | .. | .. | .. | .. | .. | .. | .. | .. |
| ទូវ៉ាលូ | .. | .. | .. | .. | .. | .. | .. | .. | .. | .. |
| **ក្រុមសន្ទស្សន៍អភិវឌ្ឍន៍មនុស្ស** | | | | | | | | | | |
| ការអភិវឌ្ឍមនុស្សខ្ពស់ខ្លាំង | 0.890 | 0.780 | — | 12.0 | 0.197 | — | 0.975 | — | — | — |
| ការអភិវឌ្ឍមនុស្សខ្ពស់ | 0.735 | 0.590 | — | 19.3 | 0.315 | — | 0.946 | — | — | — |
| ការអភិវឌ្ឍមនុស្សមធ្យម | 0.614 | 0.457 | — | 25.2 | 0.512 | — | 0.875 | — | — | — |
| ការអភិវឌ្ឍមនុស្សទាប | 0.493 | 0.332 | — | 32.4 | 0.587 | — | 0.834 | — | — | — |
| **តំបន់** | | | | | | | | | | |
| រដ្ឋអារ៉ាប់ | 0.682 | 0.512 | — | 24.2 | 0.546 | — | 0.866 | — | — | — |
| អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក | 0.703 | 0.564 | — | 19.5 | 0.331 | — | 0.943 | — | — | — |
| អឺរ៉ុប និងអាស៊ីកណ្តាល | 0.738 | 0.639 | — | 13.2 | 0.317 | — | 0.938 | — | — | — |
| អាមេរិកឡាទីន និងការ៉ាអ៊ីប | 0.740 | 0.559 | — | 23.9 | 0.416 | — | 0.963 | — | — | — |
| អាស៊ីខាងត្បូង | 0.588 | 0.419 | — | 28.0 | 0.539 | — | 0.830 | — | — | — |
| តំបន់សាហារ៉ាក្បែរអាហ្វ្រិក | 0.502 | 0.334 | — | 33.5 | 0.578 | — | 0.867 | — | — | — |
| **ប្រទេសអភិវឌ្ឍន៍តិចតួច** | 0.487 | 0.336 | — | 30.9 | 0.570 | — | 0.859 | — | — | — |
| **រដ្ឋកំពុងអភិវឌ្ឍន៍លើកោះតូចៗ** | 0.665 | 0.497 | — | 24.9 | 0.478 | — | .. | — | — | — |
| **ពិភពលោក** | **0.702** | **0.541** | **—** | **22.8** | **0.451** | **—** | **0.920** | **—** | **—** | **—** |

## សំគាល់

a ផ្អែកតាមប្រទេសនានាដែលមានការគណនាសន្ទស្សន៍អភិវឌ្ឍន៍មនុស្សដោយកែសម្រួលតាមវិសមភាព

b លំដាប់នៃប្រទេសគិតតាមគម្លាតដាច់ខាតធៀបនឹងភាពដូចគ្នាខាងយេនឌ័រនៅក្នុង HDI.

c សន្ទស្សន៍ភាពក្រីក្រពហុទិដ្ឋភាពដែលបានកែសម្រួល ផ្អែកតាមនិយមន័យដែលបានកែសម្រួលអំពីការខ្វះខាតលើទិដ្ឋភាពចំនួនបី ពោលគឺ សុខភាព ការអប់រំ និងស្តង់ដារនៃការរស់នៅ ដូចមានចែងនៅក្នុងកំណត់សំគាល់បច្ចេកទេសទី 5 នៅក្នុង http://hdr.undp.org/en.

d មិនមែនសុទ្ធតែមានសូចនាករសម្រាប់ប្រទេសទាំងអស់ឡើយ។ គួរប្រើប្រាស់ដោយប្រុងប្រយ័ត្នក្នុងការប្រៀបធៀបរវាងប្រទេស។ ក្នុងករណីគ្មានទិន្នន័យ មានការកែសម្រួលសូចនាករដើម្បីឱ្យផលបូកស្មើ 100 ភាគរយ។ ចំពោះសេចក្តីពិស្តារសម្រាប់ប្រទេសដែលគ្មានទិន្នន័យ សូមអាន Alkire and others (2011).

e D បង្ហាញទិន្នន័យដែលបានពីការអង្កេតប្រជាសាស្ត្រនិងសុខភាព។ M បង្ហាញពីទិន្នន័យបានពីការអង្កេតក្រុមពហុសូចនាករ និង N បង្ហាញថាទិន្នន័យបានពីការអង្កេតថ្នាក់ជាតិ។

f សំដៅលើទិន្នន័យបានតែពីទីក្រុងនៅក្នុងប្រទេសនោះប៉ុណ្ណោះ។

g គ្មានសូចនាករអំពីមរណភាពកុមារ។

h គ្មានសូចនាករអំពីអាហារូបត្ថម្ភ

i សំដៅតែលើផ្នែកមួយនៃផ្ទៃប្រទេស (ខេត្តចំនួន 9)

j គ្មានសូចនាករអំពីប្រភេទក្តារក្រាល

k គ្មានសូចនាករអំពីឥន្ធនៈសម្រាប់ការចំអិនអាហារ

l គ្មានសូចនាករអំពីកុមារចូលរៀន

m គ្មានសូចនាករអំពីអគ្គិសនី

## ប្រភព

**ជួរឈរ 1**: ការគណនារបស់ HDRO បានផ្អែកលើទិន្នន័យ ដែលបានពី UNDESA (2013a), Barro and Lee (2013), UNESCO Institute for Statistics (2013), UN Statistics Division(2014), World Bank (2014) and IMF (2014).

**ជួរឈរ 2**: ការគណនារបស់ HDRO បានផ្អែកលើជួរឈរទី 1 និងវិសមភាពជារបាយក្នុងអាយុកាលដែលរំពឹងទុក ចំនួនឆ្នាំដែលបានរៀន និងប្រាក់ចំណូល ឬ ការប្រើប្រាស់ដូចមានពន្យល់ក្នុងកំណត់សំគាល់បច្ចេកទេស 2

**ជួរឈរ 3**:
បានគណនាដោយផ្អែកតាមទិន្នន័យក្នុងជួរឈរ 2 និងគណនាជាបន្តអំពីលំដាប់ HDI សម្រាប់ប្រទេសនានាដែលមាន HDI កែតម្រូវតាមវិសមភាព

**ជួរឈរ 4**:
បានគណនាជាមធ្យមនព្វន្តនៃវិសមភាពដែលបានប៉ាន់ស្មានក្នុងទិដ្ឋភាពទាំងបីនៃ HDI ដូចមានពន្យល់ក្នុងកំណត់សំគាល់បច្ចេកទេស 2

**ជួរឈរ 5**: ការគណនារបស់ HDRO បានផ្អែកតាមក្រុមប៉ាន់ស្មានរបស់ UN អំពីមរណភាពមាតា (2013), UNDESA (2013a), IPU (2013), Barro and Lee (2013), UNESCO Institute for Statistics (2013) and ILO (2013a).

**ជួរឈរ 6 និង 7**: ការគណនារបស់ HDRO ផ្អែកលើទិន្នន័យពី UNDESA (2013a), Barro and Lee (2013), UN Statistics Division(2014), UNESCO Institute for Statistics (2013b), World Bank (2014) and ILO (2014).

**ជួរឈរ 9 និង 10**:
បានគណនាតាមការអង្កេតប្រជាសាស្ត្រ និងសុខភាពនៅកម្រិតម៉ាក្រូ ដោយ ICF (DHS), ការអង្កេតក្រុមសូចនាករច្រើនមុខរបស់មូលនិធិសហប្រជាជាតិដើម្បីកុមារ (MICS) និងក្នុងករណីខ្លះបានពីការអង្កេតតាមគ្រួសារនៅថ្នាក់ជាតិ ដោយផ្អែកតាមវិធីសាស្ត្រ DHS ឬ MICS

**របាយការណ៍អភិវឌ្ឍន៍មនុស្សពិភពលោក៖** របាយការណ៍អភិវឌ្ឍន៍មនុស្សឆ្នាំ 2014 គឺជារបាយការណ៍ចុងក្រោយនៅក្នុងចំណោមរបាយការណ៍អភិវឌ្ឍន៍មនុស្សពិភពលោកដែលចេញផ្សាយជាបន្តបន្ទាប់ដោយ UNDP តាំងពីឆ្នាំ 1990 មក ដែលជាការវិភាគឯករាជ្យនិងសំអាងលើបទពិសោធន៍អំពីកិច្ចការ និន្នាការ និងគោលនយោបាយអភិវឌ្ឍន៍ចំបងៗ។

ឯកសារបន្ថែមទៀតដែលទាក់ទងនឹងរបាយការណ៍អភិវឌ្ឍន៍មនុស្សឆ្នាំ 2014 មាននៅក្នុងវេបសាយ hdr.undp.org, ជាអាទិ៍ អត្ថបទទាំងស្រុង ឬ សេចក្តីសង្ខេបជាភាសាខុសៗគ្នាច្រើនជាង 20 ភាសា បណ្តាឯកសារស្រាវជ្រាវការអភិវឌ្ឍមនុស្ស ដែលបានប្រមូលផ្តុំសម្រាប់ការរៀបចំរបាយការណ៍ឆ្នាំ 2014 នេះ ផែនទីអន្តរកម្ម និងកម្រងទិន្នន័យអំពីសូចនាករអភិវឌ្ឍន៍មនុស្សនៅថ្នាក់ជាតិ សេចក្តីពន្យល់ទាំងស្រុងអំពីប្រភព និងវិធីសាស្ត្រដែលប្រើប្រាស់នៅក្នុងសន្ទស្សន៍អភិវឌ្ឍន៍ដែលមានក្នុងរបាយការណ៍នេះ និងឯកសារសារពត៌មានានាដទៃទៀត។ របាយការណ៍អភិវឌ្ឍន៍មនុស្ស (HDRs) កន្លងមកនៅកម្រិតពិភពលោក តំបន់ និងជាតិក៏មាននៅក្នុងវេបសាយតាមអាសយដ្ឋាននេះផងដែរ hdr.undp.org។

**របាយការណ៍អភិវឌ្ឍន៍មនុស្សថ្នាក់តំបន់៖** ក្នុងរយៈពេលច្រើនជាងពីរទសវត្សរ៍កន្លងទៅនេះ របាយការណ៍ HDRs ដែលផ្តោតលើថ្នាក់តំបន់ត្រូវបានបោះពុម្ពសម្រាប់តំបន់ចំបងៗទាំងអស់នៃបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ដោយមានការគាំទ្រពីការិយាល័យថ្នាក់តំបន់របស់ UNDP។ ជាមួយការវិភាគបង្ហាញហេតុផល និងអនុសាសន៍ច្បាស់លាស់សម្រាប់គោលនយោបាយរបាយការណ៍ HDRs ថ្នាក់តំបន់ បានពិនិត្យមើលកិច្ចការសំខាន់ៗទាក់ទងនឹងការពង្រឹងសិទ្ធិអំណាចនយោបាយនៅក្នុងបណ្តារដ្ឋអារ៉ាប់ សន្តិសុខស្បៀងនៅអាហ្វ្រិក ការប្រែប្រួលអាកាសធាតុនៅអាស៊ី ការប្រព្រឹត្តចំពោះក្រុមជនជាតិដើមភាគតិចនៅអឺរ៉ុបកណ្តាល និងការប្រឈមនានានៃវិសមភាព និងសន្តិសុខរបស់ពលរដ្ឋនៅអាមេរិកឡាទីន និងតំបន់ការ៉ាអ៊ីប។

**របាយការណ៍អភិវឌ្ឍន៍មនុស្សថ្នាក់ជាតិ៖** ចាប់តាំងពីពេលចេញរបាយការណ៍ HDR ថ្នាក់ជាតិជាលើកដំបូងនៅឆ្នាំ 1992 របាយការណ៍ HDRs នៅថ្នាក់ជាតិត្រូវបានផលិតនៅក្នុងប្រទេសចំនួន 140 ដោយក្រុមអ្នកនិពន្ធតាមមូលដ្ឋាន និងមានការគាំទ្រពី UNDP។ របាយការណ៍ទាំងនេះ ដែលមកទល់បច្ចុប្បន្នមានប្រមាណ 700 បាននាំយកទស្សនវិស័យនៃការអភិវឌ្ឍមនុស្សទៅផ្សារភ្ជាប់ជាមួយកង្វល់នានានៃគោលនយោបាយនៅថ្នាក់ជាតិ តាមរយៈការពិគ្រោះយោបល់ និងការស្រាវជ្រាវនៅមូលដ្ឋាន។ របាយការណ៍ HDRs នៅថ្នាក់ជាតិ បង្ហាញពីកិច្ចការអភិវឌ្ឍន៍សំខាន់ៗជាច្រើន ដែលរាប់ចាប់ពីការប្រែប្រួលអាកាសធាតុរហូតដល់ភាពមានការងារធ្វើរបស់យុវជន និងវិសមភាព ដែលជម្រុញដោយបញ្ហាយេនឌ័រ និងជាតិពន្ធុ។

## របាយការណ៍អភិវឌ្ឍន៍មនុស្ស ឆ្នាំ 1990-2014

| | |
|---|---|
| 1990 | សញ្ញាណ និងរង្វាស់ការអភិវឌ្ឍមនុស្ស |
| 1991 | ហិរញ្ញប្បទានការអភិវឌ្ឍមនុស្ស |
| 1992 | ទិដ្ឋភាពសកលនៃការអភិវឌ្ឍមនុស្ស |
| 1993 | ការចូលរួមរបស់ប្រជាជន |
| 1994 | ទិដ្ឋភាពថ្មីនៃសន្តិសុខមនុស្ស |
| 1995 | យេនឌ័រ និងការអភិវឌ្ឍមនុស្ស |
| 1996 | កំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍមនុស្ស |
| 1997 | ការអភិវឌ្ឍមនុស្ស ដើម្បីលុបបំបាត់ភាពក្រីក្រ |
| 1998 | ការប្រើប្រាស់សម្រាប់ការអភិវឌ្ឍមនុស្ស |
| 1999 | សកលភាវូបនីយកម្មជាមួយមុខមាត់មនុស្ស |
| 2000 | សិទ្ធិមនុស្ស និងការអភិវឌ្ឍមនុស្ស |
| 2001 | ការធ្វើឱ្យបច្ចេកវិទ្យាថ្មីៗមានប្រយោជន៍សម្រាប់ការអភិវឌ្ឍមនុស្ស |
| 2002 | ពង្រឹងគ្រឹះប្រជាធិបតេយ្យនៅក្នុងពិភពលោកមួយដែលខ្វះសុខដុមរមនា |
| 2003 | គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍៖ កិច្ចសន្យាក្នុងចំណោមប្រជាជាតិនានាដើម្បីបញ្ចប់ភាពក្រីក្រនៃមនុស្ស |
| 2004 | សេរីភាពវប្បធម៌នៅក្នុងពិភពលោកចម្រុះមួយនាសម័យបច្ចុប្បន្ន |
| 2005 | កិច្ចសហប្រតិបត្តិការអន្តរជាតិនៅត្រង់ផ្លូវបំបែក៖ ជំនួយ ពាណិជ្ជកម្ម និងសន្តិសុខក្នុងពិភពលោកមួយដែលគ្មានសមភាព |
| 2006 | ហួសពីភាពកម្រ៖ អំណាច ភាពក្រីក្រ និងវិបត្តិទឹកលើពិភពលោក |
| 2007/2008 | ប្រយុទ្ធនឹងការប្រែប្រួលអាកាសធាតុ៖ សាមគ្គីភាពនៃមនុស្សនៅក្នុងពិភពលោកមួយដែលមានការបែងចែក |
| 2009 | ការកំចាត់ចោលរបាំងនានា៖ សាមគ្គីភាពរបស់មនុស្ស និងការអភិវឌ្ឍ |
| 2010 | សម្បត្តិពិតប្រាកដរបស់ប្រជាជាតិ៖ មាគ៌ាឆ្ពោះទៅការអភិវឌ្ឍមនុស្ស |
| 2011 | និរន្តរភាព និងសមធម៌៖ អនាគតប្រសើរជាងមុនមួយសម្រាប់ទាំងអស់គ្នា |
| 2013 | ការងើបឡើងនៃភូមិភាគខាងត្បូង៖ វឌ្ឍនភាពមនុស្សនៅក្នុងពិភពលោកចម្រុះមួយ |
| 2014 | ទ្រទ្រង់វឌ្ឍនភាពមនុស្ស៖ កាត់បន្ថយភាពងាយរងគ្រោះ និងកសាងភាពធន់ |

United Nations Development Programme
One United Nations Plaza
New York, NY 10017

www.undp.org

ប្រជាជនជាង 200 លាននាក់ក្នុងមួយឆ្នាំ ដែលភាគច្រើនស្ថិតនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ បានរងគ្រោះដោយសារគ្រោះមហន្តរាយធម្មជាតិ។ ចំនួនប្រជាជនដែលបានជម្លៀសដោយសារជម្លោះ ឬការធ្វើទុក្ខបុកម្នេញចំនួន 45 លាននាក់ រហូតដល់ចុងឆ្នាំ 2012 គឺជាចំនួនខ្ពស់បំផុតក្នុងរយៈពេល 18 ឆ្នាំ។ ការថមថយសេដ្ឋកិច្ចបានគំរាមកំហែងធ្វើឱ្យខូចខាតសមិទ្ធផលផ្នែកសង្គមកន្លងមក សូម្បីក្នុងសង្គមមានឧស្សាហកម្មជឿនលឿនក៏ដោយ។ ជាមួយនឹងការនាំមកនូវអត្ថប្រយោជន៍ជាច្រើន សកលភាវូបនីយកម្មក៏បាននាំមកនូវភាពងាយរងគ្រោះថ្មីៗផងដែរ ពោលគឺការប៉ះទង្គិចក្នុងផ្នែកមួយនៃពិភពលោក អាចរីកសាយយ៉ាងឆាប់រហ័សដែលបង្កការប៉ះពាល់ដល់អាយុជីវិតរបស់ប្រជាជននៅគ្រប់កន្លែង។

របាយការណ៍ឆ្នាំ 2014 គូសបញ្ជាក់ពីភាពចាំបាច់ដើម្បីលើកកំពស់ជម្រើសរបស់ប្រជាជន និងកិច្ចការពារសមិទ្ធផលអភិវឌ្ឍន៍មនុស្ស។ របាយការណ៍នេះ សង្កត់ធ្ងន់ពីសារៈសំខាន់នៃការកំណត់អត្តសញ្ញាណ និងការដោះស្រាយភាពងាយរងគ្រោះរ៉ាំរ៉ៃ ដោយបង្កើតភាពធន់ និងពង្រឹងសមត្ថភាព ដើម្បីទប់ទល់នឹងការប៉ះទង្គិច ខាងហិរញ្ញវត្ថុ ធម្មជាតិ ឬ ប្រការផ្សេងទៀត។

ទោះបីមនុស្សស្ទើរគ្រប់រូប ទំនងជាមានអារម្មណ៍ថាងាយរងគ្រោះនៅក្នុងដំណាក់កាលណាមួយក្នុងជីវិតក៏ដោយ បុគ្គល និងក្រុមខ្លះកាន់តែមានស្ថានភាពធ្ងន់ធ្ងរជាងមុនជាប់ជាប្រចាំ។ ប្រជាជនជិត 1,5 ពាន់លាននាក់ គឺជាអ្នកក្រីក្រលើទិដ្ឋភាពជាច្រើន ដោយមានការបាត់បង់ជាច្រើនបែបត្រួតគ្នាទាំងខាងសុខភាព ការអប់រំ និងស្តង់ដារនៃការរស់នៅ។ ប្រជាជនជិត 800លាននាក់ ងាយនឹងធ្លាក់ទៅក្នុងភាពក្រីក្រនៅពេលដែលវិបត្តិសេដ្ឋកិច្ចកើតឡើង។ របាយការណ៍នេះផ្តោតលើប្រជាពលរដ្ឋដែលមានហានិភ័យខ្លាំងបំផុត និងលើបុព្វហេតុសំខាន់ៗនៃភាពងាយរងគ្រោះ។ របាយការណ៍នេះវិភាគរចនាសម្ព័ន្ធនៃមូលហេតុ ពោលគឺ ភាពទន់ខ្សោយខាងសង្គម ស្ថានភាពនៅក្នុងសង្គម និងសេវាសាធារណៈដែលមានមិនគ្រប់គ្រាន់ និងផ្តោតការយកចិត្តទុកដាក់លើភាពងាយរងគ្រោះខុសៗគ្នា ដែលប្រឈមនៅក្នុងដំណាក់កាលខុសៗគ្នាក្នុងជីវិត។

មុខសញ្ញាគ្រោះថ្នាក់ និងការប៉ះទង្គិច នឹងកើតឡើងដោយជៀសពុំរួច ប៉ុន្តែ គេអាចចាត់វិធានការដើម្បីកំហិតលើវិសាលភាពនៃឥទ្ធិពលរបស់ព្រឹត្តិការណ៍ទាំងនេះ ក្នុងការកាត់បន្ថយការអភិវឌ្ឍមនុស្ស។ របាយការណ៍នេះអះអាងថា ការប៉ះទង្គិចភាគច្រើនអាចជំនះបាន តាមរយៈគោលនយោបាយសមស្រប និងការប្តេជ្ញាម៉ឺងម៉ាត់ក្នុងការធ្វើឱ្យមានភាពចុះសម្រុងក្នុងសង្គម។ ការប្រើយន្តការសម្រាប់កំណត់បញ្ហាពីដំបូង និងការវិនិយោគសមល្មមនៅក្នុងពេលសមស្រប ជាញឹកញាប់អាចកាត់បន្ថយភាពងាយរងគ្រោះ និងបង្កើតភាពធន់បានច្រើន។ ដូច្នេះវិធីសាស្រ្តនៃការអភិវឌ្ឍមនុស្សនឹងមិនមានភាពពេញលេញទេ លើកលែងតែវាបានរួមបញ្ចូលភាពងាយរងគ្រោះ និងភាពធន់ទៅក្នុងការវិភាគ។ ការកំណត់អត្តសញ្ញាណ និងការផ្តោតលើក្រុមងាយរងគ្រោះ ការកាត់បន្ថយវិសមភាព និងការដោះស្រាយភាពងាយរងគ្រោះដែលមានរចនាសម្ព័ន្ធមានសារៈសំខាន់ជាសារវន្ត ដែលផ្តល់នូវវឌ្ឍនភាពមនុស្សបានរឹងមាំ និងមាននិរន្តរភាពរវាងជំនាន់មនុស្ស។

*"តាមរយៈការដោះស្រាយភាពងាយរងគ្រោះ ពលរដ្ឋទាំងអស់អាចចែករម្លែកវឌ្ឍនភាពនៃការអភិវឌ្ឍ ហើយការអភិវឌ្ឍមនុស្សនឹងកាន់តែមានសមធម៌ និងនិរន្តរភាព។"*

—ប្រធានកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ ហេឡិន ក្លាក

*"ភាពងាយរងគ្រោះមានឫសគល់ និងផលវិបាកជាច្រើន។ ការកាត់បន្ថយភាពងាយរងគ្រោះគឺជាធាតុផ្សំគន្លឹះមួយសម្រាប់កែលម្អការអភិវឌ្ឍមនុស្ស។ ប៉ុន្តែ ដើម្បីទទួលជោគជ័យក្នុងការកាត់បន្ថយភាពងាយរងគ្រោះ យើងត្រូវដោះស្រាយបញ្ហានេះតាមរយៈទស្សនទានធំទូលាយជាលក្ខណៈប្រព័ន្ធ។"*

—ជ័យលាភីរង្វាន់ណូបែល ចូហ្សេប ស្ទីកលីត្ស ដកស្រង់ពីជំពូកទី 4

*"ភាពធន់របស់មនុស្សគឺជាការកំចាត់ចោលរបាំងនានាដែលរារាំងមនុស្សមិនឱ្យមានសេរីភាពក្នុងការធ្វើសកម្មភាព។ វាក៏ជាការផ្តល់លក្ខខណ្ឌអំណោយផលដល់ក្រុមជនក្រីក្រ និងគ្មានការរាប់រកក្នុងសង្គម ដើម្បីសំដែងកង្វល់របស់ខ្លួន ដើម្បីឱ្យអ្នកដទៃបានដឹង និងដើម្បីក្លាយជាភ្នាក់ងារសកម្មនៅក្នុងការគូសវាសវាសនាអនាគតរបស់ខ្លួនផងដែរ ។"*

—អ្នកនាំមុខក្នុងការរៀបរៀងរបាយការណ៍នេះ ខាលីត ម៉ាលីក ដកស្រង់ពីជំពូក 1

*"ទោះបីមានវឌ្ឍនភាពច្រើនបែបច្រើនយ៉ាងហើយក៏ដោយ ពលរដ្ឋនិងក្រុមមនុស្សខ្លះនៅតែងាយរងគ្រោះនៅឡើយ ចំណែកក្រុមជនពិការរឹតតែងាយរងគ្រោះជាងនេះទៅទៀត។ អង្គការសហប្រជាជាតិប៉ាន់ស្មានថាមនុស្សច្រើនជាងមួយពាន់លាននាក់ រស់នៅជាមួយទម្រង់ណាមួយនៃពិការភាព ហើយពួកគេស្ថិតក្នុងវិសមាមាត្រធំមួយក្នុងចំណោមអ្នកក្រីក្រជាងគេលើពិភពលោក។"*

—សាស្រ្តចារ្យ ស្តេហ្វេន ហកគីន អ្នកទ្រឹស្តីរូបវិទ្យា នៅសកលវិទ្យាល័យខេមប្រ៊ីជ ដកស្រង់ពីជំពូក 1